សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **តិន រ័ត្ននិមិត្ត**
លោក **ធី មួយអេង**

សាស្ត្រាចារ្យណែនាំ
លោក **ហោ សុភ័ណ្ណ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ភិន រ័ត្ននិមិត្ត និង ធី មួយអេង ជានិស្សិតបរិញ្ញាបត្រច្បាប់ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**ជាបឋមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

- **លោកអ្នកមានគុណទាំងពីរ** ដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងបានចិញ្ចឹមបីបាច់ថែរក្សាប្រៀនប្រដៅអប់រំទូន្មានយើងខ្ញុំតាំងពីតូចមក និងបានផ្គត់ផ្គង់សព្វបែបយ៉ាងទាំងសម្ភារៈ និងកម្លាំងចិត្តដើម្បីលើកទឹកចិត្តកូនអោយកូនចេះស្រឡាញ់ការក្នុងការសិក្សា ខិតខំប្រឹងប្រែងរៀនសូត្រដើម្បីជាដើមទុនទៅថ្ងៃអនាគត។ ទាំងនេះសបញ្ជាក់អោយឃើញថាគុណរបស់លោកទាំងពីរ មិនអាចពិពណ៌នាបានឡើង។ ដើម្បីតបស្នងអ្នកមានគុណទាំងពីរ កូនបានខិតខំប្រឹងប្រែងរៀនសូត្រហើយនាំមកពិន្ទុដ៏ល្អ ដែលអាចឈានដល់ការធ្វើសារណាបញ្ចប់ការសិក្សា និងឡើងការពារស្នាដៃដែលពួកកូនបានសិក្សាស្រាវជ្រាវនេះ កូននឹងបញ្ចប់បរិញ្ញាបត្រសិក្សានាពេលដ៏ខ្លីខាងមុខនេះ។
- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសដល់យើងខ្ញុំបានទទួលនូវចំនេះដឹងបន្ថែតាមរយៈ ការសរសេរសារណាបញ្ចប់ការសិក្សានេះ។
- លោក **ហោ សុវ័ណ្ណា** សាស្ត្រាចារ្យណែនាំ បានចំណាយពេលវេលាដ៏មានតម្លៃចង្អុលបង្ហាញផ្លូវណែនាំរាល់ការសរសេរ គាត់តែងប្លង់ និងកែប្រែកំហុសឆ្គងរបស់យើងខ្ញុំដើម្បីអោយទទួលបានសមិទ្ធិផលមួយដែលមានសារៈប្រយោជន៍ និងមានគុណភាព។
- លោកឧត្តមសេនីយ៍ឯក **គន ម៉ូរ៉ាមី** ប្រធាននាយកដ្ឋានអនុវត្តន៍ច្បាប់នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នឹងជាអនុរដ្ឋលេខាធិការនៃគណៈកម្មារជាតិគ្រប់គ្រងភារវកម្ម ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយត្រួតពិនិត្យ និងរៀបចំកិច្ចការស្រាវជ្រាវនេះឲ្យមានភាពល្អប្រសើរ ។
- **លោក/លោកស្រីសាស្ត្រចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានប្រឹងប្រែងបង្ហាត់បង្រៀនផ្ទេរនូវចំនេះវិជ្ជាដល់យើងខ្ញុំតាំងពីថ្នាក់មូលដ្ឋានមកដល់ឆ្នាំទី៤ ដែលជាឆ្នាំបញ្ចប់បរិញ្ញាបត្រនេះ ។
- **មិត្តភក្តិរួមជំនាន់ទាំងអស់** ដែលបានជួយចែករំលែកគំនិត បញ្ចេញយោបល់ និងផ្តល់កម្លាំងចិត្តដល់ពួកយើងខ្ញុំ។

យើងខ្ញុំសូមគោរពជូនពរ និងលើកហត្ថទាំងទ្វេបួងសួងដល់ទេវតា វត្ថុស័ក្តិសិទ្ធិដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងមូល សូមជួយថែរក្សាលោកអ្នកមានគុណ ឯកឧត្តមបណ្ឌិត លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តទាំងអស់ដែលបានជួយទំនុកបម្រុងក្នុងកិច្ចការសារណានេះ សូមអោយជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀតឃ្លាតឡើយ និងសូមអោយទទួលបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

សារណានេះត្រូវបានតាក់តែងឡើង ក្រោយពីបានធ្វើការសិក្សាអស់រយៈពេលជិត ៤ ឆ្នាំនៅថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាឆមាសចុងក្រោយនៃឆ្នាំទី ៤ នេះក៏ឈានដល់តំណាក់កាលមួយគឺ ការសរសេរសារណាបញ្ចប់ការសិក្សាតែ ម្តង ។ សារណានេះបានតាក់តែងឡើងជាស្នាដៃថ្មីមួយ ដើម្បីបានជាគុណប្រយោជន៍ដល់ការសិក្សា សម្រាប់និស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយៗទៀត។

រយៈពេលជិត៤ ឆ្នាំកន្លងមកនេះ មានមុខវិជ្ជាជាច្រើនដែលយើងខ្ញុំបានសិក្សានៅក្នុងជំនាញនីតិសាស្ត្រនេះ មិនថានីតិឯកជន ឬនីតិសាធារណៈទេ សុទ្ធសឹងតែជាមុខវិជ្ជាសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រទេស។ ប៉ុន្តែអ្វីដែលយើងខ្ញុំមានការចាប់អារម្មណ៍នោះគឺ ប្រទេសកម្ពុជានាពេលបច្ចុប្បន្នកំពុងតែមានការអភិវឌ្ឍន៍ស្ទើរគ្រប់វិស័យ ដោយក្នុងនោះវិស័យអប់រំជាវិស័យមួយដែលកំពុងតែត្រូវបានរាជរដ្ឋាភិបាលខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំង។ ទន្ទឹមនឹងនោះចំពោះការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅក្នុងសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច យើងខ្ញុំសង្កេតឃើញថាមានមុខវិជ្ជា សំខាន់ៗជាច្រើនដែលសុទ្ធតែគួរជាទីចាប់ អារម្មណ៍ក្នុងការសិក្សា ។ ក្នុងចំណោមមុខវិជ្ជាទាំងនោះ យើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៃនីតិវិធីព្រហ្មទណ្ឌដែលជាមុខវិជ្ជាមួយស្ថិតក្នុងនីតិឯកជន ។ ចំពោះមុខវិជ្ជានេះ ជាមុខវិជ្ជាដែលមានទំនាក់ទំនង ជាច្រើនក្នុងសកម្មភាពរបស់បុគ្គលឯកជនក្នុងជីវភាពប្រចាំថ្ងៃ ។ ដោយឡែកក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានចែងអំពីមាត្រាជាច្រើន ដែលទាក់ទងទៅនឹងការដាក់ទោស នឹងការរឹបអូសក្នុងបទល្មើសដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ជាបញ្ហាមួយគួរអោយចាប់អារម្មណ៍ និងស្មុគស្មាញក្នុងការដោះស្រាយ ពិសេសការចាត់ចែងថែរក្សា និងការចរាចរណ៍នៃគ្រឿងញៀនដែលមានក្នុងសកលលោកយើងនេះរួមនឹងក្នុងប្រទេស កម្ពុជាយើងនាសម័យបច្ចុប្បន្ននេះផងដែរ ។ ផ្តើមចេញពីចំណុចដែលបានរៀបរាប់ខាងលើ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើស យកប្រធានបទ ដែលមានចំណងជើងថា ការអនុវត្តន៍ច្បាប់គ្រឿងញៀនក្នុងប្រទេសកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអតីតកាលពីបុរមក ។

តាមរយៈការស្រាវជ្រាវ ចងក្រងសារណាមួយក្បាលនេះ យើងខ្ញុំសង្ឃឹមនឹងជឿជាក់ថានឹងក្លាយជាឯកសារពិគ្រោះមួយ សម្រាប់ជំនួយដល់ការសិក្សាចំពោះអ្នកដែលមានបំណងចង់ស្វែងយល់អំពីមូលដ្ឋាន នៃរឿងដែលមានការពាក់ពន្ធនឹងគ្រឿងញៀន ក៏ដូចជាការចង់យល់ដឹងបន្ថែមអំពីការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ហើយក្នុងគោលបំណងជួយផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យកាន់តែទូលំ ទូលា យថែមមួយកម្រិតទៀត។ ជាមួយគ្នានេះ

ដែរ យើងខ្ញុំក៏សូមអភ័យទោសរាល់កំហុសឆ្គងដែលអាចកើតមានដោយអចេតនា ចំពោះពាក្យពេចន៍ ឬ ខ្លឹមសារ ដែលខុសឆ្គងនានា ហើយយើងខ្ញុំសូមស្វាគមន៍រាល់ការរិះគន់ក្នុងន័យស្ថាបនា និងគំនិតយោបល់នានាដើម្បីអោយសារណានេះកាន់តែល្អប្រសើរថែមទៀត ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១**

**ចំណេះដឹងមូលដ្ឋានអំពីគ្រឿងញៀន**

**ផ្នែកទី ១ ប្រវត្តិកំណើតនៃគ្រឿងញៀន**
**និងប្រភេទគ្រឿងញៀននៅកម្ពុជា** ........................................ ៤

កថាខណ្ឌទី ១ ប្រវត្តិកំណើតនៃគ្រឿងញៀន ........................................ ៤

ក- ការកកើតនៃគ្រឿងញៀន ........................................ ៥

ខ- និយមន័យគ្រឿងញៀន ........................................ ៥

កថាខណ្ឌទី ២ ប្រភេទគ្រឿងញៀននៅកម្ពុជា ........................................ ៥

ក- គ្រឿងញៀនធម្មជាតិ ........................................ ៦

១- ដើមកញ្ឆា ........................................ ៦

២- ដើមកូកា ........................................ ៧

៣- ដើមអាភៀន ........................................ ៨

ខ- គ្រឿងញៀនសំយោគ ........................................ ៨

១- ម៉រហ្វីន ........................................ ៩

២- ហេរ៉ូអ៊ីន ........................................ ៩

៣- អ៊ិចស្តាស៊ី ........................................ ១១

៤- ការហិត ........................................ ១១

**ផ្នែកទី២ ប្រភព និងការកកើតច្បាប់**
**ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ........................................ ១៣

កថាខណ្ឌទី ១ ប្រភពនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ........................................ ១៣

ក.ប្រភពនៃច្បាប់ ........................................ ១៣

១- ច្បាប់ជាតិ ........................................ ១៣

២- ច្បាប់អន្តរជាតិ ........................................................................ ១៣
ខ. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ........................................................ ១៤
កថាខណ្ឌទី ២ ស្ថាប័នអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ............................ ១៤
ក. រចនាសម្ព័ន្ធ អ.ជ.ប.គ.ញ ..................................................................... ១៤
ខ. ការបែងចែកច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន.............................................. ១៧

## ជំពូកទី២

## ការគ្រប់គ្រងលើស្ថានការណ៍គ្រឿងញៀន

**ផ្នែកទី១ សភាពការណ៍ទូទៅ នឹងការត្រួតពិនិត្យ**.................................................. ២៤
កថាខណ្ឌទី១ ស្ថានការណ៍គ្រឿងញៀនអន្តរជាតិ....................................................... ២៤
ក. អំពីក្រុមឧក្រិដ្ឋកម្មគ្រឿងញៀន........................................................................ ២៤
ខ. អំពីមធ្យោបាយនាំចេញ-នាំចូល ....................................................................... ២៧
កថាខណ្ឌទី ២ ស្ថានការណ៍គ្រឿងញៀនកម្ពុជា ........................................................ ២៨
ក. ទីតាំងភូមិសាស្ត្រ......................................................................................... ២៨
ខ. ការចរាចរគ្រឿងញៀន................................................................................... ២៩
គ. ការប្រើបំពានគ្រឿងញៀន .............................................................................. ៣០
**ផ្នែកទី២ គោលដៅនិងការត្រួតពិនិត្យ** ........................................................................ ៣១
កថាខណ្ឌទី១ សកម្មភាពក្នុងការត្រួតពិនិត្យ .............................................................. ៣១
ក. ដែនគោក ..................................................................................................... ៣១
១. តំបន់ប្រជុំជន............................................................................................... ៣២
២. តំបន់ជាប់ព្រំដែន .......................................................................................... ៣២
ខ. ដែនទឹក....................................................................................................... ៣៤
គ. ដែនអាកាស .................................................................................................. ៣៥
កថាខណ្ឌទី២ មធ្យោបាយក្នុងការត្រួតពិនិត្យ............................................................. ៣៦
ក. តាមពត៌មានជាក់លាក់..................................................................................... ៣៨
ខ. តាមឧបករណ៍ទំនើប ...................................................................................... ៣៩

## ជំពូកទី៣

## នីតិវិធី និងវិធានការទាក់ទងបទល្មើសគ្រឿងញៀន

**ផ្នែកទី១ បទល្មើស និងទោសបញ្ញត្តិ** .............................. ៤០

កថាខណ្ឌទី ១ បទល្មើសនឹងទោសបញ្ញត្តិ .............................. ៤០

ក- តារាងសង្ខេបបទល្មើសនិងទោសពិន័យ .............................. ៤០

ខ- សមត្ថកិចដែលអនុវត្តនីតិវិធី .............................. ៤៨

កថាខណ្ឌទី ២ ការព្យាបាល និងស្តានីតិសម្បទា .............................. ៤៨

ក- នីតិវិធីក្នុងការព្យាបាល និងស្តានីតិសម្បទា .............................. ៤៩

ខ- ភ្នាក់ងារក្នុងការព្យាបាល និងស្តានីតិសម្បទា .............................. ៥៩

**ផ្នែកទី២ វិធានការនឹងដំណោះស្រាយក្នុងការ**

**អនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា** .............................. ៥១

**កថាខណ្ឌទី១ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល** .............................. ៥១

ក. វិធានការណ៍ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន.............................. ៥១

ខ. វិធានការក្នុងការទប់ស្កាត់គ្រឿងញៀន.............................. ៥១

កថាខណ្ឌទី ២ ដំណោះស្រាយបញ្ហាគ្រឿងញៀននៅកម្ពុជា .............................. ៥៤

ក. ការបង្ក្រាបបទល្មើស .............................. ៥៣

ខ. ដំណោះស្រាយ.............................. ៥៣

**សេចក្តីសន្និដ្ឋាន** .............................. ៥៤

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

គ្រឿងញៀនគឺជារុក្ខជាតិ ឬសារធាតុចម្រាញ់ចេញពីរុក្ខជាតិ ឬសារធាតុគីមីដែលធ្វើឱ្យមានការផ្លាស់ប្តូរនូវមុខងារផ្សេងៗរបស់សារពាង្គកាយមនុស្ស ឬសត្វ ហើយជាពិសេសវាធ្វើឱ្យមានការប្រែប្រួលប្រព័ន្ធសរសៃប្រសាទ និងខួរក្បាលនៅពេលប្រើវា។ គ្រឿងញៀនមានពីរប្រភេទគឺ គ្រឿងញៀនធម្មជាតិ និងគ្រឿងញៀនសំយោគ។[1] ហើយគ្រឿងញៀនក៏បានរីករាលដាលក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដែលជាផលពិបាក និងស្មុគស្មាញដល់រដ្ឋាភិបាលនៃប្រទេសកម្ពុជាដើម្បីទប់ស្កាត់។

បច្ចុប្បន្ននេះនៅក្នុងសង្គមខ្មែរ ក៏ដូចជាសង្គមនៃប្រជាជាតិដទៃទៀតនៅលើពិភពលោកទាំងមូល បាននិងកំពុងតែទទួលរងនូវឥទ្ធិពលនៃគ្រឿងញៀនដូចជាថ្នាំគ្រាប់ ថ្នាំចាក់ ម៉ាទឹកកក។ គ្រឿងញៀននេះហើយដែលបានធ្វើឲ្យសង្គមជាតិ និងប្រជាជនខ្លួនឯងរងនូវផលប៉ះពាល់មានទាំងសេដ្ឋកិច្ចគ្រួសារ និងសង្គម ព្រមទាំងប៉ះពាល់ដល់សុខភាពខ្លួន និងបង្កឲ្យមានភាពស្មុគស្មាញយ៉ាងច្រើនដល់ប្រទេសជាតិទាំងមូល។

អំពើចោរកម្ម ការបាត់បង់ស្មារតីមិនស្គាល់ញាតិខ្លួន ភាពក្រីក្រលំបាក អំពើហឹង្សា បញ្ហាសុខភាព។ល។ គឺសុទ្ធសឹងតែផ្នែកមួយកើតចេញពីការសេពនូវគ្រឿងញៀនទាំងនេះ។ ការសេពគ្រឿងញៀន គឺកើតឡើងពីការចង់ដឹងចង់សាកនៃមនុស្ស ការអូសទាញពីមិត្តភ័ក្ត និងផ្សព្វផ្សាយពីអ្នករកស៊ីជាដើម។ កត្តាទាំងប៉ុន្មាននេះដែលជំរុញឲ្យមនុស្សមានអារម្មណ៍ចង់សេពគ្រឿងញៀន ។ ការសេពគ្រឿងញៀនធ្វើឲ្យបុគ្គលបាត់បង់ស្មារតីក្នុងការគ្រប់គ្រងខ្លួនឯង ហើយធ្វើឲ្យខ្លួនហ៊ានប្រព្រឹត្តនូវអំពើអសីលធម៌ផ្សេងៗ ទៅលើបុគ្គលដទៃទៀតដែលបានបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតសណ្តាប់ធ្នាប់សង្គមព្រមទាំងធ្វើឲ្យខូចនូវទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិថែមទៀត។

ធនធានមនុស្សជាកត្តាយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានភាពរីកចម្រើន និងសុខសន្តិភាពល្អបរិបូរ តែប្រសិនបើធនធានមនុស្សរបស់ខ្លួនធ្លាក់ចូលក្នុងការប្រើប្រាស់គ្រឿងញៀន និងអំពើអបាយមុខទាំងអស់នោះហើយ ដែលបាត់បង់នូវធនធានមនុស្សក្នុងការអភិវឌ្ឍន៍ជាតិដែលថយចុះមិនអាចរីកចម្រើនទៅមុខបានឡើយ។ ដូច្នេះដើម្បីធ្វើឲ្យសង្គមខ្មែរក៏ដូចជាយុវជននាសម័យទំនើបនេះជៀសឆ្ងាយផុតពីគ្រឿងញៀន រាជរដ្ឋាភិបាល អាជ្ញាធរពាក់ព័ន្ធ និងស្ថាប័នដែលជាដៃគូរ និងប្រជាជនខ្លួន ត្រូវនាំគ្នាចូលរួមផ្សព្វផ្សាយ និងពន្យល់ពីផលប៉ះពាល់ដែលបណ្តាលមកពីគ្រឿងញៀនទៅដល់ក្រុមគ្រួសារ មិត្តភ័ក្តខ្លួនឲ្យបានដឹងយល់ច្បាស់គ្រប់ៗគ្នា និងស្វែងរកដំណោះស្រាយ

[1] ប្រភេទនៃគ្រឿងញៀន

ល្អៗដើម្បីធ្វើឲ្យពួកគេយល់ហើយជៀសផុតពីការសេពគប់ ក៏ដូចជាប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ និងគ្រប់រូបភាព។

យើងក្រឡេកមើលបច្ចុប្បន្នភាព ឥទ្ធិពលរបស់គ្រឿងញៀនពិតជាមានលក្ខណៈស្មុគស្មាញ និងពុំមានភាពងាយស្រួលនៅក្នុងការដោះស្រាយឡើយ។ កិច្ចការនេះប្រាកដណាស់ គឺវាតម្រូវឲ្យមានការចូលរួម សហការពីភាគីដែលពាក់ព័ន្ធធ្វើការចូលរួមគ្នា ហើយស្វែងរកនូវជម្រើសល្អ ឬគន្លឹះឆ្ពោះទៅលុបបំបាត់វា ។ គ្រឿងញៀនបានក្លាយជាបញ្ហាចោទមួយសំរាប់សង្គមខ្មែរ និងពិភពលោកធ្វើការដោះស្រាយជុំវិញបញ្ហានេះ ។ មកដល់ពេលនេះមានមតិព្រមទាំងសំណួរមួយចំនួនដែលបានលើកឡើងយ៉ាងដូចច្នេះថា៖

- តើគ្រឿងញៀនមានអត្ថន័យដូចម្តេច? ហើយប្រភេទនៃគ្រឿងញៀន និងអត្រានៃចំនួនអ្នកប្រើប្រាស់មានយ៉ាងដូចម្តេច?
- តើគ្រឿងញៀនមានប្រភពចេញពីណា? ហើយមូលហេតុអ្វីខ្លះ ដែលនាំឲ្យមានផលប៉ះពាល់ដែលបណ្តាលមកពីគ្រឿងញៀន?
- ចំពោះដំណោះស្រាយ តើរដ្ឋមានវិធានការបែបណាខ្លះ? រីឯច្បាប់បានប្បញ្ញត្តិដូចម្តេចចំពោះអ្នកប្រើប្រាស់ និងអ្នកជួញដូរ?
- ជាចុងក្រោយតើរដ្ឋាភិបាលត្រូវធ្វើដូចម្តេចក្នុងការលុបបំបាត់គ្រឿងញៀន?

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងប៉ុន្មានដែលបានចោទសួរឡើងនេះ យើងខ្ញុំសូមធ្វើការសិក្សា និងបកស្រាយនូវលើចំណោទបញ្ហានេះជា បីជំពូក។ ដោយ**ជំពូកទី១** យើងនឹងសិក្សាលើចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន ព្រមទាំងបង្ហាញពីការគ្រប់គ្រងលើស្ថានការណ៍គ្រឿងញៀន **ជំពូកទី២** និង**ជំពូកទី៣** ដែលសិក្សានីតិវិធី និងវិធានការទាក់ទងបទល្មើសគ្រឿងញៀនដែលជាជំពូកចុងក្រោយសំរាប់ការធ្វើការសិក្សា និងបកស្រាយ។

ដូចដែលបានដឹងហើយថា **ឥទ្ធិពលនៃគ្រឿងញៀន** កំពុងតែបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិរបស់យើង ក៏ដូចជាក្នុងពិភពលោកទោះជាក្នុងរូបភាពបែបណាក៏ដោយ ។ ហើយវាបានបង្កឲ្យមានការបាត់បង់ទ្រព្យសម្បត្តិ ពេលវេលា សីលធម៌សង្គម ហើយឈានទៅដល់ការបាត់បង់អាយុជីវិតថែមទៀតផង ។ ប៉ុន្តែទោះបីជាសង្គមរបស់យើងកំពុងស្ថិតក្នុងស្ថានភាពដូចពេលបច្ចុប្បន្នដែលសំបូរទៅដោយការប្រើប្រាស់សារធាតុញៀន ពីគ្រប់ស្រទាប់វណ្ណៈ ជាពិសេសវណ្ណៈយុវវ័យ ដែលជាវណ្ណៈក្មេងឈាមរាវ ភ្លើតភ្លើនចង់ដឹង ចង់ស្គាល់អ្វីដែលថ្មីក្នុងជីវិត មិនដឹងពីផលប៉ះពាល់ និងជាវ័យដែលងាយនឹងអូសទាញពីបុគ្គលទៅបុគ្គល ។ ទោះជាយ៉ាងនេះក្តីយើងក៏អាចកាត់បន្ថយបាននូវគ្រោះថ្នាក់ និងការបាត់បង់ផ្សេងៗ ជាពិសេសធនធានមនុស្សដែលជាទំពាំងស្នង

ឬស្សី ។ ការកាត់បន្ថយនេះធ្វើទៅបានតាមរយៈការចូលរួមពីសំណាក់ រាជរដ្ឋាភិបាលក្នុងការពង្រឹងច្បាប់ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវផលវិបាក និងភាពអវិជ្ជមាននៃសារធាតុញៀន។

ការសិក្សាពី **ការអនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា** នេះមិនត្រឹមតែយល់ដឹងពីច្បាប់ និងប្បញ្ញត្តិប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវចំណេះដឹងជាច្រើន ដែលមិនធ្លាប់ដឹងពីមុនដោយឆ្លងកាត់ការស្រាវជ្រាវកន្លងមក ។ អ្វីដែលទទួលបានជាពិសេសនោះគឺការយល់ដឹងពីផលប៉ះពាល់ដល់គ្រឿងញៀន និង រុក្ខជាតិដែលមានសារធាតុញៀន ។ ក្នុងនេះដែលយើងក៏បានសិក្សាអំពីប្រភេទនៃគ្រឿងញៀន និងវិធីសាស្ត្រក្នុងការផលិតផងដែរ ។ ក្នុងការសិក្សានេះយើងក៏បានស្វែងរកនូវយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ ក៏ដូចជានីតិវិធីបង្កាមិនឲ្យមានបណ្តាប្រទេសជិតខាងនាំចូលចែកចាយយ៉ាងអនាធិបតេយ្យ ដែលមិនបានទុកសំណាញ់ច្បាប់ដែលជាវត្តក្នុងការរារាំងនោះឡើយ។

ដែលជាហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានជ្រើសយកប្រធានបទមួយនេះឡើងមកសិក្សាបកស្រាយ ក្នុងការចែកចាយសិស្សនិស្សិតជំនាន់ក្រោយបានអាន និងវាយតម្លៃលើផលប៉ះពាល់ ក៏ដូចជាសង្គមមានការព្រួយបារម្ភពីនៃលំហូរចូលសារធាតុញៀនមកក្នុងប្រទេស ។

# ជំពូកទី ១
# ចំណេះដឹងមូលដ្ឋានអំពីគ្រឿងញៀន

គ្រឿងញៀនបានប្រែក្លាយជាបញ្ហាសកល ហើយកំពុងគំរាមកំហែង និងបង្កនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាព និងសេដ្ឋកិច្ចរបស់បុគ្គល គ្រួសារ សហគមន៍ព្រមទាំងសន្តិសុខ សណ្តាប់ធ្នាប់ និងការអភិវឌ្ឍន៍សង្គមជាតិនៃបណ្តាប្រទេសនានានៅក្នុងសកលលោក ។ នៅក្នុងទសវត្សចុងក្រោយនេះព្រះរាជាណាចក្រកម្ពុជា បានប្រឈមកាត់តែខ្លាំងឡើងៗទៅនឹងបញ្ហានេះ ហើយយុទ្ធសាស្ត្រ និងវិធានការជាច្រើនដែលមាន និងបានប្រមូលផ្តុំដើម្បីដោះស្រាយបញ្ហាដ៏គ្រោះថ្នាក់នេះគឺសំដៅធានាអោយបាននូវការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងការលើកកម្ពស់សុខុមាលភាពជូនប្រជាជន សហគមន៍ និងសង្គមជាតិទាំងមូល ។[2]

## ផ្នែកទី១ ប្រវត្តិកំណើតនៃគ្រឿងញៀននឹងប្រភេទគ្រឿងញៀននៅកម្ពុជា

នៅត្រង់ចំណុចនៃប្រវត្តិនឹងប្រភេទនេះគឺចង់បង្ហាញថា តើគ្រឿងញៀនជាអ្វីទៅ? មានកំណើតក្នុងការកកើតមកពីពេលណា? មានប្រភេទយ៉ាងណាដូចម្តេចខ្លះ? ដែលមានផលប៉ះពាល់ដល់ជនទូទៅយ៉ាងនេះ។ ហើយផលប៉ះពាល់នោះមានឥទ្ធិពលយ៉ាងណា?

### កថាខណ្ឌទី ១ ប្រវត្តិកំណើតនៃគ្រឿងញៀន

មានការអះអាងជាច្រើនដែលនិយាយអំពីគ្រឿងញៀន ហើយក៏មានហេតុផលខុសៗគ្នាតាមនោះផងដែរទៅតាមតំបន់នីមួយៗ ប៉ុន្តែសុទ្ធតែមិនមានភាពជាក់លាក់នោះទេព្រោះទាំងនោះគ្រាន់តែជាពាក្យដែលចាំតៗគ្នាមកពីមុនប៉ុណ្ណោះ។[៣] ខាងក្រោមនេះគឺជាមូលហេតុដែលអ្នកវិទ្យាសាស្ត្រ និងបុរាណវិទូ បានសិក្សាស្វែងរកនូវដើមហេតុពិតមកបង្ហាញអោយជនទូទៅបានដឹងច្បាស់លាស់អំពីបញ្ហានេះ ៖

### ក. ការកកើតនៃគ្រឿងញៀន

គ្រឿងញៀនត្រូវបានអ្នកវិទ្យាសាស្ត្ររកឃើញថា ត្រូវបានគេប្រើប្រាស់តាំងពីយូយារណាស់មកហើយគឺតាំងតែពីសម័យ ព្រះចៅផារ៉ាអ៊ុង នៃប្រទេសអេស៊ីប និងអធិរាជនៃប្រទេសក្រិច មកម្ល៉េះ ព្រោះកាលសម័យនោះការកសាងប្រាសាទធំៗ រួមនឹងពីរ៉ាមីត ឬ សាជីជ្រុង ត្រូវបានគេចាត់ទុកថាជារឿងអស្ចារ្យ នឹងជាការបង្ហាញពីអនុភាពរបស់ព្រះចៅអធិរាជ ដោយប្រាសាទពីរ៉ាមីតមួយៗមាន

[២] ឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ស្តីពីគ្រឿងញៀន

[៣] ឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ស្តីពីគ្រឿងញៀន

ទំហំធំអស្ចារ្យកសាងឡើងដោយថ្មធំៗមានក្បូរក្បាច់រចនាលំអរនៅខាងក្នុង តែអ្នកប្រវត្តិវិទូបានរកឃើញថាក្នុងការកសាងនេះបានប្រើប្រាស់នូវកំលាំងមនុស្សសុទ្ធសាធ ដែលជាហេតុត្រូវបានពួកវិស្វករដែលកសាងនូវសំណង់នោះត្រូវតែរកវិធីក្នុងការសាងសង់អោយបានឆាប់រហ័ស ដើម្បីពួកគេបានគេចផុតពីការដាក់ទោស និងទទួលបានការសរសើពីថ្នាក់លើ ពួកគេបានរកឃើញនូវសារធាតុមួយប្រភេទដែលដែលធ្វើអោយទាសករទាំងនោះធ្វើការឥតឈប់ឈរ ដែលសារធាតុនោះគឺជាថ្នាំកម្លាំងចេញពីដើមអាភៀននឹងដើមកូកា ដែលអ្នកវិទ្យាសាស្ត្រនឹងប្រវត្តិវិទូបានប៉ាន់ប្រមាណថាមានអាយុកាលប្រហែល ៥០០០ឆ្នាំមុន គ.ស ម្លេះហើយ ៥០០០ឆ្នាំក្រោយមកទើបប្រាសាទអង្គរវត្តបានចាប់បដិសន្ធិលេចចេញជារូបរាងឡើងមក។[4] ចាប់តាំងពីពេលនោះមកដោយហេតុតែមានការវិវត្តជឿនលឿនផ្នែកវិជ្ជាសាស្ត្រ នឹងប្រឌិតសាស្ត្រមនុស្សបានវិវត្តគ្រឿងញៀនកាន់តែមានផលប៉ះពាល់ខ្លាំងទៅៗ ដែលមានច្រើនប្រភេទដូចបច្ចុប្បន្ននេះតែម្តង។

### ខ. និយមន័យគ្រឿងញៀន

គ្រឿងញៀនគឺជារុក្ខជាតិ ឬសារធាតុម៉្យាងដែលចម្រាញ់ចេញពីរុក្ខជាតិ ឬសារធាតុគីមីដែលធ្វើឱ្យមានការផ្លាស់ប្តូរនូវមុខងារផ្សេងៗរបស់សារពាង្គកាយមនុស្ស ឬសត្វ ហើយជាពិសេសវាធ្វើឱ្យមានការប្រែប្រួលប្រព័ន្ធសរសៃប្រសាទ និងខួរក្បាលនៅពេលប្រើវា ។ ហើយជាសារធាតុដែលធ្វើអោយអ្នកប្រើផ្លាស់ប្តូរចិត្តអារម្មណ៍ និងអាកប្បកិរិយា (ធ្វើអោយប៉ះពាល់ដល់ ផ្លូវកាយ ផ្លូវចិត្តនិងសង្គម) គ្រឿងញៀនក៏អាចធ្វើអោយអ្នកប្រើប្រាស់ប្រឈមទៅនឹងការជួបគ្រោះថ្នាក់ធ្ងន់ធ្ងរហួតទៅដល់មានការបាត់បង់ជីវិតផងដែរ ។[5] ដោយតាមការសិក្សាពីអ្នកជំនាញគេបានចែកគ្រឿងញៀនជាពីរប្រភេទ ដែលមួយប្រភេទអាចនិយាយបានថាមានឥទ្ធិពលខ្សោយនឹងមួយប្រភេទទៀតនោះមានឥទ្ធិពលខ្លាំង ដែលទាក់ទងទៅនឹងប្រព័ន្ធប្រសាទ ។[6]

### កថាខណ្ឌទី ២ ប្រភេទគ្រឿងញៀននៅកម្ពុជា

ប្រភេទគ្រឿងញៀនខ្លះៗត្រូវបានគេស្គាល់ជាបន្តបន្ទាប់ ហើយត្រូវបានគេយកវាមកប្រើប្រាស់ទាំងក្នុងនឹងក្រោយសង្គ្រាមលោកលើកទី២ ។ ប្រសិនបើនិយាយពីគ្រឿងញៀនគេត្រូវធ្វើការបែងចែកវាជាពីរប្រភេទសំខាន់បំផុតនោះគឺ៖

-គ្រឿងញៀនធម្មជាតិ និង

-គ្រឿងញៀនសំយោគ ។

[4] សៀវភៅប្រទេស អេស៊ីបបុរាណ ទំព័រទី៥

[5] ចំណេះដឹងជាមូលដ្ឋានអំពីគ្រោះថ្នាក់បណ្តាលមកពីគ្រឿងញៀន

[6] ចំណេះដឹងជាមូលដ្ឋានអំពីគ្រោះថ្នាក់បណ្តាលមកពីគ្រឿងញៀន

ខាងក្រោមនេះនឹងពន្យល់ពីប្រភេទថ្នាំញៀនខុសច្បាប់ខុសៗគ្នា ទាំងឥទ្ធិពល ទាំងរយៈពេល រួមនឹងគ្រោះថ្នាក់ដែលទាក់ទងនឹងការប្រើប្រាស់ផងដែរ។[7]

**ក. គ្រឿងញៀនធម្មជាតិ**

គ្រឿងញៀនធម្មជាតិ គឺចង់សំដៅទៅលើប្រភេទគ្រឿងញៀនដែលកើតចេញពីរុក្ខជាតិផ្ទាល់តែម្តង ហើយមិនទាន់ត្រូវបានគេយកវាទៅកែច្នៃនោះទេ ។ គ្រឿងញៀនធម្មជាតិដែលមានពីមុនមកនៅកម្ពុជាយើងហើយត្រូវបានគេប្រើប្រាស់មានដូចជា ៖

**១. ដើមកញ្ឆា**

ដើមកញ្ឆាគឺជារុក្ខជាតិ ដែលមានគេដាំវាតាំងពីយូរយារណាស់មកហើយ នៅតាមទីដីប្លែកៗគ្នានៃប្រទេសជាច្រើនស្ទើរពាសពេញពិភពលោក និងស្ទើរគ្រប់អាកាសធាតុនៃភូមិសាស្ត្រដោយវាអាស្រ័យជារុក្ខជាតិមិនរើសដីសំរាប់ដាំដុះ ។ ហើយនៅក្នុងផ្នែកវិទ្យាសាស្ត្រកញ្ឆាត្រូវបានគេដាក់ឈ្មោះថា កាណាប៉េស សាទីវ៉ា ( Canabis Sativa) ។[៨] ការប្រើប្រាស់កញ្ឆា ឬ កាណាប៉េស សាទីវ៉ានេះត្រូវបានគេប្រើវាតាំងតែពីស្លឹក ដើម នឹងជ័រ របស់កញ្ឆា។

ឥទ្ធិពលដែលប្រទះឃើញបន្ទាប់ពីបានប្រើប្រាស់នូវកញ្ឆាមកវានឹងធ្វើអោយមនុស្សមាន៖

- អារម្មណជ្រះស្រឡះ មិនខ្វល់អ្វីនៅក្បែខ្លួន
- ស្ថានភាពរីករាយ ធូរស្រាលក្នុងខ្លួន(រវើរវាយ)
- ធ្វើអោយវិញ្ញាណទាំងអស់ ចក្ខុវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ និងសោត្តវិញ្ញាណមានសកម្មភាពខុសពីប្រក្រតី
- ជីពចរមានការកើនឡើង ភ្នែកឡើងក្រហម ឆាប់ខឹង
- នៅដំណាក់កាលចុងក្រោយអ្នកប្រើកញ្ឆា នឹងទៅជាបុគ្គលដែលមានសភាពស្ងៀមស្ងាត់សញ្ចប់សញ្ចឹងតែម្នាក់ឯង
- ពេលអត់ជាតិថ្នាំអ្នកប្រើប្រាស់នឹងមានសភាពងងុយដេក ដូចមនុស្សបាក់កំលាំង គ្មានស្មារតី ។

តំបន់ធំបំផុតនៃចំការកញ្ឆាគឺស្ថិតនៅក្នុងប្រទេសមួយចំនួនដូចជា អតីតសហភាពសូវៀត កាហ្សាក់ស្ថាន អាហ្គានីស្ថាន ប៉ាគីស្ថាន អាស៊ីកណ្តាល អាស៊ីអាគ្នេយ៍ នឹងប្រទេសបន្ទាប់បន្សំរួមមាន ប្រទេសកូឡុំប៊ី ម៉ូរ៉ូកូ នីហ្សេរីយ៉ា អាហ្វ្រិខាងត្បូង ចាមេកា រួមនឹងកម្ពុជា ឡាវ ថៃ ។ ហើយតំបន់

[៧] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

[៨] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

ដែលមានការប្រើប្រាស់កញ្ឆាច្រើនលើសលប់បំផុតទូទាំងពិភពលោក គឺមាន ប្រទេស អូសេអានី អាមេរិកកណ្តាល អាមេរិកខាងជើង អ៊ឺរ៉ុបខាងលិច ជាពិសេសគឺនៅទ្វីបអាហ្វ្រិក។[៩] ចំនែកក្នុងប្រទេសកម្ពុជាយើងវិញក៏មានការដាំដុះនូវដើមកញ្ឆានេះផងដែរ ដោយការដាំដុះនោះស្ថិតនៅតាមព្រំដែនដែលនៅជាប់នឹងប្រទេសឡាវតែម្តងដែលមានខេត្ត ព្រះវិហា ស្ទឹងត្រែង នឹងរតនគីរី ។

## ២. ដើមកូកា

ដើមកូកាក៏ជារុក្ខជាតិមួយប្រភេទដែលជាគ្រឿងញៀនផងដែរ វាត្រូវបានគេរកឃើញនឹងដាំដុះតាំងតែពីយូរលង់ណាស់មកហើយ ។ រុក្ខជាតិនេះមានរាងពងក្រពើមានខ្សែពីរស្របគ្នានឹងទ្រនង់កណ្តាលដែលនៅផ្នែកខាងក្រោមនៃស្លឹក ។ កូកាត្រូវបានគេដាំដុះនៅក្នុងអាកាសធាតុត្រូពិចដែលមានរយៈកម្ពស់ ៥០០ម៉ែត្រពីនីវូទឹកសមុទ្រ ។ ការប្រើប្រាស់កូកាត្រូវបានគេយកតែ ស្លឹក នឹងជ័ររបស់វាមកប្រើតែប៉ុណ្ណោះ ដោយមែកនឹងដើមវាពុំមានសារៈសំខាន់នោះទេ។

ឥទ្ធិពលដែលកើតឡើងក្រោយការប្រើប្រាស់៖

- កាត់បន្ថយភាពឃ្លាន និង ការហត់អស់កម្លាំង
- មានអាការៈដកដង្ហើមញាប់ខុសធម្មតា , បេះដូងដើរលឿន, សម្ពាធឈាមខ្ពស់
- បើប្រើច្រើនលើសកម្រិតនឹងធ្វើអោយមានអារម្មណ៍រវើរវាយរសាប់រសល់នៅមិនសុខរហូតដល់ភាពអស់ជាតិញៀន
- បើប្រើប្រាស់លើសរហូតរាង្គកាយទទួលមិនបាន នោះនឹងមានគ្រោះថ្នាក់ដល់ជីវិត ។

តំបន់ដែលដាំដើមកូកាសំខាន់ៗមាននៅ អាមេរិកខាត្បូង ប៉េរូ កូឡុំប៊ី នឹងនៅតាមមួយចំនួននៃតំបន់អេក្វាទ័រ ប៉ុន្តែប្រទេសដែលមានការដាំដុះនូវរុក្ខជាតិកូកានេះច្រើនជាងគេលើពិភពលោកនោះគឺ ប្រទេសកូឡុំប៊ី បូលីវី រួមនឹងប៉េរូដែលគិតជាភាគរយគឺ ៧០ភាគរយនៃដំណាំសរុប ។ ចំនែកឯនៅក្នុងប្រទេសកម្ពុជាយើងនេះវិញនៅក្នុងចន្លោះឆ្នាំ ១៩៩១ ទៅ ២០០០ គេបានរកឃើញនូវរុក្ខជាតិកូកានេះនៅតាមតំបន់មាត់សមុទ្រនឹងតាមកោះខ្លះៗ ប៉ុន្តែត្រូវបានអាជ្ញាធរធ្វើការបង្ក្រាបទាន់ពេលវេលាមិនអោយមានការរីករាលដាលកាន់តែខ្លាំង។[១០]

---

[៩] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

[១០] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

### ៣. ដើមអាភៀន

អាភៀនគឺជាដំណាំមួយប្រភេទ ដើមតូចៗកម្ពស់ប្រហែលនឹងដើមថ្នាំជក់ (ខ្មែរបុរាណហៅថ្នាំខ្លាំងសម្រាប់យកមកមូលជាបារីសម្រាប់ជក់) ដែលមានកម្ពស់ពេលពេញវ័យចន្លោះប្រហែល ១,៤០ ទៅ ១,៥០ម៉ែត្រ។ អាភៀនគេមិនយកដើមវានោះទេតែគេយកផ្លែដែលមានជ័ររបស់វា គេយកជ័រនោះមកកូរឲ្យខាប់សម្រាប់ប្រើការជក់បឺតលេបផ្សេង (នាំឲ្យញៀនជាប់) ឬប្រើការផ្សំថ្នាំកែរោគជាដើម។ គេចាប់ផ្តើមដាំអាភៀន ដោយការបណ្តុះកូនរបស់វានៅក្នុងថ្នាល។[១១] បន្ទាប់ពីនោះមកទើបគេចាត់ចែងវាយកទៅដាំនៅលើដី ។

ឥទ្ធិពលដែលកើតឡើងក្រោយការប្រើប្រាស់៖

- មានភាពស្ងៀមស្ងាត់មិនធ្វើចលនា
- មានអារម្មណ៍រវើរវាយ ធ្វើអោយមនុស្សទៅជាសប្បាយៗ
- សញ្ជឹងភ្លឹក មើលអ្វីមិនដាក់ភ្នែក
- ងាយស្រមើលស្រមៃប្រងើយកន្តើយ
- មិនខ្វល់នៅវត្ថុ ឬ អំពើអ្វីទាំងអស់ដែលនៅជុំវិញខ្លួន។

ការប្រើប្រាស់អាភៀន ទោះក្នុងរូបភាព ចាក់ ជក់ ហឺត ឬ លេបក្តី ប៉ុន្មានដងដំបូងវាមិនទាន់ធ្វើអោយអ្នកប្រើមានអារម្មណ៍សប្បាយកាយនឹងចិត្តទេ វាបណ្តាលអោយអ្នកប្រើប្រាស់ វិលមុខ ចង់ក្អួត ឈឺក្បាលជាដើម ប៉ុន្តែបន្ទាប់មកទៀតអ្នកប្រើនិងមានអារម្មណ៍សប្បាយអណ្តែតអណ្តូង រហូតនាំអោយអ្នកប្រើមិនអាចអត់ពីវាស្ទើរតែខានមិនបាន ។

តំបន់ដែលដាំអាភៀនសំខាន់ៗមាននៅ ប្រទេសអាហ្គានីស្ថាន អ៊ីរ៉ង់ ប៉ាគីស្ថាន ឡាវ ថៃនឹងមីយ៉ាន់ម៉ា។ ប្រទេសទាំង៦នេះបានផលិតអាភៀនខុសច្បាប់នៅលើពិភពលោកដែលមានស្ទើរតែ ៩០ភាគរយនៃអាភៀនសរុបទាំងអស់ ។ ចំនែកក្នុងកម្ពុជាវិញក៏មានការដាំដុះខ្លះៗដែរប៉ុន្តែមិនមានការដាំដុះជាលក្ខិណៈទ្រង់ទ្រាយធំនោះទេ។[១២]

### ខ. គ្រឿងញៀនសំយោគ

គ្រឿងញៀនសំយោគគឺជាការ យកនូវសារធាតុគីមីជាច្រើនមុខមកផ្សំសំយោគបញ្ចូលគ្នាដោយមានការពឹងផ្អែកទៅលើបច្ចេទេសវិទ្យាសាស្ត្រក្នុងការផលិតវា ។ ការផលិតនូវគ្រឿងញៀនសំយោគត្រូវបានគេផលិតនៅក្នុងមន្ទីពិសោធន៍យ៉ាងលួចលាក់ដែលមានដាំអាភៀន ។ ហើយវា

---

[១១] ថ្នាល: ជាទីកន្លែងសំរាប់សាបព្វជមុនយកទៅដាំដុះ ដែលមាន ពោង ថ្នើរ។ល។

[១២] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

មានដូចជា ម័រហ្វីន ហេរ៉ូអ៊ីន អ៊ិចស្តាស៊ី នឹងការហិត ជាដើមដែលបានចរាចរណ៍ក្នុងប្រទេសកម្ពុជាយើង ។ ខាងក្រោមនេះជាការបកស្រាយខ្លះៗអោយយើងបានស្គាល់នូវប្រភេទថ្នាំញៀនមួយចំនួនខាងលើនេះ ៖

### ១. ម័រហ្វីន

ដោយចាប់តាំងពីសតវត្សរ៍ទី១៩ ការប្រើប្រាស់អាភៀនមានការថយចុះជាខ្លាំងជាហេតុធ្វើអោយអ្នកផលិតគ្រឿងញៀនបានយកអាភៀនទៅធ្វើការសំយោគជាច្រើនរយលើក ដោយមានការផ្សំផ្គុំជាមួយនឹងការច្នៃប្រឌិតបែបវិទ្យាសាស្ត្រថ្មី ម័រហ្វីនក៏បានកកើតឡើងតាំងពីពេលនោះមកវាគឺជាការលាយចូលគ្នាជាមួយសារធាតុគីមីជាច្រើនមុខ ដែលដំបូងឡើងគេហៅវាថាជា ម័រហ្វីនបាស់ដែលវាមានច្រើនទំរង់ ជាម្សៅមានច្រើនពណ៌ ស ក្រហម ក្រមៅ ត្នោតចាស់ជាដើម មិនតែប៉ុណ្ណោះវាក៏ត្រូវបានគេផលិតជាគ្រាប់សំរាប់លេប នឹងជាទឹកសំរាប់ចាក់ផងដែរ។

ម័រហ្វីនេះ វាមានឥទ្ធិពលប្រហាក់ប្រហែលនឹងអាភៀនដែរ តែមានគុណភាពសុទ្ធច្រើនជាងអាភៀន ព្រោះវាជាប្រភេទសំយោគដែលមានឥទ្ធិពលកើតឡើងក្រោយការប្រើប្រាស់៖

- មានភាពស្ពឹកស្រពន់រូបរាងកាយ និងស្មារតី
- គំនិតចាប់ផ្តើមមិនប្រក្រតី
- ការដកដង្ហើមចាប់ផ្តើមខ្សោយ
- បើការប្រើលើសកំរិតនឹងបណ្តាលអោយឆ្កួត
- កើតរោគលើសឈាម នឹងជំងឺរោគចិត្ត
- ឧស្សាហ៍ឈឺក្នុងពោះដោយជាតិថ្នាំគីមីផ្សំ
- អាចបណ្តាលអោយស្លាប់ភ្លាមៗបើអ្នកប្រើមានសុខភាពខ្សោយ ។

ចំនែកឯការផលិតវិញ ម័រហ្វីនត្រូវបានគេលួចផលិតស្ទើរគ្រប់ទីកន្លែងលើពិភពលោកដែលមានការគ្រប់គ្រងក្នុងតំបន់មិនសូវជាល្អ ឬ សន្តិសុខមានកំរិតទាបដែលជាហេតុបង្កអោយជនល្មើសមានឧកាសច្រើន ជាពិសេសគឺតំបន់ដែលមានការដាំអាភៀនតែម្តង។[13]

### ២. ហេរ៉ូអ៊ីន

បើនិយាយពីហេរ៉ូអ៊ីន គេអាចនិយាយបានថាអ្នកណាក៏ធ្លាប់លឺពីឈ្មោះវាដែរដោយគេសម្គាល់ក្នុងភាពយន្តភាគចិនការប្រាប់តៗគ្នានឹងការប្រើប្រាស់វាជាដើមតែម្តង ។ វាគឺជាគ្រឿងញៀនសំយោគដែលគេបានចម្រាញ់យកចេញមកពីម័រហ្វីន។ ហេរ៉ូអ៊ីនត្រូវបានគេរកឃើញនៅក្នុង

[១៣] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

កំឡុងសតវត្សរ៍ទី២០ នេះប៉ុណ្ណោះដោយការកំលាយវាចេញពីម័រហ្វីននឹងធ្វើការផ្សំនានាជាមួយនឹងសារធាតុគីមីជាច្រើនទៀតបញ្ចូលគ្នា ។ ហេរ៉ូអ៊ីននេះដែលគឺមានភាពពិសេសត្រង់វាត្រូវបានគេចម្រាញ់ចេញជា ៤ប្រភេទដែលមានលក្ខិណៈខុសគ្នាៗរវាង រូបរាង វិធីប្រើ និងគុណភាពសុទ្ធរបស់វាដែលមានដូចជា៖

- ហេរ៉ូអ៊ីនលេខ ១ វាជាប្រភេទដំបូងដែលកើតការកំលាយចេញពី ម័រហ្វីន គេបានហៅវាថាជាម័រហ្វីនៅតែកំរិតសុទ្ធរបស់វាមានតិចតួចណាស់ ។
- ហេរ៉ូអ៊ីនលេខ ២ ជាគ្រឿងញៀនដែមចម្រាញ់ចេញពី ម័រហ្វីន ដូចគ្នាតែមានរាងដូចជាអំបិលហើយមានពណ៌ត្នោតចាស់ ឯកំរិតភាពសុទ្ធរបស់វាមានត្រឹម ២០ភាគរយប៉ុណ្ណោះ។
- ហេរ៉ូអ៊ីនលេខ ៣ ជាប្រភេទដែលមានភាពម៉ត់សំរាប់ជក់ ហេរ៉ូអ៊ីនប្រភេទនេះត្រូវបានគេលាយនូវសារធាតុកាហ្វេអ៊ីនចូលទៅក្នុងនោះយ៉ាងច្រើន សំរាប់អោយអ្នកប្រើប្រាស់ញៀនខ្លាំង ។ ឯកំរិតភាពសុទ្ធរបស់វាមានពីចន្លោះ ២៥ ទៅ ៤៥ ភាគរយ ។
- ហេរ៉ូអ៊ីនលេខ ៤ ជាប្រភេទដែលមានរាងជា ដុំគ្រួស ឬ ជាគ្រាប់ធញ្ញជាតិ ហើយតាមពេលគេផលិតវាជាជាលិកាតូចស្រដៀលនឹងម្សៅមីដែលមានពណ៌ ស ប្រផេះ ក្រហម ផ្កាឈូក ឬខៀវទៅតាមការផលិតរបស់ជនល្មើស ។

ឥទ្ធិពលដែលកើតមានឡើងក្រោយការប្រើប្រាស់នូវហេរ៉ូអ៊ីន៖

- ជាដំបូងក្នុងការប្រើប្រាស់វា គឺមានភាពចង់ក្អួតពិបាកទ្រាំ
- មានភាពងងុយខ្លាំងខុសធម្មតា ចង់លក់ ចង់ភ្ញាក់ បន្ទាប់មកនឹងធ្វើអោយអ្នកប្រើបានកំលាំងខ្លាំងក្លាមួយរំពេច (រយៈពេលមានជាតិថ្នាំ)
- មានអារម្មណ៍សប្បាយ អណ្តែតអណ្តូង ក្នុងរយៈពេលមួយខ្លីរួចក៏ដល់ពេលមានអារម្មណ៍ចង់សំរាក(ការសំរាកនេះមានរយៈពេលពី ១ម៉ោង ទៅ ៦ម៉ោង)
- មានភាពអស់កំលាំងក្រោយពេលជាតិថ្នាំមានការថយចុះ ដែលបណ្តាលអោយមានភាពរហិតរហៃ បាត់បង់សតិ ប្រឆើយកន្តើយ វេទនាក្នុងខ្លួន ដូចរស់ក្នុងឋាននរក ១៨ជាន់ ។

ឥទ្ធិពលយ៉ាងនេះហើយទើបវាក្លាយទៅជាគ្រោះថ្នាក់ដល់សង្គម ដែលមានគ្រប់សព្វបែបយ៉ាងទាំងការលួច ប្លន់ សម្លាប់ អពើពេស្យា ដើម្បីរកនូវកម្រៃទៅដោះដូរនឹងក្នុងការទទួលបាននូវហេរ៉ូអ៊ីន ។[១៤]

[១៤] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

តំបន់ដែលផលិតហេរ៉ូអ៊ីនត្រូវបានគេចាត់ថ្នាក់តាមលំដាប់ដែលមានចាប់ពី ប្រទេសអ៊ីរ៉ង់ ប្រទេសប៉ាគីស្ថាន ប្រទេសថៃ ប្រទេសឡាវ សហរដ្ឋអាមេរិក នឹងតំបន់អាហ្វ្រិក។[15]

### ៣.អ៊ិចស្តាស៊ី

នៅក្នុងប្រទេសកម្ពុជាយើង ថ្នាំញៀនអ៊ិចស្តាស៊ីត្រូវបានគេប្រើប្រាស់យ៉ាងហូរហែរនៅក្នុងគោលបំណងមិនល្អដែលវាមានលក់នៅក្នុងទីផ្សារងងឹត ។ ថ្នាំអ៊ិចស្តាស៊ីត្រូវបានគេស្គាល់ថាជាថ្នាំប្រភេទសម្រើប ឬ ហៅបានថាថ្នាំដែលធ្វើអោយមានអារម្មណ៍ អណ្តែតអណ្តូង ហើយវាត្រូវបានគេកំលាយចេញពីមេតំហ្វេតាមីន នឹងអំហ្វេតាមីន ហើយថ្នាំប្រភេទនេះត្រូវបានគេផលិតដោយគ្រាប់ ។

ឥទ្ធិពលនឹងគ្រោះថ្នាក់ដែលកើតមានឡើងក្រោយការប្រើប្រាស់៖

- មានអាការ រមូល រកកលចង់ក្អួត
- នៅមិនស្ងៀម អន្ទះសារ ព្រិលភ្នែកនឹងស្លាប់មិនសូវលឺដោយអំណាចនៃថ្នាំ
- ពេលប្រើក្នុងកំរិតច្រើននឹងធ្វើអោយមានអារម្មណ៍រវើរវាយ និយាយច្រើន លេងច្រើនខុសពីធម្មតាពិសេសគ្មានម្ចាស់ការក្នុងខ្លួន រហូតជាតិថ្នាំចាប់ផ្តើមអស់
- ចាប់ផ្តើមប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ខូចខួរក្បាល និងថ្លើម ។
- ធ្វើអោយសម្ពាធឈាម និងចលនាបេះដូងកើនឡើង ហើយអាចស្លាប់ប្រសិនបើអ្នកប្រើស្ថិតនៅទីកន្លែងដែលក្តៅ ។

តំបន់ដែលមានការផលិតថ្នាំប្រភេទនេះច្រើនជាងគេគឺនៅតាមព្រំដែន ថៃ-ឡាវ ដែលជាហេតុបណ្តាលអោយមានការហូរចូលរួមនឹងការផលិតផងដែរក្នុងប្រទេសកម្ពុជា។ ថ្នាំប្រភេទនេះក៏ត្រូវបានពួកជនល្មើសលួចផលិតផងដែរក្នុងតំបន់នានានៃប្រទេសចិន សម្រាប់ការនាំចេញទៅកាន់ពិភពលោកក្នុងការចែកចាយបន្ត ។[16]

### ៤.ការហិតញៀន

ការហិតញៀនគឺជា សារធាតុរាវដែលគេបានចម្រាញ់វាចេញពីជ័រកៅស៊ូហើយបានធ្វើការលាយវាជាមួយនឹងសារធាតុគីមីម្យ៉ាងគឺ តូលុយអែន[17] ដែលគេហាមប្រើប្រាស់ផ្តេសផ្តាស។

ចំណែកក្នុងប្រទេសកម្ពុជាយើងវិញការហិតញៀនក៏ត្រូវបានគេប្រើប្រាស់ជាច្រើនហូរហែរផងដែរពីសំណាក់ពួកក្មេងៗអនាថាទិញវាយកទៅហិត សំរាប់ការញៀនជាប្រចាំ។ ការប្រភេទនេះ

[១៥] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

[១៦] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

[១៧] តូលុយអែន សារធាតុដែលធ្វើអោយមានភាពញៀនក្នុងវត្ថុរាវ ឬ ខាប់

ត្រូវបានគេយកវាមកប្រើប្រាស់ជាប្រចាំក្នុងការតភ្ជាប់សំរាប់វត្ថុដែលដាច់ ឬ បាក់ រហែក ជាដើម។ ការញៀននេះត្រូវបានគេកំណត់វាដែលមានដូចជា ៖

-ការរូបមនុស្សកាន់កំភ្លើង ( RUBBR CEMENT ) ជាការសំរាប់បិទនៅរបស់ដែលរហែក

-ការក្បាលឆ្កែ ( X-66 )

-ការបិទការជំរាបទឹក (PVC)

-ការបិទទុយ៉ូ ( MAT TROL )

-ការបិទសំណរូបតោលើដៃ។[១៨]

ក្នុងចំណោមប្រភេទការខាងលើនេះ ការរូបមនុស្សកាន់កំភ្លើងគឺជាការដែលពេញនិយមជាងគេក្នុងពេលបច្ចុប្បន្នដោយវាបានផ្ទុកនៅសារធាតុតូលុយអែនប្រមាណជា ៨០ភាគរយដែលជាបរិមាណមួយខ្ពស់ជាងការនានា។ រីឯការក្បាលឆ្កែវិញត្រូវក្មេងៗអនាថាក្នុងប្រទេសកម្ពុជាប្រើប្រាស់ជាហូរហែរ ព្រោះការប្រភេទនេះត្រូវបាននាំចូលដោយស្របច្បាប់ក្នុងការប្រើប្រាស់ក្នុងប្រទេស ហើយមានសារធាតុតូលុយអែនប្រមាណតែ ៥០ភាគរយប៉ុណ្ណោះ។ តែការបីប្រភេទទៀតក្នុងកម្ពុជាមិនត្រូវបានគេរកឃើញថាមានការប្រើប្រាស់នោះទេដោយយើងមានច្បាប់ក្នុងការមិនអោយនាំចូលនូវការប្រភេទនេះ ។

ឥទ្ធិពលនឹងគ្រោះថ្នាក់ដែលកើតមានឡើងក្រោយការប្រើប្រាស់៖

- ធ្វើអោយរាងកាយខាងក្រៅមានភាពខុសភ្លែក
- បាត់បង់ភាពនឿយហត់ដែលមាន
- មិនស្រេកឃ្លានអាហារ
- មិនទទួលដឹងពីការឈឺចាប់ដែលកើតមានលើខ្លួន
- ធ្វើអោយមានចិត្តក្លាហានក្នុងការប្រព្រឹត្តបទល្មើស លួច ប្លន់ ឆក់ ឬ វាយតប់គ្នាជាដើម
- ធ្វើអោយមានជំងឺ រលាកសួត រលាកផ្លូវដង្ហើម ហើមសួត
- បើការប្រើប្រាស់ហួសកំរិតនិងធ្វើអោយអ្នកប្រើប្រាស់ឆាប់បាត់បង់ស្មារតី ស្រើបស្រាលគ្មានព្រំដែន ចេះតែមានអារម្មណ៍សប្បាយៗ រវើរវាយបាត់ម្ចាស់ការក្នុងខ្លួន
- គុលិកាឈាមបាត់បង់ នាំអោយមានជំងឺបេះដូង ស្បែកប្រែជាស្លូត ។

[១៨] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

តំបន់ដែលផលិតការទាំងអស់ខាងលើនេះ ត្រូវបានគេកត់សម្គាល់ទីតាំងផលិតបានថាវាមិនមានការផលិតនៅខាងក្រៅពីរោងចក្រដែលមានច្បាប់ផលិតនោះទេ។ រោងចក្រភាគច្រើនគឺស្ថិតក្នុងប្រទេសចិន-វៀតណាម និងខ្លះទៀតស្ថិតក្នុងប៉ែកអឺរ៉ុប។[19]

## ផ្នែកទី២ ប្រភពនឹងការកកើតច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ត្រង់ចំណុចនេះ នឹងបង្ហាញពីកំណើតនៃការកំកើតនូវច្បាប់ស្តីពីគ្រឿងញៀនរបស់កម្ពុជារួមនឹងការបង្ហាញពីអត្ថន័យរបស់មាត្រាទាំងអស់របស់ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២នេះផងដែរ ។

### កថាខណ្ឌទី ១ ប្រភពនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២គឺជាច្បាប់ពិសេស ដែលកើតឡើងដោយមានប្រភពពីប្រភពនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិក្នុងគោលបំណងអោយច្បាប់នេះមានអំណាចគ្រប់គ្រង់ និងថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខ ជូនប្រជាជននឹងដាក់ទោសលើពួកឧក្រឹដ្ឋជន ។

#### ក.ប្រភពនៃច្បាប់

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនមានប្រភពចេញមកពី:

##### ១. ច្បាប់ជាតិ

ច្បាប់ជាតិគឺជាច្បាប់គោល ដែលសំខាន់បំផុតក្នុងការកកើតច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ។ ហើយមានច្បាប់ ៣ ជាគ្រឹះធំបំផុតនោះមានដូចជា ៖

១.ច្បាប់ស្តីពីការហាមឃាត់អាភៀន១៩៥៥

២.ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២

៣.ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។

##### ២. ច្បាប់អន្តរជាតិ

ច្បាប់អន្តរជាតិក៏បានចូលរួមចំនែកយ៉ាងសំខាន់ ក្នុងការកើតច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែរ ហើយច្បាប់សំខាន់ៗទាំងនោះមានដូចជា៖

១.អនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២។

២.អនុសញ្ញាស្តីពីសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១។

៣.អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំង នឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨។ល។

---

[១៩] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

**ខ.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបានរដ្ឋសភាជាតិអនុម័តកាលពីថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី៧នីតិកាលទី១ ហើយត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០១៩៧/០១ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ ។ ច្បាប់នេះមាន ២៧ជំពូក និង ១១១ មាត្រា។

ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបានរដ្ឋសភាជាតិអនុម័ត កាលពីថ្ងៃទី១៧ខែមីនា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២នីតិកាលទី៣ ហើយត្រូវបាន ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥/០៥/០១៤ចុះថ្ងៃទី៩ខែឧសភាឆ្នាំ២០០៥។ ច្បាប់នេះមាន០២មាត្រា។ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនត្រូវបាន រដ្ឋភាជាតិអនុម័តកាល ពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ និងប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខនស/រកម/០១១២/០០១ ចុះថ្ងៃទី០២ខែមករាឆ្នាំ២០១២ ដែលមានទាំងអស់ ១២៥មាត្រា ចែកចេញជា៩ជំពូក និង២៥ផ្នែក។

**កថាខណ្ឌទី ២ ស្ថាប័នអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា**

ក្នុងការអនុវត្តនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២នៅកម្ពុជាក្រោមការដឹកនាំ ដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា ពេលនោះស្ថានប័នដែលគ្រប់គ្រងនូវបញ្ហាគ្រឿងញៀនត្រូវបានចាំបដិសន្ធិឡើងដែលមាន ឈ្មោះថា " **អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** " ដែលហៅកាត់ជាភាសាខ្មែរថា **អ.ជ.ប.គ.ញ** ហើយមានឈ្មោះជាភាសាអន្តរជាតិថា NATIONAL AUTHORITY FOR CONBATING DRUGS និងអក្សរកាត់ថា N.A.C.D ។ ក្នុងនេះផងដែរអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀនមាន អគ្គលេខាធិការដ្ឋានមួយដែលទទួលខុសត្រូវក្នុងរាល់ការដាក់អនុវត្តន៍នូវគោល នយោបាយ និងធានាក្នុងការសម្របសម្រួលនានារបស់រាជរដ្ឋាភិបាលជាមួយបណ្តាអន្តរក្រសួង ។

**ក. រចនាសម្ព័ន្ធរបស់ អ.ជ.ប.គ.ញ**

ដោយយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩៥ បានចែងច្បាស់លាស់ពីសមាសភាពរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដូចតទៅ៖

| | |
|---|---|
| -សហនាយករដ្ឋមន្ត្រី | ប្រធាន |
| -រដ្ឋមន្ត្រីក្រសួងយុត្តិធ៌ម | អនុប្រធាន |
| -ឥស្សរជន ថ្នាក់ស្មើរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| -រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |

-រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

-រដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

-រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

-រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា សមាជិក

-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

-រដ្ឋមន្ត្រីក្រសួងព័ត៌មាន សមាជិក

-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល សមាជិក

-ទេសាភិបាល ធានាគាជាតិនៃកម្ពុជា សមាជិក

-រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ លេខាធិការ ។

ដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអគ្គលេខាធិការដ្ឋានមួយជាលេខាធិការ ហើយត្រូវបានចាត់ចែងមានរចនាសម្ព័ន្ធដូចខាងក្រោម៖

-អគ្គលេខាធិការ ១រូប ប្រធាន

-អគ្គលេខាធិការរង ៣រូបឡើងទៅ ជាជំនួយការ

-មានរចនាសម្ព័ន្ធជានាយកដ្ឋាន និងអង្គភាពដែលមានថ្នាក់ស្មើនាយកដ្ឋានជាជំនួយការ រួមមាន៖

១-**នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ** ៖ មាននាទីសម្របសម្រួលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន និង គ្រប់គ្រងឯកសាររដ្ឋបាលផ្សេងៗ ។ ដឹកនាំដោយ ប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។

២-**នាយកដ្ឋាន ផែនការ និង បណ្តុះបណ្តាល**៖ មាននាទីរៀបចំយុទ្ធសាស្ត្រ និងលើកផែនការគោលនយោបាយ ក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ នាំចូលនឹងការជញ្ជូនគ្រឿងញៀន។ ដឹកនាំដោយ ប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។

៣-**នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ៖** មាននាទីទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលបរទេស និងអង្គការក្នុងតំបន់ ឬ អន្តរជាតិ ។ ដឹកនាំដោយ ប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។

៤-**នាយកដ្ឋាន អនុវត្តច្បាប់៖** មាននាទីស្រាវជ្រាវនិង ប្រមូលព័ត៌មានពាក់ព័ន្ធនិងគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័ននឹងអង្គការពាក់ព័ន្ធដទៃទៀត។ ដឹកនាំដោយប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។ ដោយការយកព័ត៌មានមានការងារច្រើននឹងពិបាកគេបានបង្កើតនូវ **មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន** ដែលស្ថិតនៅក្រោមចំណុះនាយកដ្ឋាននេះ មាននាទីចងក្រងរបាយការណ៍ប្រចាំឆ្នាំស្តីពីទិន្នន័យគ្រឿងញៀនខុសច្បាប់ និងប្រព័ន្ធតាមដានជាប្រចាំនៅកម្ពុជា ។

៥-**នាយកដ្ឋាន នីតិកម្ម អប់រំនិងស្តារនីតិសម្បទា៖** មាននាទីរៀបចំអនុវត្តកម្មវិធីអប់រំបង្ការទប់ស្កាត់ និងកាត់បន្ថយការប្រើបំពានគ្រឿងញៀនក្នុងប្រទេស។ ដឹកនាំដោយប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។

៦-**នាយកដ្ឋាន ស្រាវជ្រាវនិងត្រួតពិនិត្យ៖** មាននាទីស្រាវជ្រាវរាល់សភាពការណ៍និង ប្រមូលព័ត៌មានទូទៅដែលពាក់ព័ន្ធនឹងសារធាតុគីមី និង សារធាតុទាំងឡាយណាដែលប្រើប្រាស់សំរាប់ផ្សំជាគ្រឿងញៀន។ ដឹកនាំដោយ ប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ ។

៧-**មន្ទីពិសោធន៍គ្រឿនញៀន៖** មាននាទីធ្វើការស្រាវជ្រាវនិងធ្វើការវិភាគ តាមបែបវិទ្យាសាស្ត្រ លើលក្ខណៈគីមី និងលក្ខណៈរូបនៃសារធាតុញៀន និងគីមីផ្សំគ្រឿងញៀនដែលបានកំណងត់ជាស្រេច ។ មន្ទីពិសោធន៍គ្រឿនញៀនត្រូវបានដឹកនាំដោយប្រធានមន្ទីរពិសោធន៍១រូប និងមានអនុប្រធានជាជំនួយការ ។

| | |
|---|---|
| -អគ្គស្នងការនគរបាលជាតិ | ជាសេនាធិការ |
| (មានមន្ទីរប្រឆាំងគ្រឿងញៀន ជាចំនុះ) | |
| -កងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសេនាធិការ |
| -កងយុទ្ធពលខេមរភូមិន្ទ | ជាសេនាធិការ |
| -មានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្ត-ក្រុង ដែលមានសមាសភាពដូចតទៅ: | ជាសេនាធិការ |
| -អភិបាលខេត្ត ឬ ក្រុង | ប្រធាន |
| -អភិបាលរងខេត្ត ឬ ក្រុង | សមាជិកអចិន្ត្រៃយ៍ |
| -ស្នងការ ឬ តំណាងនគរបាលខេត្ត ឬ ក្រុង ១រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងយោធាភូមិភាគ ១រូប | សមាជិក |
| (សំរាប់តែខេត្តដែលមានយោធាភូមិភាគឈរជើង) | |

-មេបញ្ជាការ ឬ តំណាងកងនាវាចរខេមរភូមិន្ទ ១រូប សមាជិក
(មូលដ្ឋានដែនសមុទ្រ)
-មេបញ្ជាការ ឬ តំណាងកងនាវាចរខេមរភូមិន្ទ ១រូប សមាជិក
(មូលដ្ឋានដែនទន្លេ)
-មេបញ្ជាការ ឬ តំណាងកងទ័ពអាកាសចរណ៍
នៃកងយោធពលខេមរភូមិន្ទ ១រូប សមាជិក
-មេបញ្ជាការ ឬ តំណាងកងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ១រូប សមាជិក
-ប្រធានស្នាក់ការ សាខាគយ-រដ្ឋាករ ខេត្ត-ក្រុង ១រូប សមាជិក
-ប្រធានស្នាក់ការសាខាកាំកុងត្រូល ខេត្ត-ក្រុង ១រូប សមាជិក
-ប្រធាន ឬ តំណាងមន្ទីរជំនាញចំណុះទាំងអស់ ខេត្ត-ក្រុង ១រូប សមាជិក ។[២០]

**ខ. ការបែងចែកច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**

ច្បាប់នៃការត្រួតពិនិត្យគ្រឿងញៀនថ្មីឆ្នាំ ២០១២ ត្រូវបានបង្កើតឡើងដោយមានការបែងចែកជា៖

- **៩** ជំពូក
- **២៤** ផ្នែកនឹង
- **១២៥** មាត្រាដែលមានដូចជា៖

**ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅមាន៦មាត្រាចាប់ពីមាត្រា១ដល់មាត្រា៦៖**

- មាត្រា ១ ចែងអំពីគោលបំណង
- មាត្រា ២ ចែងអំពីគោលដៅ
- មាត្រា ៣ ចែងអំពីវិសាលភាព
- មាត្រា ៤ ចែងអំពីនិយមន័យវាក្យស័ព្ទបច្ចេកទេសស
- មាត្រា ៥ ចែងអំពីចំណាត់ថ្នាក់គ្រឿងញៀននិង
- មាត្រា ៦ ចែងអំពីការកែប្រែចំណាត់ថ្នាក់។
- មាត្រា ៥ ចែងថា:គ្រឿងញៀនត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោយនេះ ៖

[២០] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

| តារាង ១ | តារាង ២ | តារាង ៣ | តារាង ៤ |
|---|---|---|---|
| រុក្ខជាតិនិងសារធាតុដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរហើយដែលគ្មានផលប្រយោជន៍អ្វីខាងវេជ្ជសាស្ត្រ។ | រុក្ខជាតិនិងសារធាតុដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរប៉ុន្តែមានផប្រយោជន៍ខាងវេជ្ជសាស្ត្រ។ | រុក្ខជាតិនិងសារធាតុដែលបណ្ដាលឲ្យមានគ្រោះថ្នាក់ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ។ | សារធាតុគីមីផ្សំទាំងឡាយដែលបានចាត់ថ្នាក់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់។ |

**ជំពូកទី២ ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀនមាន ៣ ផ្នែកនិង៣មាត្រាចាប់ពីមាត្រា៧ដល់មាត្រា៩៖**

១. ផ្នែកទី១ ចែងអំពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមាន ១ មាត្រា គឺមាត្រា ៧

- មាត្រា៧បញ្ញត្តអំពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

២. ផ្នែកទី២ ចែងអំពីមន្ទីរប្រឆាំងគ្រឿងញៀនមាន ១ មាត្រា គឺមាត្រា ៨

- មាត្រា៨បញ្ញត្តអំពីតួនាទីមន្ទីរប្រឆាំងគ្រឿងញៀន។

៣.ផ្នែកទី៣ ចែងអំពីស្ថាប័នត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន មាន១មាត្រាគឺ មាត្រា ៩

- មាត្រា៩បញ្ញត្តអំពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន។

**ជំពូកទី៣ ស្ដីពីសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនមាន៣ផ្នែកនិង១៧មាត្រាចាប់ពីមាត្រា១០ដល់មាត្រា២៦៖**

១. ផ្នែកទី១ ចែងអំពីបទប្បញ្ញត្តិទូទៅមាន ៤ មាត្រា ចាប់ពី មាត្រា ១០ ដល់មាត្រា ១៣

- ផ្នែកនេះបញ្ញត្តអំពី សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ល័ក្ខខ័ណ្ឌនៃការចេញអាជ្ញាប័ណ្ណឬការអនុញ្ញាតស្ដីពីគ្រឿងញៀន ការអនុញ្ញាតសម្រាប់ការសិក្សាស្រាវជ្រាវដោយប្រើប្រាស់គ្រឿងញៀននិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឲ្យចែកចាយផ្គត់ផ្គង់និងលក់ឱសថដែលមានសារធាតុញៀន។

២. ផ្នែកទី២ ចែងអំពីស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាប័ណ្ណឬការអនុញ្ញាតទាក់ទង នឹងគ្រឿងញៀនមាន ២ មាត្រា ចាប់ពី មាត្រា ១៤ ដល់មាត្រា ១៥

- ផ្នែកនេះបញ្ញត្តអំពី អាជ្ញាប័ណ្ណ ឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី១ ទី២ និងទី៣ ព្រមទាំងអាជ្ញាប័ណ្ណឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី៤។

៣. ផ្នែកទី៣ ចែងអំពីការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន មាន១១មាត្រា ចាប់ពីមាត្រា ១៦ ដល់ មាត្រា ២៦

- ផ្នែកនេះបញ្ញត្តអំពី វិធានការត្រួតពិនិត្យផលិតផលលាយផ្សំការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្មការត្រួតពិនិត្យ ការឆ្លងកាត់ ឬការឈប់សំចតនៃគ្រឿងញៀន បទប្បញ្ញត្តិចំពោះសារធាតុគីមីផ្សំក្នុងតារាងទី៤ ព័ត៌មានដែលត្រូវរាយការណ៍ការកំណត់បរិមាណនៃសេចក្ដីត្រូវការនូវគ្រឿងញៀន កាតព្វកិច្ចក្នុងការចុះបញ្ជីការធ្វើបញ្ជីសារពើភ័ណ្ឌ និងការគណនាសមតុល្យការវេចខ្ចប់ និងការដាក់ស្លាកសញ្ញាការត្រួតពិនិត្យ និងអធិការកិច្ចព្រមទាំងការត្រួតពិនិត្យនៅតាមកំពង់ផែរួចពន្ធ និងតំបន់រួចពន្ធ។

**ជំពូកទី៤ ស្ដីពីបទប្បញ្ញត្តិព្រហ្មទណ្ឌមាន៨ផ្នែកនិង៥៦មាត្រាចាប់ពីមាត្រា២៧ដល់មាត្រា៧២៖**

១. ផ្នែកទី១ ចែងអំពីបទប្បញ្ញតិទូទៅ មាន ១១ មាត្រា ចាប់ពីមាត្រា ២៧ ដល់ មាត្រា ៣៧

- ផ្នែកនេះ បញ្ញត្តអំពីការអនុវត្តបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ ការប្រកាសមូលទោសនិយមន័យនៃការប៉ុនប៉ង ការបង្ខំឲ្យទទួលការព្យាបាល ការលើកលែងឲ្យរួចផុតពីទោស ការសម្រាលទោសការអនុវត្តស្ថានសម្រាលទោស ទោសបន្ថែមសម្រាប់រូបវន្តបុគ្គល ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មូលទោសអនុវត្តចំពោះនីតិបុគ្គលនិងទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល។

២.ផ្នែកទី២ ចែងអំពីបទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ១ និង តារាងទី ២ មាន ៨មាត្រាចាប់ពី មាត្រា ៣៨ ដល់ មាត្រា ៤៥

- បញ្ញត្តអំពី បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន បទផលិតដោយខុសច្បាប់នូវសារធាតុញៀន បទរក្សាទុកដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទរឹបយកសារធាតុញៀន បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនបទបង្ខំអូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់ នូវសារ

ធាតុញៀន បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

៣. ផ្នែកទី៣ ចែងអំពីបទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៣ មាន ៨ មាត្រាចាប់ពីមាត្រា ៤៦ ដល់ មាត្រា ៥៣

- ផ្នែកនេះបញ្ញត្តអំពី បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន បទផលិតដោយខុសច្បាប់នូវសារធាតុញៀន បទរក្សាទុកដឹកជញ្ជូនឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទរឹបយកសារធាតុញៀន បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទបង្ខំអូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

៤.ផ្នែកទី៤ ចែងអំពីបទល្មើសទាក់ទងនឹងសារធាតុគីមីផ្សំក្នុងតារាងទី ៤ មាន ២ មាត្រាចាប់ពីមាត្រា ៥៤ ដល់ មាត្រា ៥៥

- ផ្នែកនេះបញ្ញត្តអំពី បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំនិងបទផ្តល់ឲ្យអនីតិជនហិតស្រូបនូវសារធាតុគីមីផ្សំជាអាទិ៍។

៥. ផ្នែកទី៥ ចែងអំពីបទល្មើសទាក់ទងនឹងបរិក្ខារនិងសម្ភារ មាន ១ មាត្រា គឺមាត្រា៥៦

- ផ្នែកនេះបញ្ញត្តអំពីបទផលិតរក្សា ទុកដឹកជញ្ជូនឬជួញដូរបរិក្ខារឬសម្ភារសម្រាប់ប្រើប្រាស់ក្នុងការផលិតឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

៦. ផ្នែកទី៦ ចែងអំពីបទល្មើសទាក់ទងនឹងការញុះញង់មាន ១ មាត្រាគឺ មាត្រា ៥៧

- ផ្នែកនេះបញ្ញត្តអំពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើស។

៧.ផ្នែកទី៧ ចែងអំពីបទល្មើសផ្សេងទៀតមាន១១មាត្រាចាប់ពីមាត្រា ៥៨ ដល់ មាត្រា ៦៨

- ផ្នែកនេះបញ្ញត្តអំពីបទទទួលផលបទល្មើស បទចូលរួមក្នុងក្រុមឧក្រិដ្ឋជនការផ្តន្ទាទោសចំពោះមេដឹកនាំក្រុមឧក្រិដ្ឋជនបទប្រឆាំងនឹងវិធានការឆែកឆេរសរីរាង្គបទបំពានលើបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងការប្រើប្រាស់ឱសថដែលមានសារធាតុញៀន សារធាតុញៀនឬសារធាតុគីមីផ្សំបទ
- បើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀនបទបំពានលើការសម្ងាត់នៃវិធានការតាមដានបទរារាំងការធ្វើអធិការកិច្ច បទបំពានលើវិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូសបទមិនគោរពការរឹបអូសនិងបទគេចវេះពីកាតព្វកិច្ចព្យាបាលដោយបង្ខំ។

៨. ផ្នែកទី៨ ចែងអំពីបទប្បញ្ញត្តិស្តីពី ការសំអាតប្រាក់ទាក់ទងនឹងបទល្មើសគ្រឿងញៀនមាន ៤ មាត្រាចាប់ពី មាត្រា ៦៩ ដល់ មាត្រា ៧២

- ផ្នែកនេះបញ្ញត្តអំពីបទប្បញ្ញត្តិទូទៅ និយមន័យនៃការសំអាតប្រាក់បទសំអាតប្រាក់ និងស្ថានទម្ងន់ទោស។

**ជំពូកទី៥ ស្តីពីបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌមាន ៤ ផ្នែក និង២៧មាត្រា ចាប់ពីមាត្រា ៧៣ ដល់ មាត្រា៩៩៖**

១. ផ្នែកទី១ ចែងអំពីបទប្បញ្ញត្តិទូទៅមាន ២ មាត្រា ចាប់ពី មាត្រា ៧៣ ដល់ មាត្រា ៧៤

- បញ្ញត្តអំពីការអនុវត្តបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនិងការចូលរួមក្នុងនីតិវិធី។

២ ផ្នែកទី២ចែងអំពីវិធានការស៊ើបអង្កេតនិងស៊ើបសួរមាន ១៣ មាត្រាចាប់ពីមាត្រា ៧៥ ដល់ មាត្រា ៨៧

- បញ្ញត្តអំពីការឆែកឆេរនៅតាមព្រំដែន ការឆែកឆេរសរីរាង្គដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រការត្រួតពិនិត្យក្នុងសេវាប្រៃសណីយ៍ ការឃ្លាំមើលការឆ្លងកាត់ការប្រគល់ដោយមានការឃ្លាំមើល និងការពន្យាពេលញុះញង់ឲ្យលក់គ្រឿងញៀនការត្រួតពិនិត្យប្រតិបត្តិការឃ្លាំមើលការបិទស្លាក និងការថែរក្សាវត្ថុតាងការដកយកវត្ថុដែលសង្ស័យថាជាគ្រឿងញៀន សម្រាប់ធ្វើកោសលវិច្ច័យតាមបច្ចេកទេសវិទ្យាសាស្ត្រការប្រគល់ការបំផ្លាញចោលនូវគ្រឿងញៀន ដែលបានចាប់យកការតាមដានការសម្ងាត់ធនាគារ និងការបិទគ្រឹះស្ថានការហាមឃាត់អាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន។

៣.ផ្នែកទី៣ ចែងអំពីវិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូសមាន ៥ មាត្រាចាប់ពី មាត្រា ៨៨ ដល់មាត្រា ៩២

- ផ្នែកនេះបញ្ញត្តអំពីវិធានការបន្ទាន់សម្រាប់ធានាការរឹបអូស ការឃាត់ទុកទ្រព្យសម្បត្តិ ការបង្កកទ្រព្យសម្បត្តិ ទ្រព្យបញ្ចូលគ្នានិងបន្ទុកលើជនប្រឆាំងនឹងសេចក្តីសម្រេច។

៤.ផ្នែកទី៤ ចែងអំពីវិធានការរឹបអូសមាន ៧ មាត្រាចាប់ពីមាត្រា ៩៣ ដល់ មាត្រា ៩៩

- ផ្នែកនេះបញ្ញត្តអំពី ការរឹបអូសដាច់ខាតការរឹបអូសវត្ថុជាអាទិ៍បន្ទុករបស់ជនប្រឆាំងនឹងសេចក្តីសម្រេចរឹបអូសការរឹបអូសទ្រព្យសម្បត្តិជាអាទិ៍ ការលក់ដោយរដ្ឋនូវវត្ថុឬទ្រព្យសម្បត្តិ រឹបអូសបណ្តឹងចំពោះសេចក្តីសម្រេចស្ថាពរទាក់ទងនឹងការរឹបអូស

ទ្រព្យសម្បត្តិជាអាទិ៍ និងការទុកជាមោឃៈនូវអំពើទាំងឡាយដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការបង្កកឬការរឹបអូស។

**ជំពូកទី៦ ស្តីពីវិធានការព្យាបាលនិងស្តារនីតិសម្បទាមាន ៤ ផ្នែក និង ១១ មាត្រាចាប់ពីមាត្រា ១០០ ដល់មាត្រា១១០៖**

១.ផ្នែកទី១ ចែងអំពីបទប្បញ្ញត្តិទូទៅមាន ៤មាត្រា ចាប់ពី មាត្រា ១០០ ដល់ មាត្រា ១០៣

- ផ្នែកនេះបញ្ញត្តអំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់សេវាព្យាបាលនិងស្តារនីតិសម្បទាគោលការណ៍
- នៃការព្យាបាលនិងស្តារនីតិសម្បទាវិធាននៃការគ្រប់គ្រងការព្យាបាលនិងការស្តារនីតិសម្បទានិងការសម្ងាត់នៃការព្យាបាលនិងការស្តារនីតិសម្បទា។

២.ផ្នែកទី២ ចែងអំពីការព្យាបាលនិងស្តារនីតិសម្បទាដោយស្ម័គ្រចិត្តមាន ១ មាត្រាគឺមាត្រា ១០៤

- ផ្នែកនេះបញ្ញត្តអំពីការព្យាបាលនិងស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត។

៣.ផ្នែកទី៣ ចែងអំពីល័ក្ខខ័ណ្ឌនៃការចោទប្រកាន់ និងការអនុវត្តទោសចំពោះអ្នកញៀនគ្រឿងញៀនមាន ២ មាត្រា ចាប់ពី មាត្រា ១០៥ ដល់ មាត្រា ១០៦

- ផ្នែកនេះបញ្ញត្តអំពីល័ក្ខខ័ណ្ឌ នៃការចោទប្រកាន់អ្នកញៀនគ្រឿងញៀន និងល័ក្ខខ័ណ្ឌនៃការអនុវត្តទោសចំពោះអ្នកញៀនគ្រឿងញៀន។

៤. ផ្នែកទី៤ ចែងអំពីការព្យាបាលនិងស្តារនីតិសម្បទាដោយបង្ខំមាន ៤ មាត្រាចាប់ពីមាត្រា ១០៧ ដល់ មាត្រា ១១០

- ផ្នែកនេះបញ្ញត្តអំពីល័ក្ខខ័ណ្ឌទូទៅនៃការព្យាបាលនិងការស្តារនីតិសម្បទាដោយបង្ខំការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំបង្គាប់ដោយព្រះរាជអាជ្ញាការបង្ខំឲ្យព្យាបាលនិងស្តារនីតិសម្បទានៅក្នុងដំណាក់កាលស៊ើបសួរនិងដំណាក់កាលជំនុំជម្រះនិងមូលដ្ឋានដោយឡែកនៃការកំណត់ទោស។

**ជំពូកទី៧ ស្តីពីបត្យាប័ននិងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់មាន ២ ផ្នែក និង១០មាត្រា ចាប់ពី មាត្រា ១១១ ដល់ មាត្រា ១២០៖**

១. ផ្នែកទី១ ចែងអំពីបត្យាប័នមាន ៣ មាត្រា ចាប់ពី មាត្រា ១១១ ដល់ មាត្រា ១១៣

- បញ្ញត្តអំពីបត្យាប័ននៃអាណិកជនបរទេសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាបទប្បញ្ញត្តិគ្រប់គ្រងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទង នឹងគ្រឿងញៀននិងការឆ្លងកាត់។

២.ផ្នែកទី២ ចែងអំពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់មាន ៧ មាត្រា ចាប់ពី មាត្រា ១១៤ ដល់មាត្រា ១២០

- បញ្ញត្តអំពី សំណើរបស់រដ្ឋបរទេសចំពោះព្រះរាជាណាចក្រកម្ពុជាដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេសជំនួយអាចត្រូវផ្តល់ជូនដោយផ្អែកលើល័ក្ខខ័ណ្ឌមូលហេតុចាំបាច់ សម្រាប់ការបដិសេធសំណើសុំជំនួយវិធានការនៃការសម្ងាត់ធនាគារ សំណើសុំផ្តល់ភស្តុតាងក្នុងតុលាការនៅក្នុងរដ្ឋបរទេស សំណើដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេសមួយដើម្បីសុំជំនួយក្នុងការស៊ើបអង្កេតឬចំណាត់ការតុលាការ និងសហប្រតិបត្តិការអន្តរជាតិ។

**ជំពូកទី៨ ស្តីពីអន្តរប្បញ្ញត្តិមាន ៤ មាត្រា ចាប់ពីមាត្រា ១២១ ដល់ មាត្រា១២៤៖**

- ជំពូកនេះបញ្ញត្តអំពីអន្តរប្បញ្ញត្តិ ស្តីពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនអន្តរប្បញ្ញត្តិស្តីពីអាជ្ញាបណ្ណ និងការអនុញ្ញាតអន្តរប្បញ្ញត្តិស្តីពីនីតិវិធីនិងអន្តរប្បញ្ញត្តិស្តីពីបទល្មើស។

**ជំពូកទី៩ ស្តីពីអវសានប្បញ្ញត្តិមាន ០១ មាត្រា គឺ មាត្រា១២៥៖**

- ជំពូកនេះបញ្ញត្តអំពីនិរាករណ៍នៃបទប្បញ្ញត្តិនិងករណីលើកលែង។

# ជំពូកទី ២

# ការគ្រប់គ្រងលើស្ថានការណ៍គ្រឿងញៀន

ការគ្រប់គ្រងទៅលើការសភាពការណ៍គ្រឿងញៀន វាជារឿងមួយដ៏សែនពិបាកសំរាប់ប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូលក្នុងការកំណត់សភាព និងស្ថានការណ៍ជាក់លាក់របស់វាខ្លាំងណាស់ព្រោះតែក្រុមឧក្រិដ្ឋជនមានភាពរហ័ស និងមានគ្នីគ្នាជាក្រុមតូច-ធំមានការទាក់ទងប្រាស្រ័យគ្នាជាប្រព័ន្ធស៊ីចង្វាក់ជាច្រើននៅពាសពេញសកលលោក ដែលជាហេតុធ្វើអោយក្នុងការតាមដានរបស់សមត្ថកិច្ចទៅលើជនល្មើសមានភាពលំបាកយ៉ាងខ្លាំង [21]។

## ផ្នែកទី១ សភាពការណ៍ទូទៅនឹងការត្រួតពិនិត្យ

ត្រង់ចំណុចនេះ នឹងបង្ហាញពីសភាពការណ៍ជាទូទៅអំពីការផលិតការចែកចាយនូវគ្រឿងញៀនបូករួមនិងការបង្ហាញពីមធ្យោបាយរបស់ពួកឧក្រិដ្ឋក្នុងការនាំចេញ-នាំចូលនូវគ្រឿងញៀនក្នុងពិភពលោកយើងនេះ។

ខាងក្រោមនេះនឹងបង្ហាញនូវពត៌មានខ្លះៗ ដែលទាក់ទងនឹងសភាពការណ៍ក្នុងអន្តរជាតិក៏ដូចជាក្នុងប្រទេសកម្ពុជាយើងផងដែរ ៖

### កថាខណ្ឌទី១ ស្ថានការណ៍គ្រឿងញៀនអន្តរជាតិ

គ្រឿងញៀនគឺជាវត្ថុមានតម្លៃរបស់ជនល្មើស វាប្រៀបបាននឹងតម្លៃនៃ ដុំមាស ឬ ត្បូងពេជ្រ ហេតុនេះហើយទើបឧក្រិដ្ឋជនអន្តរជាតិមានការចាត់ចែងយ៉ាងប្រុងប្រយ័ត្ន និងច្បាស់លាស់ជាក់លាក់ក្នុងការចែកចាយ នឹងធ្វើការជួញដូរ។

#### ក. អំពីក្រុមឧក្រិដ្ឋកម្មគ្រឿងញៀន

អង្គការឧក្រិដ្ឋកម្មគ្រឿងញៀន បានចាប់ផ្តើមខ្លួនពីទ្រង់ទ្រាយតូចហើយពង្រីកសកម្មភាពកាន់តែធំឡើងៗ ។ ក្រុមឧក្រិដ្ឋជនត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធស្រដៀងទៅនឹងក្រុមហ៊ុនពាណិជ្ជកម្មមួយដោយជនល្មើសត្រូវការសិក្សារៀនសូត្រស្វែងយល់អំពីទីផ្សារ ហើយក៏ត្រូវការអ្នកជំនាញផ្នែកហិរញ្ញវត្ថុ អ្នកឯកទេស អ្នកច្បាប់ជាដើមក្នុងការទប់ទល់នឹងការអង្កេតពីសំណាក់សមត្ថកិច្ច ។ ក្នុងការចែកចាយពួកឧក្រិដ្ឋជនគ្មានការព្រួយបារម្ភអំពីរឿងគ្មានទីផ្សារឡើយ ។ ពួកគេធ្វើកិច្ចការនេះដោយមានការប្រុងប្រយ័ត្នខ្ពស់បំផុតក្នុងការវេចខ្ចប់ ការដឹកជញ្ជូន ការចរាចរចែកចាយ រួមនឹងផ្នែកសន្តិសុខផងដែរ។

[21] ស្ថានការណ៍គ្រឿងញៀនអន្តរជាតិ

វាជាជំនួញខុសច្បាប់ដ៏ធំលេខមួយ ដែលក្រុមឧក្រិដ្ឋជនទទួលបានផលចំណេញយ៉ាងសម្បើមឥតគណនា ។ ផលចំណេញទាំងនោះគេទទួលបានជាសាច់ប្រាក់សុទ្ធដែលត្រូវបានការពារ និងទុកដាក់ជាកម្មសិទ្ធិដោយក្រុមជនសង្គមងងឹត ដោយមិនចាំបាច់ក្នុងការនាំចូលមកកាន់ប្រទេសវិញឡើងពោលគឺគេសំអាតលុយនោះអោយទៅជាលុយស្របច្បាប់នៅក្នុងតំបន់នោះតែម្តង។ ប្រាក់ដែលរកបានភាគច្រើន គេទិញអាវុធ និងជ្រើសរើសមនុស្សកាន់តែច្រើនក្នុងការចូលរួមក្រុមដើម្បីអោយបានគ្នាច្រើនក្នុងការធ្វើការ ។

ជាមួយមនុស្សនឹងអាវុធកាន់តែច្រើន គេបានពង្រីកនិងបំបែកខ្លួនទៅជាឧក្រិដ្ឋកម្មផ្សេងៗទៀតមានដូចជា ពួកភេរវកម្ម ឧក្រិដ្ឋកម្មក្នុងការជួញដូរអាវុធ ឧក្រិដ្ឋកម្មក្នុងការជួញដូរមនុស្សជាដើម ។ គេប្រើប្រាស់ចំនូលនានាដែលខុសច្បាប់នេះ ដើម្បីសូកប៉ាន់មន្រ្តីរដ្ឋាភិបាលអោយការពារពួកគេក៏ដូចជាធ្វើអោយរដ្ឋាភិបាលផ្តល់សិទ្ធិអោយឧក្រិដ្ឋជនទាំងនោះដោយមិនដឹងខ្លួន ហើយវានឹងជ្រៀតជ្រែកក្នុងការគ្រប់គ្រងសហជីពកម្មករ ទីបំផុតគេនឹងធ្វើការគាប់សង្កត់រដ្ឋាភិបាលរួចគ្រប់គ្រងពាណិជ្ជកម្មស្របច្បាប់ទាំងស្រ៊ុងក្នុងគោលបំណងងាយស្រួលធ្វើការលាងលុយកខ្វក់ និងឈានទៅរកវិធីយកលុយនោះទៅធ្វើការវិនិយោគវិញនាពេលអនាគត ។ ហើយឧក្រិដ្ឋជនក៏បានប្រើប្រាស់នូវចំណូលទាំងអស់នោះក្នុងការសូកប៉ាន់ ឬ ទិញប្រព័ន្ធផ្សព្វផ្សាយដើម្បីសំរេចបានការការពារនិងទំនាក់ទំនងសាធារណៈល្អ ឬ ក្នុងគោលបំណងនឹងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋាភិបាលនឹងអ្នកនយោបាយក្នុងការប្រឆាំងនឹងពួកឧក្រិដ្ឋជនទាំងនោះ ។

ឧក្រិដ្ឋកម្មគ្រឿងញៀនមានទំនោរខ្លាំងណាស់ក្នុងការបង្កើតទីផ្សារជារបស់ខ្លួនផ្ទាល់ ដោយយើងមិនអាចដឹងបានទេថាគេនឹងបង្កើតទីផ្សារនៅក្នុងប្រទេសណាមួយ។ គ្រឿងញៀនត្រូវបានគេនាំចេញ-នាំចូល ដូចនឹងផលិតផលប្រើប្រាស់នឹងអាហារនានាតែមួយផងដែរ។ គេចរាចរយ៉ាងរហ័សជុំវិញពិភពលោកតាមរបៀបល្បិចរៀបចំយ៉ាងខ្ពស់ ដោយទាយយកផលប្រយោជន៍ពីបច្ចេកវិទ្យាទំនើប ពីកង្វះខាតនៃចន្លោះប្រព័ន្ធច្បាប់ និងការខ្វះខាតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

បណ្តាលក្រុមឧក្រិដ្ឋកម្មគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំងល្បីៗដែលកំពុងមានការមរមាញឹកក្នុងការធ្វើសកម្មភាពខុសច្បាប់រួមមាន៖

- **ក្រុម ទ្រីត ( Triads ) របស់ចិន:** ជាក្រុមដែលធំជាងគេបង្អស់ក្នុងពិភពលោក មានសាខាជាង ១៦០ ក្រុមដែលមានសកម្មភាពភាគច្រើននៅក្នុងទីក្រុងហុងកុង ម៉ាការនិងតំបន់មួយចំនួនទៀតក្នុងប្រទេសចិន ។

- **ក្រុម ម៉ាហ្វៀល ( Mafia ) របស់អ៊ីតាលី:** ក្រុមនេះមានសាខាចំនួន ៦៦ក្រុមគិតត្រឹមឆ្នាំ ២០១៥នៅលើពិភពលោក ។ ក្រុមនេះមានឥទ្ធិពលខ្លាំងនឹងមហាសេដ្ឋីធំៗនៅលើសកលលោកជាពិសេសគឺនៅទ្វីបអឺរ៉ុបនិងកំពុងបន្តសកម្មភាពក្នុងសហរដ្ឋអាមេរិកផងដែរ ។
- **ក្រុម យ៉ាងកូហ្ស៊ា ឬ ក្បូរ្វកូដាន់( Yakusa ឬ Borvokudan ) របស់ជប៉ុន:** ជាក្រុមដែលមានឥទ្ធិពល ខ្លាំងនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ។ ជំនួយធំៗរបស់ក្រុមនេះគឺការជួញដូរគ្រឿងញៀន ការរត់ពន្ធមនុស្ស ការបោះពុម្ពសៀវភៅអាសអាភាស ការបើកបនល្បែង និងកន្លែងរកស៊ីដែលច្បាប់ហាមឃាត់ ។ ចំនែកទំនាក់ទំនងវិញក្រុមនេះមានការទាក់ទងនឹងក្រុមឧក្រឹដ្ឋជនចំនួន ១២ ប្រទេសដែលមាន កូរ៉េ ចិន(ហុងកុង) តៃវ៉ាន់ ហ្វីលីពីន ថៃ វៀតណាម ម៉ាឡេស៊ី ប្រេស៊ីល កាណាដា អាមេរិក និងអ៊ីរ៉ង់ ។
- **ក្រុម ខាតេល ( Cartels ) របស់កូឡុំប៊ី:** ក្រុមនេះមានឥទ្ធិពលនៅទ្វីបអាមេរិកនិងទទួលផ្ដាច់មុខនូវជំនួញគ្រឿងញៀនប្រភេទ អាភៀន កូកាអ៊ីន និងលុយក្លែងក្លាយ ។
- **ក្រុម ខាតេលទី២ ( Cartels Mixeco ) របស់មិចស៊ិចកូ:** ក្រុមនេះគឺបានបំបែកខ្លួនពីក្រុម ខាតេល ដំបូងរបស់កូឡុំប៊ីហើយជាក្រុមដែលបានធ្វើការផលិតនៅថ្នាំញៀនប្រភេទ អ៊ិចស្តាស៊ីដ៏ធំក្នុងលោក។ក្រុមនេះផងដែរក៏ទទួលខុសត្រូវលើទីផ្សារកូកាអ៊ីននៅសហរដ្ឋអាមេរិកកណ្ដាល ។
- **ក្រុម ឃុនសា ( Khun Sa ) របស់ភូមា:** ក្រុមនេះស្ថិតនៅអាស៊ីអាគ្នេយ៍ដែលជំនួយធំគឺការលក់អាភៀន ហេរ៉ូអ៊ីន និងអាវុធ ។
- **ក្រុម ឧទ្ទាមក្រហម របស់ភូមា:** ក្រុមនេះក៏ធ្វើការរកស៊ីដូចនឹងក្រុមឃុនសាដែរ ។
- **ក្រុម ឧក្រឹដ្ឋជន របស់អាហ្គានីស្ថាន:** ក្រុមនេះគឺមានការជួយដូរគ្រឿងញៀន អាវុធទំនើប និងការធ្វើភេរវកម្ម ។
- **ក្រុម ឧក្រឹដ្ឋជន របស់រុស្ស៊ី:** ក្រុមនេះគឺជាក្រុមចុងក្រោយពុំមានសាខាច្រើនពុំមានសមាជិកច្រើនតែក្រុមនេះពោពេញទៅដោយមនុស្សចេះដឹងខ្ពស់ ហើយមានឥទ្ធិពលគ្រប់ដណ្ដប់លើក្រុមឧក្រឹដ្ឋជនទាំងអស់ដែលបានរៀបរាប់នៅខាងលើ ។ ក្រុមនេះកើតឡើងក្រោយពីការដួលរលំនៃរបបកុម្មុយនិស្តសហភាពសូវៀត ដែលសមាជិកក្នុងក្រុមនេះភាគច្រើនសុទ្ធតែជាភ្នាក់ងារ កាហ្សេប៉េ ( K.G.B ) ដែលមានអាជីពខាងឧក្រឹដ្ឋកម្មកំរិតខ្ពស់។[22] ជំនួញដែលក្រុមនេះមានគឺការលក់នូវ បច្ចេកវិជ្ជាបរិមាណូ(អាវុធប្រល័យលោក) សារធាតុនុយក្លេអ៊ែរ រូបិយប័ណ្ណក្លែងក្លាយ ជួញដូរគ្រឿងញៀន និងរត់ពន្ធមនុស្ស ។

[២២] K.G.B គឺជាភ្នាក់ងារស៊ើបការដូចគ្នានឹងភ្នាក់ងារ F.B.I របស់អាមេរិកបច្ចុប្បន្ន

ការបង្ហាញខាងលើ បានចង្អុលអោយយើងឃើញច្បាស់ពី គ្រឿងញៀន និង ថ្នាំញៀន ដែលជាប់ទាក់ទិនជាមួយ នឹងអំពើឧក្រិដ្ឋកម្មវាពិតជាបញ្ហាមួយដែលធ្វើអោយច្បាប់អន្តរជាតិមានការពិបាកយ៉ាងខ្លាំងក្លាផងដែរ។[២៣]

### ខ. អំពីមធ្យោបាយនាំចេញ-នាំចូល

ក្នុងការនាំចេញ-នាំចូលនូវគ្រឿងញៀន ជាវិធីសំខាន់បំផុតដែលពួកឧក្រិដ្ឋជនត្រូវគិតមុខគេបង្អស់ក្នុងការចាត់ចែងនឹងដោះស្រាយបញ្ហាដែលកើតមានក្នុងការរារាំងជំនួញរបស់ពួកគេ ។ ហើយក្នុងពិភពលោកមានផ្លូវបីទិសដែលសំខាន់ៗសំរាប់ពួកឧក្រិដ្ឋជនប្រើប្រាស់ជាប្រចាំក្នុងការរត់ពន្ធ ។

ផ្លូវដឹកជញ្ជូនបីដែលសំខាន់ៗនោះរួមមានដូចជា៖

១-**ទិសប៉ែកខាងលិច:**ជាផ្លូវភ្ជាប់ប្រទេសមួយទៅប្រទេសមួយសំរាប់ពួកឧក្រិដ្ឋជនប្រើប្រាស់ក្នុងការនាំយកគ្រឿងញៀនឆ្លងកាត់ព្រំប្រទល់ ប្រទេសប៉ាគីស្ថាន/ប្រទេសអ៊ីរ៉ង់ និងព្រំប្រទល់នៃ ប្រទេសអាហ្វហ្គានីស្ថាន / ប្រទេសអ៊ីរ៉ង់ រួចពួកគេបន្តទៅប្រទេសតួគី មុនពេលដែលឆ្លងកាត់ផ្លូវបាល់កង់ ។

២-**ផ្លូវបាល់កង់:**នេះជាផ្លូវសំខាន់ដែលចាប់ភ្ជាប់ពីប្រទេសតួគីទៅនឹងទីក្រុងក្នុងអ៊ឺរ៉ុបកណ្តាលនិងអ៊ឺរ៉ុបខាងលិច សំរាប់ឧក្រិដ្ឋជនធ្វើការនាំចេញគ្រឿងញៀនទៅកាន់តំបន់នានា។ ផ្លូវនេះត្រូវបានកើតឡើងនៅពេលដែលអតីតប្រទេសយូហ្គោស្លាវីមានជម្លោះហើយគេកសាងផ្លូវនេះឡើងសំរាប់ធ្វើការដឹកជញ្ជូន ស្បៀងអាហារ ថ្នាំពេទ្យ នឹងទំនិញនានាទៅកាន់តំបន់ដែលមានជម្លោះនោះ ទើបក្រោយមកជម្លោះត្រូវបានបញ្ចប់ផ្លូវនេះក៏ក្លាយជាច្រកសំខាន់របស់ពួកឧក្រិដ្ឋជនតែម្តង ។

៣-**ទិសប៉ែកខាងកើតនិងខាងលិច:** ផ្លូវនេះស្ថិតនៅក្នុងប្រទេសអ៊ីរ៉ង់ តួគី និងអាស៊ីកណ្តាលចំនែកឯផ្លូវដែលស្ថិតនៅទិសខាងកើតនិងខាងត្បូងនៃប្រទេសប៉ាគីស្ថាន បានបន្តទៅប្រើប្រាស់ជាផ្លូវចរាចរយ៉ាងទូលំទូលាយជាពិសេសតាមផ្លូវអាកាស និងតាមផ្លូវសមុទ្រ ។[24]

ឧក្រិដ្ឋជនមានវិធីសាស្ត្រជាច្រើនក្នុងការដឹកជញ្ជូន សំរាប់សារធាតុដែលមានជាតិញៀនទៅកាន់ពិភពលោកជាពិសេសគឺ ផ្លូវគោកតែម្តង ។ ការដឹកជញ្ជូនតាមផ្លូវអាកាស រួមនិងការដឹកជញ្ជូនចំពោះសេវាប្រៃសណីយ៍នឹងផ្លូវរថភ្លើងក៏ត្រូវបានគេប្រើប្រាស់ជាញឹកញាប់ណាស់ដែរ។

---

[២៣] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

[២៤] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

ក្រុមដែលចាត់តាំងជួញដូរគ្រឿងញៀនសំខាន់ៗ បានប្រើប្រាស់នូវការវាយតម្លៃអំពីគ្រោះថ្នាក់ថាមានហានិភ័យដល់កំរិតណា ហើយពួកគេព្យាយាមរកនូវវិធីសាស្ត្រថ្មីដែលមានការប្រសប់មួយចំនួននៅពេលដែលវិធីសាស្ត្រមុនៗប្រើការលែងមានប្រសិទ្ធិភាព ។ ការកង្វះខាតក្នុងការអនុវត្តច្បាប់ ជាមូលហេតុដែលបានលើកទឹកចិត្តអោយមានការជួញដូរគ្រឿងញៀនមានការកើនឡើង ។ ដើម្បីប្រថុយប្រថាននឹងការដឹកជញ្ជូនដ៏ធំ ក្រុមពួកឧក្រិដ្ឋជនដែលមានការចាត់តាំងជាច្រើន ពិសេសក្រុមឧក្រិដ្ឋជនដែលស្ថិតនៅក្នុងទ្វីបអាហ្វ្រិក បានជួលអ្នកដឹកជញ្ជូនដែលមានការប្រសប់ក្នុងភាពដឹកជញ្ជូនគ្រឿងញៀនដោយការវេចខ្ចប់ ការលាក់ទុក ឬ ការលេបចូលក្នុងពោះតែម្តងដើម្បីឆ្លងកាត់ការត្រួតពិនិត្យ នៅតាមព្រលានយន្តហោះ ឬ កំពង់ផែសមុទ្រជាដើម ។

**កថាខណ្ឌទី ២ ស្ថានភាពណ៍គ្រឿងញៀនកម្ពុជា**

កម្ពុជា មិនមែនជាប្រទេសដែលមានការផលិតគ្រឿងញៀននោះទេ តែជាប្រទេសទទួលរងការហូរចូលគ្រឿងញៀនខុសច្បាប់ និង ប៉ុនប៉ងផលិតពីសំណាក់ពួកជនល្មើសគួរអោយមានការព្រួយបារម្ភដោយសារតែប្រព័ន្ធច្បាប់មិនទាន់មានភាពរឹងមាំ ធនធានមនុស្សនៅមានកំរិតទាប និងភាពក្រីក្រជាទូទៅរបស់ប្រជាពលរដ្ឋ ហើយទីតាំងភូមិសាស្ត្រកម្ពុជាស្ថិតនៅជិតតំបន់ដែលសំបូរទៅដោយគ្រឿងញៀនផងនោះ វាបានក្លាយទៅជាកត្តាធ្វើអោយកម្ពុជាក្លាយជាប្រទេសដែលមានការចរាចរឆ្លងកាត់ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គួរអោយកត់សំគាល់ ។

ខាងក្រោមនេះ នឹងបង្ហាញថាតើគ្រឿងញៀនត្រូវបានហូរចូលមកប្រទេសកម្ពុជាដោយរយៈវិធីអ្វី? ហើយមានការចរាចរយ៉ាងដូចម្តេច ?

**ក. ទីតាំងភូមិសាស្ត្រ**

ព្រះរាជាណាចក្រកម្ពុជាមានព្រំប្រទល់ប្រវែង២.៦០០គ.ម គឺព្រំប្រទល់ដីគោក ៥/៦ និងឆ្នេរសមុទ្រ១/៦ ដែលមានព្រំប្រទល់:

-ខាងជើង ជាប់និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

-ខាងកើត និង ខាងត្បូង ជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-ខាងលិច ជាប់ជាមួយព្រះរាជាណាចក្រថៃ និង ឈូងសមុទ្រថៃ ដែលមានឆ្នេរប្រវែង ៤៤០ គ.ម និងមានជម្រោមធ្យម ។

ក្នុងការចរាចរគ្រឿងញៀនភាគច្រើនចូលមកក្នុងប្រទេសកម្ពុជា គឺចេញពីតំបន់ដែលផលិតធំៗនៅនឹងជាប់ប្រទេសតែម្តងដែលគេអាចកំណត់ច្បាស់ បានថាមានតែប្រទេសពីរប៉ុណ្ណោះនោះគឺ

ប្រទេសថៃ នឹង ប្រទេសឡាវ ដែលជាប្រទេសមានការផលិតនូវគ្រឿងញៀនច្រើន ចំនែកឯប្រទេសវៀតណាមវិញមិនសូវមានការចរាចរចូលមកកម្ពុជានោះទេ ។

**ខ. ការចរាចរគ្រឿងញៀន**

រហូតមកទល់ពេលនេះ គ្រឿងញៀនខុសច្បាប់នៅតែបង្កបញ្ហាដ៏ស្មុគស្មាញ និងគ្រោះថ្នាក់ចំពោះសុខភាពមនុស្សជាតិ និងសន្តិសុខសណ្តាប់ធ្នាប់រួមនឹងការអភិវឌ្ឍន៍សង្គមនៃបណ្តាប្រទេសនានានៅលើសកលលោក ។ យោងតាមរបាយការណ៍គ្រឿងញៀនពិភពលោករបស់ការិយាល័យសហប្រជាជាតិទទួលបន្ទុកកិច្ចការគ្រឿងញៀន និងឧក្រិដ្ឋកម្ម (United Nations Office on Drugs and Crime) ដែលហៅកាត់ថា UNODC ក៏ដូចជារបាយការណ៍របស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ (International Narcotics Control Board) ដែលហៅកាត់ថា INCB ឆ្នាំ២០១០ និងឆ្នាំ២០១១ បានឱ្យដឹងថា ការដាំដុះ និងការផលិតគ្រឿងញៀនខុសច្បាប់ ពិសេសគ្រឿងញៀនសំយោគដូចជាអំហ្វេតាមីន មេតំ ហ្វេតាមីន និងអ៊ិចស្តាស៊ី នៅលើពិភពលោក ក៏ដូចជានៅក្នុងតំបន់អាស៊ីមានការកើនឡើងគួរឱ្យកត់សំគាល់ ។

កម្ពុជាបានទទួលរងនូវផលប៉ះពាល់ដោយសារគ្រឿងញៀនចាប់តាំងកំឡុងដើមឆ្នាំ ១៩៩០ ហើយកម្ពុជាត្រូវបានគេទទួលស្គាល់ថា ជាតំបន់ឆ្លងកាត់នៃការចរាចរគ្រឿងញៀនពីតំបន់ផលិតគ្រឿងញៀនទៅកាន់ប្រទេសជិតខាង និងបណ្តាប្រទេសមួយចំនួនទៀតទាំងនៅក្នុងនឹងក្រៅតំបន់ ។ ឆ្លងតាមលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននាពេលកន្លងមក គេកំណត់បានថាមុនឆ្នាំ២០០៣ ការចរាចរគ្រឿងញៀនខុសច្បាប់ចូលមកប្រទេសកម្ពុជា គឺធ្វើឡើងនៅតាមច្រកនានានៃបណ្តាខេត្តនៅភាគពាយ័ព្យនៃប្រទេស ប៉ុន្តែបន្ទាប់ពីឆ្នាំ២០១៣ ពិសេសបន្ទាប់រដ្ឋាភិបាលប្រទេសថៃបើកយុទ្ធនាការសង្គ្រាមប្រឆាំងគ្រឿងញៀននៅក្នុងប្រទេសរបស់ខ្លួនមក ការចរាចរគ្រឿងញៀនខុសច្បាប់របស់ក្រុមឧក្រិដ្ឋជនចូលមកកម្ពុជាភាគច្រើនបំផុតបានបង្វែរទិសដៅរបស់ខ្លួន ទៅកាន់ភាគឦសាននៃប្រទេសកម្ពុជាវិញ។ ហើយខេត្តចំនួន៣ ដែលរងនៅការចរាចរយ៉ាងខ្លាំងនោះគឺខេត្តព្រះវិហា ស្ទឹងត្រែង និងខេត្តរតនគីរីះ

-**ខេត្តព្រះវិហា៖** មានព្រំប្រទល់ជាប់នឹងសាធារណរដ្ឋប្រជាមាតិប្រជាធិបតេយ្យ ឡាវ ប្រវែង ១៩០ គីឡូម៉ែត្រ (ជាប់នឹងប្រទេសថៃ ១២៩ គីឡូមែត្រ) ។ ស្រុកដែលជាប់នឹងព្រំដែនឡាវរួមមានស្រុកឆែប ជាប់ព្រំប្រទល់ជាមួយនឹង ស្រុក មឿងប៊ុន និងស្រុក មឿងខូង នៃខេត្តចំប៉ាសាក់ ។ ស្រុកឆែប នៃខេត្តព្រះវិហា និងស្រុកមឿងប៊ុន និងស្រុកមឿងខូងនៃខេត្តចំប៉ាសាក់ មានបន្ទាត់ព្រំដែនខណ្ឌដោយទន្លេរពៅ ហើយមិនទាន់មានច្រកទ្វារជាផ្លូវការនៅឡើយ ។ ស្រុក ឆែប ពិសេសនៅ

តំបន់ជាប់គ្នានៃឃុំស្រឡៅ១ និងឃុំស្រឡៅ២ គឺតំបន់ដែលមានលក្ខណៈអំណោយផលសម្រាប់ជនល្មើសធ្វើសកម្មភាពចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ ។

**-ខេត្តស្ទឹងត្រែង៖** មានព្រំប្រទល់គោកប្រវែង ២៥៧ គីឡូមែត្រ និងព្រំប្រទល់ទឹកទន្លេមេគង្គ និងទន្លេសេកុង ។ ភូមិសាស្ត្រព្រំប្រទល់មានសភាពស្មុគស្មាញ ដែលជាលក្ខណៈអំណោយផលដល់ក្រុមឧក្រិដ្ឋជនក្នុងការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែន ពិសេសនៅតាមភូមិសាស្ត្រមួយចំនួននៃស្រុកថាឡាបរិវ៉ាត់ និង ស្រុកសៀមប៉ាង ដែលក្រុមឧក្រិដ្ឋជនអាចធ្វើការចរាចរគ្រឿងញៀនទាំងតាមផ្លូវគោក និងតាមផ្លូវទឹក ។

**-ខេត្តរតនគីរី៖** មានព្រំប្រទល់ជាប់នឹងប្រទេសឡាវប្រវែង ១៦៥ គីឡូមែត្រ និង ស្រុកជាប់ព្រំដែនចំនួន ២ គឺស្រុកវើនសៃ និងស្រុកតាវែង ប៉ុន្តែស្រុកទាំង ២ នេះ មិនអំណោយផលដល់ក្រុមឧក្រិដ្ឋជនឡើយ ។ តំបន់ដែលមានលក្ខណៈប្រឈម ហើយតែងមានការចរាចរគ្រឿងញៀនឆ្លងកាត់ពីសំណាក់ក្រុមឧក្រិដ្ឋជន គឺតំបន់ដែលមានភូមិសាស្ត្រជាប់នឹងស្រុកសៀមប៉ាងនៃខេត្តស្ទឹងត្រែង ។

ផ្លូវទាំងបីខាងលើនេះត្រូវបានពួកជនល្មើសបានប្រើប្រាស់ជាប្រចាំ ហើយពួកគេបានប្រើប្រាស់នូវមធ្យោបាយនានាដែលរួមមានទាំងបច្ចេកទេសទំនើបក្នុងការដឹកជញ្ជូនផងដែលទោះបីត្រូវបានសមត្ថកិច្ចមូលដ្ឋានបង្ក្រាបយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមានសកម្មភាពជាហូរហែរមិនដាច់សោះឡើយ។[២៥]

### គ. ការប្រើបំពានគ្រឿងញៀន

តាមការកត់សំគល់នានាកន្លងមកនេះ អ្នកប្រើប្រាស់គ្រឿងញៀនខុសច្បាប់ភាគច្រើនបំផុតគឺជាយុវវ័យ ដែលមានអាយុចាប់ពីចន្លោះ ១៨ឆ្នាំ ទៅ ២៨ឆ្នាំ ដែលមានប្រមាណជា ១២.០០០នាក់ ទៅ ២៨.០០០នាក់ ដែលជាលិទ្ធផលប៉ាន់ប្រមាណរបស់មន្ត្រីអនុវត្តច្បាប់គ្រឿងញៀនបានវាយតម្លៃក្នុងឆ្នាំ២០១២ ប៉ុន្តែការប៉ាន់ស្មានពីចំនួនអ្នកប្រើគ្រឿងញៀន និងអ្នកចាក់គ្រឿងញៀនៅក្នុងប្រទេសកម្ពុជានេះ គឺនៅមានកម្រិតដោយសារកង្វះប្រភពទិន្នន័យដែលអាចទុកចិត្តបាន ។

នេះជាប្រភេទគ្រឿងញៀនដែលគេបានប្រើប្រាស់ក្នុងប្រទេសកម្ពុជា ៖

- មេតំហ្វេតាមីនគ្រប់ ឬ ហៅថា យ៉ាបា យ៉ាម៉ា (ពេញនិយមនៅកម្ពុជា)
- មេតំហ្វេតាមីនអាយ ឬ ហៅថា ម៉ាទឹកកក
- ហេរ៉ូអ៊ីនប្រភេទជាម្សៅ

[២៥] បញ្ហាគ្រឿងញៀន និង គោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាល

- អ៊ិចស្តាស៊ី ឬ ថ្នាំសម្រើប ឬ ថ្នាំឆ្កួត
- កញ្ឆា (ទាំង ស្រស់ ស្ងួត នឹង ក្រៀម)
- អាភៀន (ទាំងជ័រស្រស់ នឹង សំយោគ) ។

ដោយឡែកអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៣ដល់២០១៣ ច្រើនតែប្រើប្រាស់នូវគ្រឿងញៀនប្រភេទសំយោគ មេតំហ្វេតាមីន ហើយពួកគេទាំងអស់នោះច្រើនតែប្រើប្រាស់វាដោយការ "ជក់"។[២៦] ប៉ុន្តែបើតាមរបាយការណ៍ថ្មីៗនៃ អ.ជ.ប.គ.ញ បានបង្ហាញថាការប្រើប្រាស់នូវគ្រឿងញៀនប្រភេទ ហេរ៉ូអ៊ីន មានការកើនឡើងដែលនឹកស្មានមិនដល់ហើយវាជាប្រភេទគ្រឿងញៀនចុងក្រោយបង្អស់ដែលគេបានប្រទះ ។ ការប្រើប្រាស់នូវ ហេរ៉ូអ៊ីន គឺប្រើដោយតាមរយៈការ ចាក់[២៧] បញ្ចូលទៅក្នុងសារពាង្គកាយដែលដំបូងឡើងការចាក់នេះត្រូវបានគេសន្មត់ថាមានតែក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នវិធីនេះបានរីករាលដាលទៅដល់ ខេត្ត ក្រុងនានា និងទីប្រជុំជនសំខាន់ៗមួយចំនួនទៅហើយ ។

## ផ្នែកទី២ គោលដៅនៃការត្រួតពិនិត្យ

នៅពេលអនុវត្តអំណាចនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ គេបានកំណត់ទីតាំងនៃដែនតំបន់នានាដែលត្រូវត្រួតពិនិត្យ នឹងការខិតខំស្វែងរកនូវមធ្យោបាយ គំនិតការពារ រួមទាំងឧបករណ៍បរិក្ខាប្រើប្រាស់ទំនើបៗ ដើម្បីជារបងការពារនិងអនុវត្តច្បាប់អោយមានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយការប្រើប្រាស់ខុសច្បាប់ លុបបំបាត់បទល្មើសជួញដូរ និងពិសេសគឺទប់ស្កាត់នូវការហូរចូលគ្រឿងញៀនមកកាន់ប្រទេសកម្ពុជា ។

### កថាខណ្ឌទី ១ សកម្មភាពក្នុងការត្រួតពិនិត្យ

ក្នុងការអនុវត្តសកម្មភាពត្រួតពិនិត្យគ្រឿងញៀន គេបានចែកតំបន់ជាបីដែលត្រូវកំនត់ក្នុងការត្រួតពិនិត្យដែលមានបង្ហាញនៅខាងក្រោមនេះដូចជា៖

#### ក. ដែនគោក

មន្ត្រីអនុវត្តច្បាប់ បានខិតខំកាត់បន្ថយនិងទប់ស្កាត់យ៉ាងខ្លាំងក្នុងការ ចរាចរ ការជួញដូរ ការរត់ពន្ធ និងការប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀនគ្រប់ប្រភេទដែលមានការក្នុងតំបន់នានាដែលខ្លួនបានគ្រប់គ្រង ។ ការប្រព្រឹត្តបទល្មើសគ្រឿងញៀន ត្រូវបានគេលួចលាក់យ៉ាងខ្លាំងទោះមានការបង្ក្រាបពីសមត្ថកិច្ចយ៉ាងណាក៏ដោយការ អ្នកប្រើប្រាស់នឹងពួកជនល្មើសរត់ពន្ធនៅតែខ្លាចដដែល។

[២៦] ការជក់: គ្រឿងញៀនប្រភេទនេះគេធ្វើតាមការដុតយកផ្សែង ឬ ហឺតចូលតាមច្រមុះដែលមានបង្ហាញក្នុងឧបសម្ព័ន្ធទី២

[២៧] ការចាក់: គ្រឿងញៀនប្រភេទនេះគេចាក់វាតាមរូបភាព ក្រោមស្បែក សាច់ដុំ និងសរសៃវ៉ែន(សរសៃឈាមមនុស្ស) ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធទី២

ដោយសារតែរបៀបនេះហើយទើប អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានព្យាយាមមានទំនាក់ទំនងអោយកាន់តែល្អជាមួយនិងសមត្ថកិច្ចមូលដ្ឋាននិងតាមតំបន់ព្រំដែនក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសដែលនឹងកើតមានឡើង ។ ហើយគោលដៅដែលបានកំណត់ទុកនោះរួមមាន តំបន់ប្រជុំជន និង តំបន់ជាប់ព្រំដែន ។

### ១.តំបន់ប្រជុំជន

តំបន់ប្រជុំជនគឺ សំដៅលើតំបន់ដែលភាគច្រើនមានការប្រើប្រាស់មិនមែនការរត់ពន្ធ ដែលមានដូច ទីក្រុង តំបន់មនុស្សរស់នៅច្រើន តំបន់ដែលមានសេដ្ឋកិច្ចខ្ពស់ ព្រោះតំបន់ទាំងនេះនឹងធ្វើអោយការប្រើប្រាស់គ្រឿងញៀនមានសំទុះកើនឡើងពីតិចទៅច្រើន ជាហេតុដែលអ្នកលក់គ្រឿងញៀនតូចតាចអាចរកកម្រៃបានច្រើន និងមានទីផ្សារធំទូលាយសំរាប់ពួកគេ ។

ក្នុងការគ្រប់គ្រងតំបន់ដែកគោកសមត្ថកិច្ចអនុវត្តច្បាប់ដែលមាននាទីសំខាន់មានដូចជា៖

-កងកម្លាំងនៃនគរបាល ( ខេត្ត - ក្រុង និង មូលដ្ឋាន )

-កងកម្លាំងនៃរាជអាវុធហត្ថ ( ខេត្ត - ក្រុង និង មូលដ្ឋាន )

-កងកម្លាំងនៃយោធា ( ករណីមានការចាំបាច់ )

-កងកម្លាំងនៃកងអន្តរាគមន៍

-មេឃុំ-ចៅសង្កាត់

-រួមនិងការសហការនៃប្រជាពលរដ្ឋតាមមូលដ្ឋាន ។

### ២. តំបន់ជាប់ព្រំដែន

ក្នុងការទប់ស្កាត់ការហូរចូលនូវគ្រឿងញៀនតាមព្រំដែន គេមិនអាចពឹងផ្អែកសុទ្ធសាធទៅលើកម្លាំងប្រដាប់អាវុធ និង យោធានានាដែលនៅក្នុងមូលដ្ឋាននោះទាំងអស់បានទេ ព្រោះដោយហេតុថាការគ្រប់គ្រងនៅតំបន់ជាប់ព្រំដែននៅមានភាពធូរលង់នៅឡើយ ។ ដើម្បីធានាអោយបាននូវសុវត្ថិភាពខ្ពស់ជាងមុនក្នុងការបង្ក្រាបបទល្មើស អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្កើតនូវ ការិយាល័យទំនាក់ទំនងព្រំដែន **( Border Liaison Office )** ដែលហៅកាត់ថា **BLO** នៅក្នុងខេត្តជាប់តំបន់ព្រំប្រទល់រវាងកម្ពុជា និងប្រទេសជិតខាង។ ការិយាល័យនេះជាការិយាល័យទំនាក់ទំនងព្រំដែននេះបានក៏កើតឡើងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ក្រោមការចុះហត្ថលេខារបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយមានភារកិច្ចសហការជាមួយការិយាល័យទំនាក់ទំនងព្រំដែនរបស់ប្រទេសជាប់ព្រំដែន និងមន្ត្រីអនុវត្តច្បាប់ទាំងអស់ ក្នុងការផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមកក្នុងការបង្ការដើម្បីទប់ស្កាត់ និងបង្ក្រាបការចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំខុសច្បាប់នានា ។

ការិយាល័យទំនាក់ទំនងព្រំដែន មានសមាសភាពគ្រប់គ្រងដូចខាងក្រោមៈ

| | |
|---|---|
| -អភិបាលរងខេត្ត | ប្រធាន |
| -ស្នងការរងនគរបាលខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| -ប្រធានប៉ុស្តអន្តរជាតិ | អនុប្រធាន |
| -អភិបាលស្រុកជាប់ព្រំដែន | សមាជិក |
| -ប្រធានក្រុមមន្ទីរប្រឆាំងគ្រឿងញៀន | សមាជិក |
| -មេបញ្ជាការវរៈនគរបាលព្រំដែន | សមាជិក |
| -នាយសេនាធិការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| -ប្រធានស្នាក់ការគយនិងរដ្ឋាករខេត្ត | សមាជិក |
| -ប្រធានស្នាក់ការកាំកុងត្រូលខេត្ត | សមាជិក ។ |

ឧទាហរណ៍ជាក់ស្តែងៈ កំលាំងសមត្ថកិច្ចការិយាល័យទំនាក់ទំនងព្រំដែន ប្រចាំខេត្តស្ទឹងត្រែង នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៨ បានធ្វើការបង្រ្កាបករណីលួចរត់ពន្ធគ្រឿងញៀនពីប្រទេសឡាវ ចូលមកកាន់កម្ពុជាដោយរថយន្តតាមច្រករបៀង ។ ដែលក្នុងករណីនេះគេបានចាប់ជនល្មើសបាន១នាក់ និងគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន ចំនួន ១៧.៣៩៩គ្រប់ ដែលគិតជាទឹកប្រាក់ប្រមាណជាជិត ១សែនដុល្លារអាមេរិក។

ដោយឡែកនៅទូទាំងប្រទេសកម្ពុជា ការិយាល័យទំនាក់ទំនងព្រំដែនមានចំនួន ១៤កន្លែង ដែលមាននៅជាប់នឹងប្រទេស ៣ គឺ ប្រទេសថៃ ប្រទេសវៀតណាម និង ប្រទេសឡាវ ៖

១- ច្រក បាវិត ( ខេត្តស្វាយរៀង ) ជាប់និង ច្រក ម៉ុកប៉ៃ (ខេត្តតៃនីញ វៀតណាម)

២- ច្រក ភ្នមសំណា ( ខេត្តកណ្តាល ) ជាប់និង ច្រក វិនសឿន (ខេត្តអាងយ៉ាង វៀតណាម)

៣- ច្រក ជ្រៃធំ ( ខេត្តកណ្តាល ) ជាប់និង ច្រក កាន់បៀន (ខេត្តអាងយ៉ាង វៀតណាម)

៤- ច្រក ភ្នំដិន ( ខេត្តតាកែវ ) ជាប់និង ច្រក របៀង (ខេត្តអាងយ៉ាង វៀតណាម)

៥- ច្រក ត្រពាំងផ្លុង ( ខេត្តត្បូងឃ្មុំ ) ជាប់និង ច្រក របៀង (ខេត្តអាងយ៉ាង វៀតណាម)

៦- ច្រក ចាំយាម ( ខេត្តកោះកុង ) ជាប់និង ច្រក ខ្លងយៃ (ខេត្តត្រាត ថៃ)

៧- ច្រក ប៉ោយប៉ែត ( ខេត្តបន្ទាយមានជ័យ ) ជាប់និង ច្រក អារញ្ញ (ខេត្តស្រះកែវ ថៃ)

៨- ច្រក ព្រំ ( ខេត្តប៉ៃលិន ) ជាប់និង ច្រក បាងផាកាន (ខេត្តចាន់ថៈបុរី ថៃ)

៩- ច្រក ដូង ( ខេត្តបាត់ដំបង ) ជាប់និង ច្រក បាងផាកាន (ខេត្តចាន់ថៈបុរី ថៃ)

១០- ច្រក អូរស្មាច់ ( ខេត្តឧត្តរមានជ័យ ) ជាប់និង ច្រក ស៊ីសាកេត ( ថៃ )

១១- ច្រក ជាំ ( ខេត្តឧត្តរមានជ័យ ) ជាប់និង ច្រក កាប់ឆឹន ( ថៃ )

១២- ច្រក ព្រះវិហារ ( ខេត្តព្រះវិហារ ) ជាប់ជាមួយនិង ខេត្ត អ៊ូប៊ុន ( ថៃ )

១៣- ច្រក ដុងក្រឡ ( ខេត្តស្ទឹងត្រែង ) ជាប់និង ច្រក វើនខាំ (ខេត្តចំម្ប៉ាសាក់ ឡាវ)

១៤- ច្រក ឈើទាលធំ ( ខេត្តស្ទឹងត្រែង ) ជាប់និង ច្រក វើនខាំ (ខេត្តចំម្ប៉ាសាក់ ឡាវ) ។[២៨]

**ខ. ដែនទឹក**

ការរត់ពន្ធគ្រឿងញៀនចូលមកក្នុងប្រទេសកម្ពុជាដោយជ្រើសរើសយកផ្លូវទឹក វាជាជម្រើសមធ្យោបាយដ៏សំខាន់សំរាប់ពួកឧក្រឹដ្ឋជនក្នុងការដឹកជញ្ជូន ដោយមានទាំងលំហសមុទ្រ ផ្លូវទឹកសាបនៃទន្លេមេគង្គជាដើម ដោយផ្លូវនេះបានកាត់បន្ថយនូវគ្រោះថ្នាក់ក្នុងការចាប់ខ្លួនរបស់អំណាចច្បាប់លើពួកគេដែលមានសមត្ថកិច្ចជាអ្នកអនុវត្តន៍ច្បាប់ ។ កម្ពុជាពិតជាពិបាកទប់ស្កាត់ខ្លាំងណាស់ក្នុងការរត់ពន្ធគ្រឿងញៀនតាមផ្លូវទឹកនេះ ទោះបីយើងមានសមត្ថកិច្ចដូចជា កងនាវាចរខេមរភូមិន្ទនៃដែនសមុទ្រ, កងនាវាចរខេមរភូមិន្ទកងនៃមូលដ្ឋានដែនទន្លេ , ស្នាក់ការសាខាគយ-រដ្ឋាករ និងប្រធាន ឬ តំណាងមន្ទីរជំនាញចំណុះនានា ក្នុងការដោះស្រាយបញ្ហានេះក៏ដោយ ប៉ុន្តែការតាមដាននិងត្រួតពិនិត្យនៅតែមានភាពមិនទាន់គ្រប់ជ្រុងជ្រោយ ។

ការដឹកគ្រឿងញៀនតាមផ្លូវទឹកភាគច្រើនត្រូវបានគេប្រើប្រាស់វិធីផ្សេងៗ ដើម្បីជាការបង្វែរដានជម្លៀសកុំអោយមានការសង្ស័យពីអ្នកត្រួតពិនិត្យ ដែលមានវិធីសាស្ត្រខ្លះសមត្ថកិច្ចបានដឹងមានដូចជា៖

- លាក់នូវក្នុង កាណូត ឬ នាវាដឹកទំនិញ
- បង្កប់ក្នុងទំនិញដែលបញ្ជូនមក
- បង្កប់ក្នុងគ្រឿងរថយន្តដែលដឹកមក
- បង្កប់ក្នុងទូ កុងទីន័រ ដែលមានសម្ភារៈច្រើន ។ល។

មួយវិញទៀត ពួកឧក្រឹដ្ឋជនជ្រើសរើសយកផ្លូវទឹកដោយហេតុថា ដែននៃផ្ទៃទឹកមានវិសាលភាពធំធេងខ្លាំងណាសដែលពិបាកនិងគ្រប់គ្រង ដែលជាឪកាសសំរាប់ពួកគេធ្វើការជួបគ្នា ក្នុងការពិភាក្សារជួញដូរនៅទីនោះ ។ ទោះបីមានការពិបាកនិងគ្រប់គ្រងសភាពការណ៍យ៉ាងណាក្តីក៏ការអនុវត្តច្បាប់ និងការបង្រ្កាបរបស់សមត្ថកិច្ចមានកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជានៅតែមានភាពជោគជ័យជាបន្តបន្ទាប់ ។

ឧទាហរណ៍ជាក់ស្តែង៖ ករណីក្នុងការបង្រ្កាបការរត់ពន្ធគ្រឿងញៀន មកក្នុងប្រទេសកម្ពុជាតាមច្រកកំពង់ផែស្វយ័ត កំពង់សោម (លេខ៣៧២ ចាប់ថ្ងៃ១៥ ខែកក្កដា ឆ្នាំ២០១២) ជាករណីដែល

[២៨] រូបភាពមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

កម្ពុជារកឃើញ និងបង្ក្រាបដោយខ្លួនឯងដោយនៅក្នុងនោះ ឃាត់ខ្លួន ជនល្មើសចំនួន ២០ នាក់ ក្នុងនោះមានជនជាតិចិន ៣នាក់ ថៃ ១នាក់ និងកម្មករខ្មែរចំនួន ១៤ នាក់ ។ រឹបអូសបានសារធាតុគីមីចំនួនជិត ៦ តោន ។[២៩]

**គ. ដែនអាកាស**

ការដឹកជញ្ជូនគ្រឿងញៀនតាមផ្លូវអាកាសតាមអាកាសយានដ្ឋានគឺជាផ្លូវមួយដ៏សំខាន់បំផុតរបស់ជនល្មើស ក្នុងការប្រើប្រាស់ជាមធ្យោបាយតែមួយគត់ក្នុងការឆ្លងតំបន់សំរាប់ធ្វើការដឹកជញ្ជូនគ្រឿងញៀនទៅកាន់ប្រទេសនានាក្នុងសកលលោក ។ ចំនែកឯកម្ពុជាវិញដោយសារតែជាប្រទេសកំពុងអភិវឌ្ឍន៍ យើងមានអាកាសដ្ឋានសំរាប់អន្តរជាតិចំនួន ៣ ដែលមានដូចជា៖

១- អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៃ រាជធានីភ្នំពេញ

២- អាកាសយានដ្ឋានអន្តរជាតិសៀមរាម នៃ ខេត្តសៀមរាម

៣- អាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ នៃ ខេត្តព្រះសីហនុ ( កំពង់សោម ) ។

អាកាសយានដ្ឋានទាំងបីខាងលើនេះ មានតែអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមួយប៉ុណ្ណោះដែលត្រូវបានពួកជនល្មើសប្រើប្រាស់ជាមធ្យោបាយ សំរាប់ដឹកជញ្ជូនគ្រឿងញៀនទៅកាន់តំបន់ខាងក្រៅ ។ ក្នុងការដឹកជញ្ជូននេះផងដែរពួកជនល្មើសមានការប្រុងប្រយ័ត្នខ្លាំងណាស់ក្នុងការលាក់ទុកនូវគ្រឿងញៀនដែលធ្វើអោយមន្ត្រីសមត្ថកិច្ចមានការពិបាកតាមដាន និងមើលដឹងអំពីការលួចលាក់ទុករបស់ពួកគេដែលមានការបង្កប់ក្នុងរបស់ជាច្រើនដូចជា ៖

-លាក់ក្នុងបាតនៃស្បែកជើង ឬ កេះនៃផ្លែឈើ ឬ ក្នុងផ្លែឈើតែម្តង

-លាក់ទុកក្នុងសុតមាន់ សុតទា ឬ កញ្ចប់ភេសជ្ជះ

-លាក់ទុកក្នុងរូបតុក្កតា ឬ រូបបដិមាក

-លាក់ទុកក្នុងប្រអប់អាហារ ស្ករគ្រាប់ ឬ គ្រាប់ធុញជាតិ ( ឧ.ទា គ្រាប់ឈូក.សណ្តែកដី...)

-បង្កប់ក្នុងម៉ាស៊ីនទូរស័ព្ទ កាំម៉េរ៉ា ។ល។

ក្នុងការគ្រប់គ្រង និងទប់ស្កាត់ការពារការកើតឡើងនៃការដឹកជញ្ជូនគ្រឿងញៀនតាមផ្លូវអាកាសនេះសមត្ថកិច្ចអនុវត្តច្បាប់ដែលនាទីសំខាន់មានដូចជា៖

- មន្ត្រី និង កងកម្លាំងសន្តិសុខអាកាសចរណ៍ស៊ីវិល
- មន្ត្រី និង កងកម្លាំងនៃមន្ទីប្រឆាំងគ្រឿងញៀន
- កងកម្លាំងនៃនគរបាល ( ខេត្ត - ក្រុង និង មូលដ្ឋាន )

---

[២៩] រូបភាពមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

- កងកម្លាំងនៃរាជអាវុធហត្ថ ( ខេត្ត - ក្រុង និង មូលដ្ឋាន )
- កងកម្លាំងនៃយោធា ( ករណីមានការចាំបាច់ )
- មេឃុំ-ចៅសង្កាត់
- រួមនិងការសហការនៃប្រជាពលរដ្ឋ ។

ឧទាហរណ៍ជាក់ស្តែង៖ មន្ត្រីនិងកងកម្លាំងសន្តិសុខអាកាសចរណ៍ស៊ីវិលរួមទាំងមន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយការិយាល័យគយនិងរដ្ឋករ កាលពីថ្ងៃទី ១២-០២-២០១៤ បានបង្រ្កាបករណីដឹកជញ្ជូន នូវសារធាតុញៀនឆ្លងដែនខុសច្បាប់ តាមព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យស្ត្រីជនជាតិហ្វីលីពីន ១នាក់ និងបានរឹបអូសគ្រឿងញៀនកូកាអ៊ីនទម្ងន់ ២៥១៣ក្រាម ។ បន្ទាប់ពីបានអនុវត្តនីតិវិធីប្រគល់ដោយមានការឃ្លាំមើល ជនសង្ស័យចំនួន ៣នាក់ទៀត ត្រូវបានឃាត់ខ្លួនរួមមានបុរសជនជាតិនីហ្សេរីយ៉ាចំនួន ២នាក់ និងស្ត្រីជនជាតិខ្មែរចំនួន ១នាក់។[៣០]

### កថាខណ្ឌទី ២ មធ្យោបាយក្នុងការត្រួតពិនិត្យ

បទល្មើសគ្រឿងញៀនជាបទល្មើសពិសេស វាមានលក្ខិណៈខុសពីបទល្មើសចរាចរណ៍ បទល្មើសព្រហ្មទណ្ឌ និងបទល្មើសនានាទៀតត្រង់ថាបទល្មើសនេះមិនមានអ្នករងគ្រោះនោះទេក៏មិនមានករណីណាមួយដែលជនល្មើសមកប្តឹងសមត្ថកិច្ចនោះដែរ ព្រោះអ្នកជួញដូរក្តី អ្នកប្រើប្រាស់ក្តី ឬ អ្នករក្សាទុកក្តី សុទ្ធតែជាជនល្មើសដែលខុសនិងច្បាប់កំនត់ ។ ដោយហេតុនេះហើយទើបការកើតឡើងនៃបទល្មើសគ្រឿងញៀនមានសភាពក្នុងទីអាថកំបាំង មិនសូវបង្ហាញជាសាធារណៈនោះទេ ហើយនេះក៏ជាកត្តាធ្វើអោយមន្ត្រីសមត្ថកិច្ចពិបាកនឹងបង្រ្កាប ទប់ស្កាត់នឹងកាត់បន្ថយ ក៏ដូចជាតាមរកទីកន្លែងនៃជនល្មើសអោយជាក់លាក់ច្បាស់លាស់នោះដែរ ។ ដូច្នេះហើយមានតែមធ្យោបាយពីរប៉ុណ្ណោះដែរប្រើការណ៍ជាគោលក្នុងការអនុវត្តន៏ច្បាប់បានគឺការពឹងផ្អែកលើពត៏មានដែលបានមកពីការស៊ើបអង្កេតជាក់លាក់ និងតាមការប្រើប្រាស់នូវឧបករណ៍ទំនើបវិទ្យាក្នុងការតាមដានការលាក់កំបាំងរបស់ពួកឧក្រឹដ្ឋជន ។

#### ក. តាមព័ត៌មានជាក់លាក់

ព័ត៌មាននៃបទល្មើសគ្រឿងញៀន ជាកត្តាដែលសំខាន់ដែលនាំអោយសមត្ថកិច្ចអនុវត្តន៏ច្បាប់ឈានទៅដល់ការឆែកឆេរ និងបង្រ្កាបអំពើខុសច្បាប់នានាដែលពាក់ពន្ធជាមួយគ្រឿងញៀនថ្នាំញៀន សារធាតុគីមី ដែលបានចរាចរចែកចាយជួញដូរ និងប្រើប្រាស់ក្នុងប្រទេស ។ ក្នុងការ

[៣០] រូបភាពមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

ទទួលព័ត៌មាននិងតាមដាមព័ត៌មាននៃគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្កើតនូវ **មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន** ដែលហៅជាភាសាបទេសថា **Drug Information Centre Development** នឹងហៅកាត់ថា **DIC** ។[៣១]

មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀននេះបានបង្កើតឡើងដោយប្រកាសលេខ ០០១/០៥ប្រ.ក អ.ជ.ប.គ.ញ នៅថ្ងៃ ទី៣០ ខែមករា ឆ្នាំ២០០៥[៣២] ក្រោមការចុះហត្ថលេខាដោយផ្ទាល់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់របស់អគ្គលេខាធិការ គ្រប់គ្រងដោយមាន ប្រធាន ១រូប និងអនុប្រធាន ២រូបជាជំនួយការនិងមាន៣ផ្នែកសំរាប់ធ្វើការដាច់ពីគ្នារួមមាន ផ្នែករដ្ឋបាលនិងទិន្នន័យ ផ្នែកសេវាបច្ចេកទេសព័ត៌មានវិទ្យា និងចុងក្រោយផ្នែកអង្កេតនិងធ្វើស្ថិតិគ្រឿងញៀន ហើយមានតួនាទីសំខាន់ក្នុងការអនុវត្តដូចជា៖

- ធ្វើជាមជ្ឈមណ្ឌលក្នុងការប្រមូល ចងក្រង វិភាគ និងរក្សាទុក និងផ្តល់ព័ត៌ជាក់លាក់ នូវព័ត៌មានគ្រឿងញៀន គ្រប់ប្រភេទសំដៅជំរុញឲ្យកម្ពុជាមានទិន្នន័យគ្រប់គ្រាន់ស្តីពីបញ្ហាគ្រឿងញៀន ទៅគ្រប់មជ្ឈដ្ឋាន ។
- ជំរុញលើកកំពស់ការអនុវត្តការងារ ប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀនដោយប្រើប្រាស់បច្ចេកទេសព័ត៌មានវិទ្យាឲ្យបានសមស្របដល់បណ្តាគ្រប់អង្គភាពទាំងអស់ សំដៅធ្វើឲ្យទិន្នន័យដែលទទួលបានមានលក្ខណៈវិទ្យាសាស្ត្រនិងទាន់ពេលវេលានិងត្រឹមត្រូវ ។
- វាយតម្លៃសភាពការណ៍គ្រឿងញៀននៅក្នុង និងក្រៅប្រទេសដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ ដែលជាប្រមុខការងារ ។
- គ្រប់គ្រងបច្ចេកទេសលើការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបញ្ជូននិងផ្ញើសារ តាមប្រព័ន្ធអេឡិចត្រូនិច ។
- រៀបចំនិងគ្រប់គ្រងគេហទំព័ររបស់ អ.ជ.គ.ប.ញ ដើម្បីផ្តល់ព័ត៌មានទៅមហាជន ។
- សហការជាមួយជំនាញការ និងអង្គការពាក់ព័ន្ធក្នុងការធ្វើអង្កេតរកទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀននិងទិន្នន័យនានាពាក់ព័ន្ធនឹងគ្រឿងញៀន ព្រមទាំងរៀបចំនីតិវិធីក្នុងការប្រមូល ចងក្រង វិភាគ និងរក្សាទុកនូវទិន្នន័យព័ត៌មានគ្រឿងញៀន ។

---

[៣១] មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

[៣២] មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

- រៀបចំរបាយការណ៍ស្តីពីទិន្នន័យព័ត៌មានគ្រឿងញៀនខុសច្បាប់ប្រចាំឆ្នាំ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ប្រមូលទិន្នន័យព័ត៌មានពីគ្រប់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត គ្រប់ស្ថាប័នអនុវត្តច្បាប់នៅគ្រប់មណ្ឌលអប់រំ បន្សាបគ្រឿងញៀន (រដ្ឋ ឯកជន) និងទីកន្លែងនានាដែលពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មជួយដល់អ្នកញៀនគ្រឿងញៀន ។

ក្រៅពីការផ្តល់ព័ត៌មានពីមជ្ឈមណ្ឌលគ្រឿងញៀនគេក៏នៅមានការតាមដាន និងសិក្សារអំពីសភាពការណ៍ក្នុងប្រទេសផងដែរដោយប្រើក្នុងរូប ៖

- ប្រើប្រាស់ជនសើបអង្កេតក្នុងការតាមដានទីតាំង
- ទិញទឹកចិត្តអ្នកប្រើប្រាស់អោយធ្វើជាបណ្តាញស៊ើបការ
- ព័ត៌មានដែលបានពីប្រជាជនតាមតំបន់រាយការណ៍
- ព័តិមានដែលបានមកពីការសហការណ៍គ្នាពីបណ្តាលប្រទេសជិតខាង កម្ពុជា-ថៃ កម្ពុជា-វៀតណា កម្ពុជា-ឡាវ ។ល។

### ខ. តាមឧបករណ៍ទំនើប

ការពិនិត្យដោយភ្នែកទទេ ការស្រូបក្លិន ឬ ការអង្កេតមើលនូវអាកប្បកិរិយានៃទង្វើររបស់ជនល្មើសគ្រឿងញៀនដោយសំណាក់មន្ត្រីអនុវត្តច្បាប់ ពេលខ្លះវាពុំអាចមានប្រសិទ្ធភាពខ្ពស់នៅក្នុងការតាមចាប់សញ្ញាអោយដឹងថា ពួកគេមានការលាក់ទុក ការជួញដូរ ឬ ក៏ប្រើប្រាស់ដោយខុសច្បាប់បាននោះទេ ព្រោះភាគច្រើននៃជនល្មើសទាំងនោះមានភាពប្រសព្វខ្លាំងណាស់ក្នុងការបំភាន់ភ្នែករបស់មន្ត្រីអនុវត្តច្បាប់ក្នុងការទប់ស្កាត់ និងបង្ក្រាប ។ ក្នុងការរត់ពន្ធគ្រឿងញៀនពួកឧក្រឹដ្ឋជនមានការគិតខ្ពស់ខ្លាំងណាស់ ដោយពួកគេបានខិតខំរកវិធីសាស្ត្រយ៉ាងណាអាចគេចពីការសង្ស័យរបស់សមត្ថកិច្ច ដោយពួកតាមការបំលែងគ្រឿងញៀនទៅជា ថ្នាំឧសថ(ថ្នាំផ្តាសាយ ឬ ថ្នាំបំបាត់ការឈឺចាប់)[៣៣] រួចដាក់វាចូលក្នុងកំប៉ុងថ្នាំដែលច្បាប់អនុញ្ញាត ឬចម្រាញ់វាជាប្រេង ឬ វត្ថុអ្វីផ្សេង ។ ចំនែកឯអ្នកប្រើប្រាស់វិញក៏គេមិនអាចកំណត់ដោយការស្មានបាននោះដែរ ព្រោះអ្នកប្រើប្រាស់គ្រឿងញៀនក្នុងដំណាក់កាលដំបូងបំផុត ភាគច្រើនពុំមានចេញសញ្ញាណាដែលគួរអោយសង្ស័យនោះទេ ហេតុនេះទើបយើងចាំបាច់ត្រូវតែមានឧបករណ៍ទំនើបវិទ្យាជារបស់ជំនួយក្នុងការកំណត់គោលដៅនៃជនល្មើសទាំងនោះបាន ហើយឧបករណ៍ទាំងនោះអាចមានដូចជា៖

- ឧបករណ៍ពិនិត្យទឹកនោម (សំរាប់អ្នកប្រើប្រាស់)

[៣៣] រូបភាពមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

- ឧបករណ៍ពិនិត្យរកសារធាតុជាតិញៀនកំរិតខ្ពស់ (ឧបករណ៍ ផ្នែកវិជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាល)
- ឧបករណ៍ពិសោធន៍សារធាតុជាតិញៀនទូទៅ និងកំរិតខ្ពស់ GC (ឧបករណ៍ខ្នាតធំរបស់មន្ទី ពិសោធន៍គ្រឿងញៀននៃ អ.ជ.ប.គ.ញ)
- ឧបករណ៍តាមដានសកម្មភាពរបស់ជនល្មើស ( ដែលមានដូចជាកាំម៉េរា ឧបករណ៍តាមដានជាតិផ្ទុះ។ល។)
- ឧបករណ៍ស្កេនវត្ថុ (ឧបករណ៍ដែលគេប្រើប្រាស់ក្នុងព្រលានយន្តហោះ ឬ តាមអយស្ម័យយាន្ត) ។[៣៤]

[៣៤] មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ

# ជំពូកទី ៣

# នីតិវិធីទាក់ទងនឹងបទល្មើសគ្រឿងញៀន

ចំពោះបទល្មើសគ្រឿងញៀន ការចាត់ចែងនឹងការដាក់ពិន័យវាពិតជារឿងដែលសំខាន់ ប៉ុន្តែក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ ក៏មានមាត្រាដែលនិយាយពីការដាក់ពិន័យជាការព្យាបាលនឹងស្តានីតិសម្បទាផងដែរ យើងខ្ញុំនឹងធ្វើការបកស្រាយនូវក្នុងកថាខណ្ឌខាងក្រោម ។

## ផ្នែកទី១ បទល្មើសនឹងទោសបញ្ញត្តិ

ស្ថិតក្នុងចំនុចនេះ គឺការបង្ហាញសំដៅលើការអនុវត្តមាត្រានៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ក្នុងការដាក់កំណត់ប្រភេទនៃបទល្មើសដែលកើតឡើងនោះថាជាបទល្មើសជាប់ពាក់ព័ន្ធនឹងមាត្រាមួយណា ហើយក៏មានការទាក់ទងនឹងការដាក់ទណ្ឌកម្មដែលឈានដល់ការជាប់ពន្ធនាគារ រួមនឹងការដាក់ពិន័យផងដែរ ។

### កថាខណ្ឌទី ១ បទល្មើសនឹងទោសពិន័យ

តាមរយៈច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ បានធ្វើការកំណត់នឹងបែងចែកនូវបទល្មើសដែលទាក់ទង និងគ្រឿងញៀនជាច្រើនដែលមានដូចជា៖

- ការដាំដុះ ការផលិត ការរក្សាទុក ការជួញដូរ ដឹកជញ្ជូន
- ការរើបអូសយកសារធាតុញៀន
- ការចាត់ចែង ឬ ចែកចាយ
- ការបង្ខំ ឬ ការអូសទាញអោយប្រើប្រាស់
- ការសម្រួលផ្តល់ទីកន្លែង
- ការប្រើប្រាស់ខុសច្បាប់ ។ល។

#### ក. តារាងសង្ខេបបទល្មើសនឹងទោសពិន័យ

ខាងក្រោមនេះជាតារាងដែលសង្ខេបរៀបរៀងពីបទល្មើសដែលទាក់ទងនឹងគ្រឿងញៀនរួមនឹងទោសពិន័យផងដែរ ៖

| **បទល្មើស (ប្រព្រឹត្តចេតនា)** | **ប្រភេទគ្រឿងញៀន (បរិមាណសុទ្ធ) និង ប្រភេទបទល្មើស** | **ទណ្ឌកម្ម (ពន្ធនាគារ/ពិន័យជាប្រាក់)** |
|---|---|---|
| **មាត្រា ៣៨ បទដាំដុះ** | ក្នុងករណីប្រើប្រាស់ផ្ទាល់ខ្លួនក្នុងបរិមាណតិចតួចឬ ប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាម ទម្លាប់ឬចែកចាយធ្វើពាណិជ្ជកម្ម | - ៦ខែដល់២ឆ្នាំ និងអាចពិន័យ ១លានរៀល ដល់ ៤ លានរៀល<br>- ២ឆ្នាំ ដល់៥ឆ្នាំ និងអាចពិន័យ ៤លានរៀលដល់ ១០លានរៀល ។ |
| **មាត្រា ៣៩ បទផលិត**[៣៥] (ចំរាញ់ ឬ ញែកបន្សុទ្ធ បំប្លែងផ្សំ។ល) | - **ជ័រអាភៀនជ័រកញ្ឆាឬការកូកា** (៨០០ក្រ- ១៦០០ក្រឡើង)<br>- **ប្រេងកញ្ឆា**(២០០ក្រ - ៨០០ក្រឡើង)<br>- **ម័រហ្វីនហេរ៉ូអ៊ីន ឬ កូកាអ៊ីន** (៨ក្រ - ៨០ក្រឡើង)<br>**អំហ្វេតាមីនមេតំហ្វេតាមីនឬអ៊ិចស្តាស៊ី** (១៥ក្រ - ២៨០ក្រឡើង)<br>- **សារធាតុញៀនក្នុងតារាងទី ១ ទី ២** | - ២ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យ ៤លានរៀល ដល់១០លានរៀល<br>- ៥ដល់១០ឆ្នាំ និងអាចពិន័យ១០លានរៀល ដល់២០លានរៀល<br>- ពី ១០ឆ្នាំ ដល់២០ឆ្នាំ និងអាចពិន័យ ២០ លានរៀលដល់ ៤០ លានរៀល ។<br>- ពី២០ឆ្នាំដល់៣០ឆ្នាំឬ អស់មួយជីវិត និង ពិន័យពី ១០លានរៀល |

[៣៥] អំពើផលិតដោយខុសច្បាប់នូវសារធាតុញៀនគឺជាការចំរាញ់ឬការញែកសារធាតុញៀនចេញពីរុក្ខជាតិការបន្សុទ្ធការបំប្លែងការផ្សំឬសកម្មភាពតាមគ្រប់រូបភាពផ្សេងទៀតដោយខុសច្បាប់ដើម្បីទទួលបាននូវគ្រឿងញៀន។

| | | |
|---|---|---|
| **មាត្រា ៤០**<br>**បទរក្សាទុក**[៣៦]<br>**ដឹកជញ្ជូន**[៣៧]<br>**ឬ ជួញដូរ**[៣៨]<br>(កាន់កាប់លាក់ទុក ការជញ្ជូនការធ្វើការចរាចរការនាំចូលនាំចេញ ការផ្តល់សម្រាប់លក់ ការទិញដើម្បីលក់ឬដោះដូរជ័រអាភៀន ជ័រកញ្ឆា ឬ ការកូកាជ័រ) អាភៀនជ័រកញ្ឆា ឬ ការ | - **ជ័រអាភៀនជ័រកញ្ឆាឬការកូកា**<br>- (៨០០ក្រ - ១៦០០ក្រឡើង)<br>- **ប្រេងកញ្ឆា** (៤ក្រ - ៨០ក្រឡើង)<br>- **ម័រហ្វីនហេរ៉ូអ៊ីនឬកូកាអ៊ីន**<br>- (៨ក្រ - ៨០ក្រឡើង)<br>- **អំហ្វេតាមីនមេតំហ្វេតាមីនឬអ៊ិចស្តាស៊ី** (១៥ក្រ - ២៤០ក្រឡើង)<br>- **កញ្ឆាស្ងួតឬស្លឹកកូកា**(៨គក្រ - ៤០គក្រឡើង)<br>- **ផ្លែអាភៀនស្រស់**(៨គក្រ - ១២០គក្រឡើង)<br>- **ផ្លែអាភៀនស្ងួត**(៤០គក្រ - ៤៨០គក្រឡើង)<br>- **សារធាតុញៀនក្នុងតារាងទី១ទី២** | -២ឆ្នាំដល់៥ឆ្នាំ និងអាចពិន័យ៤លានរៀលដល់ ១០លានរៀល<br>-៥ដល់១០ឆ្នាំ និងអាចពិន័យ១០លានរៀល ដល់២០លានរៀល<br>-ពី១០ឆ្នាំដល់២០ឆ្នាំនិងអាចពិន័យ២០លាន រៀលដល់៤០លានរៀល<br>-ពី២០ឆ្នាំដល់៣០ឆ្នាំឬ អស់មួយជីវិតនិងពិន័យ ពី ៤០ លានរៀលដល់ ១០០លានរៀល ។ |
| **មាត្រា ៤១**<br>**បទរឹបអូសយកសារធាតុញៀន** | - បទរឹបយកសារធាតុញៀនក្នុង តារាងទី ១ ទី ២<br>- ប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុង ឱកាសបំពេញមុខងារ | -ពី២ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យពី ៤ លានរៀល ដល់ ១០ លានរៀល<br>-ពី៥ឆ្នាំដល់១០ឆ្នាំនិងត្រូវពិន័យបន្ថែមពី១០លាន រៀល ដល់ ២០ លាន រៀល ។ |

[៣៦] អំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនគឺជាការកាន់កាប់ការលាក់ទុកសន្និធិនិងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន។

[៣៧] អំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀនគឺជាការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទីពីទីកន្លែងមួយទៅទីកន្លែងមួយទៀតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍តាមរយៈការធ្វើការធ្វើចរាចរការនាំចូលឬការនាំចេញ។

[៣៨] អំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនគឺជាការផ្តល់សម្រាប់លក់ការលក់ការទិញដើម្បីលក់ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន។

| បទល្មើស (ប្រព្រឹត្តចេតនា) | ប្រភេទគ្រឿងញៀន (បរិមាណសុទ្ធ) និងប្រភេទបទល្មើស | ទណ្ឌកម្ម (ពន្ធនាគារ/ពិន័យជាប្រាក់) |
|---|---|---|
| **មាត្រា ៤២**<br>**បទចាត់ចែង**<br>(ជួយដឹកនាំបែងចែកបញ្ញា ឬចែកចាយ) | - ចាត់ចែងអោយប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនក្នុងតារាងទី១ទី២<br>- ប្រព្រឹត្តច្រើនដង<br>- ចំពោះអនីតិជនដែលមានអាយុចាប់ពីក្រោម១៥ឆ្នាំ និងលើសពី១៥ឆ្នាំឡើងទៅ<br>- ដឹងថាស្ត្រីមានគភ៌<br>- បុគ្គលកំពុងទទួលវិធានការព្យាបាល<br>- បង្កអោយមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពអ្នកដទៃ<br>- បង្កអោយមនុស្សស្លាប់ | - ២ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យ ៤ លានរៀលដល់ ១០ លានរៀល<br>- ៥ដល់១០ឆ្នាំនិងអាចពិន័យ ១០ លានរៀល ដល់ ២០ លានរៀល<br>- ពី ១០ឆ្នាំដល់២០ឆ្នាំនិងអាចពិន័យ ២០ លាន រៀលដល់ ៤០ លាន<br>- ពី ២០ ឆ្នាំដល់ ៣០ ឆ្នាំឬអស់មួយជីវិតនិងពិន័យពី ៤០ លានរៀលដល់ ១០០ លានរៀល ។ |

| | | |
|---|---|---|
| **មាត្រា ៤៣**<br>**បទបង្ខំ អូសទាញ**<br>(អំពើហឹង្សាគំរាមកំហែង ដោយប្រើហិង្សាបញ្ចុះ បញ្ចូលលួងលួមញុះញុង ឬប្រើឧបាយកល ផ្សេងៗ) | - បទបង្ខំអូសទាញអោយអ្នកដទៃប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀនក្នុង តារាង ទី១ទី២<br>- ប្រព្រឹត្តច្រើនដង<br>- មូលហេតុគំនុំឬព្យាបាទ<br>- អនីតិជនដែលមានអាយុចាប់ពីក្រោម ១៥ឆ្នាំ និងលើសពី១៥ឆ្នាំឡើងទៅ<br>- ដឹងថាស្ត្រីមានគិភ<br>- បុគ្គលកំពុងទទួលវិធានការព្យាបាល<br>- បង្កអោយមានការខូចខាតធ្ងន់ធ្ងរដល់ សុខភាពអ្នកដទៃ<br>- ក្នុងករណីប្រព្រឹត្តបទល្មើសបណ្តាល អោយស្លាប់មនុស្សច្រើននាក់ | - ២ឆ្នាំដល់៥ឆ្នាំនិងអាច ពិន័យ ៤ លានរៀលដល់ ១០ លានរៀល<br>- ៥ដល់១០ឆ្នាំនិងអាច ពិន័យ ១០ លានរៀល ដល់ ២០ លានរៀល<br>- ពី១០ឆ្នាំដល់២០ឆ្នាំ និង អាចពិន័យ ២០លាន រៀល ដល់ ៤០ លាន<br>- ពី ២០ ឆ្នាំដល់ ៣០ឆ្នាំឬ អស់មួយជីវិតនិងពិន័យ ពី ១០ លានរៀល ដល់ ១០០ លានរៀល ។ |
| **មាត្រា ៤៤**<br>**បទសម្រួល**<br>(ជួលទីកន្លែងឬផ្តល់ទីកន្លែងឬអំពើផ្សេងៗ សំរាប់ប្រើប្រាស់គ្រឿងញៀន) | - បង្កលក្ខណៈងាយស្រួលដល់ការប្រើ ប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ក្នុងតារាងទី១ទី២<br>- ប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃមុខងារ ឬ ក្នុងឱកាសបំពេញមុខងារ<br>- អនីតិជន<br>- ដឹងថាស្ត្រីមានគិភ<br>- ចំពោះមនុស្សច្រើននាក់ | - ១ឆ្នាំដល់៥ឆ្នាំនិងអាច ពិន័យ២លានរៀលដល់ ១០លានរៀល<br>- ដល់១០ឆ្នាំនិងពិន័យពី ១០ លានរៀលដល់ ២០ លានរៀល ។ |
| **មាត្រា ៤៥**<br>**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** | - ដោយប្រើប្រាស់ខុសច្បាប់ នូវសារធាតុ ញៀនស្ថិតក្នុងតារាង ទី ១ ទី ២ និងធ្លាប់ ទទួលរងនូវវិធានក្នុងការព្យាបាលដោយ បង្ខំ។<br>- ក្នុងករណីមិនរាងចាល | - ពី១ខែដល់៦ខែនឹង អាចពិន័យពី១សែន ទៅ១លានរៀល<br>- ៦ខែទៅ១ឆ្នាំនឹងអាច ពិន័យពី ១ លានរៀល ដល់ ២ លានរៀល ។ |

| | | |
|---|---|---|
| **មាត្រា ៥៤ ផលិតរក្សាទុក ដឹកជញ្ជូនជួញដូរនូវសារធាតុគីមីផ្សំដែល ស្ថិតក្នុងតារាងទី៤ក្នុងគោលដៅផលិតខុសច្បាប់** | - បទល្មើសច្រើនដងមានលក្ខណៈជាមុខរបរក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសបំពេញមុខងារ (សារធាតុគីមីផ្សំចាប់ពី១គក្រដល់១០គក្រ) | - ៥ដល់១០ឆ្នាំនិងអាចពិន័យ ១០លានរៀលដល់ ២០ លានរៀល<br>- ពី ១០ឆ្នាំ ដល់២០ឆ្នាំនិងអាចពិន័យ ២០ លានរៀលដល់ ៤០ លានរៀល ។<br>- ពី២០ឆ្នាំដល់៣០ឆ្នាំឬអស់មួយជីវិត និងពិន័យជាទឹកប្រាក់៤០ លានរៀល ដល់១០០ លានរៀល ។ |
| **មាត្រា៥៥ បទផ្តល់អោយអនីតិជនហិតស្រូបនូវសារធាតុគីមីផ្សំជាអាទិ៍** | - ផ្តល់អោយអនីតិជននូវសារធាតុគីមីផ្សំ ឬសារធាតុផ្សេងៗដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ<br>- ដឹងច្បាស់ថាជាអនីតិជននោះនឹងយកសារធាតុទាំងនោះទៅហិតស្រូប<br>- ជនរងគ្រោះច្រើននាក់បណ្តាលអោយគ្រោះថ្នាក់ធ្ងន់ធ្ងរ | - ១ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យ ២ លានរៀលដល់ ១០ លានរៀល<br>- ៥ដល់១០ឆ្នាំនិងពិន័យពី ១០ លានរៀលដល់ ២០ លានរៀល ។ |
| **មាត្រា ៥៦ បទផលិតរក្សាទុកដឹកជញ្ជូន ឬ ជួញដូរ** | - ផលិតរក្សាទុកដឹកជញ្ជូនឬជួញដូរ ឬប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនឬដោយដឹងថាបរិក្ខារឬសម្ភារក្នុងគោលដៅផលិតឬប្រើប្រាស់ដោយខុសច្បាប់<br>- មានលក្ខណៈជាមុខរបរក្នុងក្របខ័ណ្ឌមុខងារឬឱកាសបំពេញមុខងារ | - ១ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យ ២ លានរៀលដល់ ១០ លានរៀល<br>- ៥ដល់១០ឆ្នាំនិងពិន័យពី ១០ ដល់លានរៀល ២០លានរៀល ។ |

| | | |
|---|---|---|
| **មាត្រា ៥៧**<br>**បទញុះញង់**<br>**អោយប្រព្រឹត្តបទល្មើស** | - ញុះញង់ដោយផ្ទាល់ ឬប្រយោលអោយអ្នកដទៃប្រព្រឹត្តបទល្មើស<br>- ញុះញង់ទៅលើអនីតិជន | - ៦ខែដល់២ឆ្នាំនិងអាចពិន័យ ១ លានរៀល ដល់ ៤ លានរៀល<br>- ២ដល់៥ឆ្នាំនិងពិន័យពី៤ លានរៀលដល់ ១០លានរៀល ។ |
| **មាត្រា ៥៨**<br>**បទទទួលផលបទល្មើស**<br>ទទួល លាក់បាំងរក្សាទុក ឬ បញ្ជូនវត្ថុនោះបានពីបទ ឧក្រិដ្ឋឬបទមជ្ឈឹមនៃច្បាប់នេះ | - ធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយដោយដឹងថារបស់នោះបានពីបទឧក្រិដ្ឋ ឬមជ្ឈឹមនៃច្បាប់<br>- ទទួលផលបទល្មើសដោយដឹងពីហេតុការណ៍នៃបទឧក្រិដ្ឋ | - ២ឆ្នាំដល់៥ឆ្នាំនិងអាចពិន័យ ៤ លានរៀល ដល់ ១០ លានរៀល<br>- ៥ដល់១០ឆ្នាំនិងពិន័យពី ១០ លានរៀល ដល់ ២០លានរៀល ។ |
| **មាត្រា ៥៩**<br>**បទចូលរួមក្នុងក្រុមឧក្រិដ្ឋជន** | - ក្រុមឧក្រិដ្ឋជនចាប់ពី ៣នាក់ឡើងទៅដែលមានអង្គការចាត់តាំងបែបជារចនាសម្ព័ន្ធ | - ២ ឆ្នាំដល់៥ឆ្នាំ និងអាចពិន័យ ៤ លានរៀល ដល់ ១០លានរៀល ។ |
| **មាត្រា ៦០**<br>**ការផ្តន្ទាទោសចំពោះ មេដឹកនាំក្រុមឧក្រិដ្ឋជន** | - ក្រុមឧក្រិដ្ឋជនបានប្រព្រឹត្តបទល្មើសចាប់ពីមាត្រា ៣៨ ដល់មាត្រា ៤២ មាត្រា ៤៧ ដល់មាត្រា ៥០ មាត្រា៥៦ និង មាត្រា៧១ | - បើទោសតិចជាង ១០ ឆ្នាំត្រូវពិន័យជាប្រាក់ទ្វេឡើង<br>- បើទោសលើសពី ១០ ឆ្នាំឬអស់មួយជីវិតត្រូវពិន័យជាប្រាក់១០០ លានរៀល ដល់ ៥០០ លានរៀល ។ |

| | | |
|---|---|---|
| **មាត្រា ៦២ បទបំពានលើ បទប្បញ្ញត្ត ឬបទបញ្ជាស្តីពីការគ្រប់គ្រង** | - ជនដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងត្រួតពិនិត្យអធិការកិច្ច ការនាំចេញ ការនាំចូល ការដឹកជញ្ជូន ការលក់ ការទិញ ការរក្សាទុក ការបែងចែកការ ប្រើប្រាស់នូវឱសថដែលមានសារធាតុញៀន ឬសារធាតុគីមីផ្សំបាន បំពានលើបទ ប្បញ្ញត្ត ឬបទបញ្ជាស្តីពីការគ្រប់គ្រងការប្រើប្រាស់ឱសថឬសារធាតុទាំងនោះ | - ១ ខែដល់១ឆ្នាំនឹងអាចពិន័យពី ១ សែនរៀល ដល់ ២ លានរៀល<br>- ១ ឆ្នាំដល់៥ឆ្នាំ និងអាចពិន័យ ២ លានរៀល ដល់ ១០ លានរៀល ។ |
| **មាត្រា ៦៣ បទបើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀន** | - បទបើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀន | - ពី១ខែដល់២ឆ្នាំនិងអាចត្រូវពិន័យពី ១ សែនរៀល ដល់ ៤ លានរៀល ។ |
| **មាត្រា ៦៨ បទគេចវេះពីកាតព្វកិច្ចព្យាបាលដោយបង្ខំ** | - គេចវៀសពីវិធានការព្យាបាលដោយបង្ខំ | - ពី១ខែដល់១ឆ្នាំនិងអាចត្រូវពិន័យជាប្រាក់ពី ១ សែនរៀល ដល់ ២ លានរៀល ។ |
| **មាត្រា ៧១ និង ៧២ បទសំអាតប្រាក់និងស្ថានទម្ងន់ទោស** | - ការសំអាតប្រាក់បានពីជំនួញគ្រឿងញៀនខុសច្បាប់<br>- បទល្មើសច្រើនដង ប្រើភាពងាយស្រួលដែលការប្រកបនូវសកម្មភាពវិជ្ជាជីវៈផ្តល់អោយ | - ២ ឆ្នាំដល់៥ឆ្នាំ និងអាចពិន័យ ៤ លានរៀល ដល់ ១០ លានរៀល<br>- ៥ ដល់ ១០ឆ្នាំនិងអាចពិន័យ ១០ លានរៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬ តម្លៃទ្រព្យសម្បត្តិនៃវត្ថុនោះ ។ |

ក្រៅពីទោសទណ្ឌខាងលើក្នុងច្បាប់ផ្សេងទៀតមិនអាចយកមកអនុវត្តបាននោះឡើងលើកលែងតែតាមបទប្បញ្ញត្តិគន្លីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌតែប៉ុណ្ណោះ។[៣៩]

**ខ. សមត្ថកិច្ចដែលអនុវត្តន៍នីតិវិធី**

ក្នុងការអនុវត្តនីតិវិធី ក្រៅពីមន្ត្រីសមត្ថកិច្ចនគរបាលយុត្តិធម៌ចាំបាច់ណាស់គឺត្រូវមានការចូលរួមពីសំណាក់តុលាការនៃក្រសួងយុត្តិធម៌សំរាប់ធ្វើការចោទប្តឹង និងសើបសួរជំនុះជម្រះដាក់ទោសទៅលើបទល្មើសដែលដែលជនល្មើសបានប្រព្រឹត្តិខុស ។ ប៉ុន្តែដោយបទល្មើសគ្រឿងញៀនខុសគ្នានឹងបទល្មើសដ៏ទៃ ព្រោះពិរុទ្ធជនដែលប្រើប្រាស់គ្រឿងញៀនមិនអាចរង់ចាំតាមនីតិវិធីកំណត់បានទេព្រោះពួកគេត្រូវការគ្រឿងញៀនមកបំពេញក្នុងខ្លួនដើម្បីទប់ស្កាត់ការមានគ្រោះថ្នាក់នានាដោយចៃដន្យដែលអាចកើតមានលើខ្លួនពិរុទ្ធជន ឬ គ្រោះថ្នាក់ដល់អ្នកដទៃ ។ ដូច្នេះហើយទើបត្រូវចាំបាច់មានការចូលរួមពីសំណាក់ ក្រសួងសុខាភិបាល ដើម្បីធានានូវបច្ចេកទេស និងបច្ចេកវិជ្ជាក្នុងការទប់ស្កាត់ រួមនឹងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធានាការរៀបចំមណ្ឌលព្យាបាលសំរាប់អ្នកប្រើប្រាស់គ្រឿងញៀន និងស្ថាប័នដែលអាចពាក់ព័ន្ធមួយចំនួនទៀត [៤០]។

**កថាខណ្ឌទី ២ ការព្យាបាល និងស្តានីតិសម្បទា**

ក្នុងការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន ជារឿងមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាលបានកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ព្រោះឥទ្ធិពលនៃគ្រឿងញៀនបានបំផ្លាញយ៉ាងច្រើននូវធនធានមនុស្ស ក៏ដូចជាឧបសគ្គធំក្នុងការរារាំងការអភិវឌ្ឍន៍ប្រទេសជាតិអោយមានការរីកចម្រើនខ្លាំងផងដែរ ។ ដោយកត្តាចម្បងនេះហើយ ទើបអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមនឹងប្រមុខថ្នាក់ដឹកនាំនាបច្ចុប្បន្នបានខិតខំយ៉ាងខ្លាំង ក្នុងការទាញយកធនធានមនុស្សដែលកំពុងប្រើប្រាស់គ្រឿងញៀនអោយចូលមករស់នៅក្នុងសង្គមវិញតាមរយៈការធ្វើសមាហរកម្ម ។

**ក. នីតិវិធីក្នុងការព្យាបាល និងស្តារនីតិសម្បទា**

ជាគោលការណ៍ ការព្យាបាល និងស្តារនីតិសម្បទាអាចធ្វើទៅបាន លុះត្រាតែមានការទទួលបានការព្រមព្រៀងពីអ្នកញៀនគ្រឿនញៀនជាមុន ។ ប៉ុន្តែការព្យាបាល និងស្តារនីតិសម្បទាអាចកើតមានឡើងក្នុងករណីពិសេសដើម្បីជាប្រយោជន៍ដល់អ្នកប្រើប្រាស់គ្រឿងញៀននោះ និងផល

[៣៩] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១២៤

[៤០] ផែនការជាតិ ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២០០៥-២០១០ ទំព័រ ២៦

ប្រយោជន៍ទូទៅផង។[41] ហេតុនេះនីតិវិធីក្នុងការព្យាបាល និងស្តារនីតិសម្បទាសំរាប់អ្នកប្រើប្រាស់នូវគ្រឿងញៀនខុសច្បាប់ត្រូវបានចែកជាពីរដែលមានដូចជាៈ

- ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត[42]

- ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ ។[43]

ក្នុងការព្យាបាល និងស្តារនីតិសម្បទាទោះស្ថិតក្នុងការស្ម័គ្រចិត្តក្តី ឬការបង្ខំក្តីត្រូវបានការពារនឹងរក្សាការសម្ងាត់រាល់ព័ត៌មានអំពី អត្តសញ្ញាណ រោគវិនិច្ឆ័យ ការវិវត្តប្រែប្រួលនៃជំងឺ ឬទាក់ទងនៃការព្យាបាលជាដើមរបស់អ្នកញៀនគ្រឿងញៀនទៅកាន់សាធារណៈ ឬចែករំលែកទៅកាន់បុគ្គលភ្នាក់ងារផ្សេងណាមួយឡើយ លើកលែងតែក្នុងករណីដែលជាតម្រូវការនៃប្រយោជន៍របស់សាធារណៈ ។[44]

ឧទាហរណ៏ៈ មានបុរសម្នាក់ឈ្មោះ ភក្ត្រា ប្រើប្រាស់ថ្នាំញៀនហើយគាត់មានបំណងចង់ផ្តាច់វាវិញគាត់បានទៅទទួលការព្យាបាលនៅមណ្ឌលកែប្រែមួយ ដោយមានការពិភាក្សាព័ត៌មានមុននឹងធ្វើការព្យាបាល ប៉ុន្តែគាត់មិនទាន់បានធ្វើការព្យាបាលនៅពេលនោះទេ ។ ដូច្នេះព័ត៌មាននានាដែលទាក់ទងនឹងនិងភក្ត្រា ខាងមណ្ឌលកែប្រែមិនអាចធ្វើការផ្សព្វផ្សាយជាសាធារណៈ ឬផ្តល់ព័តិពីការប្រើប្រាស់គ្រឿងញៀនរបស់លោកភក្ត្រាទៅកាត់អ្នកដ៏ទៃបាននោះទេ ។

**ខ. ភ្នាក់ងារក្នុងការព្យាបាល និងស្តារនីតិសម្បទា**

ភ្នាក់ងារដែលមានការទាក់ទងទៅនឹងការព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀននៅក្នុងប្រទេសកម្ពុជារួមមានភ្នាក់ងាររដ្ឋ និងឯកជន ចាំបាច់ត្រូវមានផ្នែកសេវាវេជ្ជសាស្ត្រ និងផ្នែកសេវាសង្គមកិច្ចសមស្របទៅតាមបែបវិទ្យាសាស្ត្រជាដាច់ខាតដោយតម្រូវតាមលក្ខខណ្ឌៈ

- ការព្យាបាល និងការស្តារនីតិសម្បទាត្រូវគ្រប់គ្រងដោយអ្នកជំនាញផ្នែកថែទាំសុខភាព និងអ្នកជំនាញផ្នែកស្តារនីតិសម្បទា ។
- វិធិសាស្ត្រព្យាបាល និងស្តារនីតិសម្បទាត្រូវតែច្បាស់លាស់ចំពោះសេចក្តីត្រូវការតាមរោគសញ្ញារបស់បុគ្គលម្នាក់ៗ ហើយត្រូវបានសម្រេចដោយអ្នកជំនាញផ្នែកថែទាំសុខភាព និង

[41] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០១
[42] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០៤
[43] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០៧
[44] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០៣

អ្នកជំនាញផ្នែកស្តារនីតិសម្បទាដោយមានការពិគ្រោះយោបល់ និងយល់ព្រមពីបុគ្គលនោះជាមុន ។

- ការព្យាបាល និងស្តារនីតិសម្បទាត្រូវបានគោលការស្របទៅតាមទិសដៅជាតិ និងអន្តរជាតិហើយការប្រតិបត្តិត្រូវធ្វើអោយបានល្អបំផុត ទៅលើវិធានការព្យាបាលភាពញៀនអោយមានប្រសិទ្ធភាព និងមនុស្សធម៌ ។
- ការព្យាបាល ត្រូវគ្រប់គ្រងក្នុងផលប្រយោជន៍តែមួយគត់សម្រាប់អ្នកញៀនគ្រឿងញៀនដើម្បីអោយពួកគេទទួលបានសមត្ថភាពតាមផ្លូវច្បាប់យ៉ាងពេញលេញ ។
- ការព្យាបាលត្រូវបានកំណត់ពេលវេលា ដោយរយៈពេលចាប់ពី ៦ខែ ទៅ ២ឆ្នាំ ។

ក្នុងការព្យាបាល និងស្តារនីតិសម្បទានេះទោះបីស្ថិតក្នុងកាលៈទេសៈ ឬ ករណីបែបណាមួយក៏ដោយអ្នកដែលត្រូវទទួលការព្យាបាល គ្មានបុគ្គលម្នាក់ណាត្រូវបានគេយកជាកម្មវត្ថុក្នុងការពិសោធផ្នែកវេជ្ជសាស្ត្រ ឬ វិទ្យាសាស្ត្របានឡើយ។[៤៥]

នៅក្នុងប្រទេសកម្ពុជាយើងមជ្ឈមណ្ឌលសាធារណៈសំរាប់ព្យាបាល និងស្តារនីតិសម្បទាជាមណ្ឌលរបស់រដ្ឋ ហើយរាល់ការចំនាយគឺជាបន្ទុករបស់រដ្ឋផងដែរ ។ ប៉ុន្តែមជ្ឈមណ្ឌលនេះមានសិទ្ធិអាចទទួលនៅរាល់វិភាគទានផ្សេងៗពីគ្រប់ទិសទីដើម្បីយកមកទ្រទ្រង់ដំណើរការនៃមជ្ឈមណ្ឌល ។ ទោះបីមានមជ្ឈមណ្ឌលសាធារណៈរបស់រដ្ឋក៏ដោយ វត្តមានរបស់មជ្ឈមណ្ឌលឯកជននៅតែជាការចាំបាច់ក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនផងដែរ។ ហើយកម្ពុជាទាំងមូលនាពេលបច្ចុប្បន្ននេះយើងមានមជ្ឈមណ្ឌលសំរាប់ព្យាបាល និងស្តារនីតិសម្បទាទាំងសាធារណៈ និងឯកជនចំនួន ១៨កន្លែងនៅបណ្តាលខេត្ត-ក្រុង ។

ដើម្បីសំរេចបាននូវគោលបំណងក្នុងការបើកនូវមជ្ឈមណ្ឌលឯកជន សំរាប់ការព្យាបាល និងស្តារនីតិសម្បទាចាំបាច់ត្រូវមានលក្ខខណ្ឌមួយចំនួនដែលត្រូវបំពេញដូចជា៖

- មានអ្នកជំនាញគ្រប់គ្រាន់ ខាងអ្នកថែទាំ និងអ្នកស្តារនីតិសម្បទា
- មានជំនាញសមស្របដែលទទួលយកបាន
- ត្រូវមានការទទួលស្គាល់ពីក្រសួងសុខាភិបាលលើផ្នែកព្យាបាល
- ត្រូវមានការទទួលស្គាលពីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាលើផ្នែកស្តារនីតិសម្បទា

[៤៥] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០២

- ក្រោយទទួលបានការទទួលស្គាល់ពីក្រសួងទាំងពីរត្រូវជូនដំណឹងរាយការណ៍ទៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- មជ្ឈមណ្ឌលដែលបានបើកត្រូវទទួលការដឹកនាំពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រាល់ការទទួលព្យាបាលអ្នកញៀនគ្រឿងញៀន ត្រូវធ្វើតាមមាត្រាដែលមានក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។[៨៦]

## ផ្នែកទី២ វិធានការនិងដំណោះស្រាយក្នុងការអនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា

ដើម្បីអោយការអនុវត្តច្បាប់មានជំហានបោះទៅមុខបាន គេត្រូវការមានវិធានការដែលល្អ និងមានប្រសិទ្ធភាព រួមនឹងដំណោះស្រាយផងដែរ ។

### កថាខណ្ឌទី ១ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

ខាងក្រោមនេះ និងធ្វើការបង្ហាញនូវគោលវិធានការក្នុងការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ក៏ដូចជាធ្វើអោយប្រទេសកម្ពុជាកាត់បន្ថយនូវគ្រឿងញៀនផងដែរ ។

#### ក. វិធានការណ៍ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន

គ្រប់មុខទំនិញទាំងអស់ទោះតូច ឬធំ ជាធម្មតាគេផលិតឡើងតាមតម្រូវការទីផ្សារ ឬអ្នកប្រើប្រាស់តែប្រសិនបើគ្មានតម្រូវការទេ ក៏គ្មានអ្នកផលិតផ្គត់ផ្គង់នោះដែរ រីឯគ្រឿងញៀនក៏ដូចជាទំនិញដែរ ប្រសិនបើគ្មានអ្នកប្រើប្រាស់ទេក៏គ្មានអ្នកផលិត ។ ដូចនេះដើម្បីកាត់បន្ថយការផលិត ការចរាចរ ការផ្គត់ផ្គង់គ្រឿងញៀន និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ចាំបាច់ត្រូវតែកាត់បន្ថយអ្នកប្រើប្រាស់គ្រឿងញៀនជាមុខសិន ។

#### ខ. វិធានការក្នុងការទប់ស្កាត់គ្រឿងញៀន

វិធានការទប់ស្កាត់គ្រឿងញៀន គឺមានបំណងដើម្បីកាត់បន្ថយតម្រូវការគ្រឿងញៀន និងកាត់បន្ថយការផ្គត់ផ្គង់ ឬ ការដាំដុះរុក្ខជាតិញៀន ។ ដើម្បីធ្វើការកាត់បន្ថយគ្រឿងញៀន និងបង្ការការប្រើប្រាស់គ្រឿងញៀននោះគេចាំបាច់ត្រូវការមាន៖

- លើកកំពស់ការយល់ដឹងពីគ្រឿងញៀនជាសាធារណៈ អំពីផលប៉ះពាល់នៃគ្រឿងញៀនក្នុងសង្គម និងគ្រួសារ ។
- ជំរុញ និងលើកទឹកចិត្តអោយមានការចូលរួមពីផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងសាសនាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

---

[៨៦] ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ មាត្រា ១០០

- ដាក់បញ្ចូលបន្ថែមអំពីគ្រឿងញៀន និងការរីករាលដាលនៃជំងឺអេដស៍ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ទៅក្នុងកម្មវិធីសិក្សាជាតិក្នុងគ្រប់កំរិតសិក្សាទោះក្នុង ឬក្រៅប្រព័ន្ធអប់រំ ដោយរាប់បញ្ចូលទាំងការបណ្តុះបណ្តាលគ្រូបង្គោលផងដែរ ។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃជាប្រចាំនូវសកម្មភាពអប់រំ និងបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀនជាមួយដៃគូពាក់ព័ន្ធ ។
- ធានាផ្តល់នូវសុខភាព ការអប់រំ និងដំណោះស្រាយទូលំទូលាយស្របតាមលក្ខណៈច្បាប់ចំពោះអ្នកប្រើបំពានគ្រឿងញៀន
- ផ្សព្វផ្សាយតាម វិទ្យុ ទូរទស្សន៍ សារព័ត៌មាន តាមបដា ខិត្តប័ណ្ណនឹងផ្ទាំងរូបភាពជាដើម ដើម្បីអោយពលរដ្ឋទូទៅដឹងពីគ្រោះថ្នាក់ និងបញ្ហាផ្សេងៗទៀតដែលមានបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន
- ត្រូវសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល អតីតអ្នកញៀនគ្រឿងញៀន ប្រព័ន្ធផ្សព្វផ្សាយ បណ្តាញឃោសនា និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអប់រំ និងបង្កាគ្រឿងញៀន
- រៀបចំអោយមានមជ្ឍមណ្ឌលសំរាប់ព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀនច្រើនតាមដែលអាចធ្វើបាន ។
- បង្កើតក្រុមប្រឹក្សាពិគ្រោះយោប់សម្រាប់តាមដានអ្នកជម្ងឺនៅតាមសហគមន៍ និងគ្រួសារអ្នកញៀនគ្រឿងញៀន ។
- លើកទឹកចិត្តអោយមានការចូលរួមពីសំណាក់សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

ការកាត់បន្ថយនូវការដាំដុះ ការផលិត និងការផ្គត់ផ្គង់គ្រឿងញៀន និងសម្រេចទៅបានជោគជ័យលុះត្រាតែធានាថា ច្បាប់នឹងយន្តការនានាត្រូវបានផ្សព្វផ្សាយ និងអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពយ៉ាងទូលំទូលាយដែលចាំបាច់ត្រូវះ

- កសាងផែនការអភិវឌ្ឍន៍ដាំដំណាំជំនួសដ៏មានប្រសិទ្ធភាពមួយដើម្បីជំនួសដំណាំគ្រឿងញៀនខុសច្បាប់ ។
- បង្កើនយុទ្ធនាការឃោសនាប្រឆាំងនឹងការដាំដុះគ្រឿងញៀនខុសច្បាប់ ។
- លើកកម្ពស់ការយល់ដឹកជាសាធារណៈអពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលសង្កត់ធ្ងន់លើទោសបញ្ញត្តិ នៃការដាំដុះ ការផលិត និងការផ្គត់ផ្គង់គ្រឿងញៀន ។

- សហការជាមួយបណ្តាលប្រទេសជិតខាងក្នុងតំបន់ និងរៀនសូត្រអំពីបទពិសោធន៍ល្អៗទាក់ទងទៅនឹងការដាំដំណាំជំនួសដែលស្របតាមស្ថានភាពភូមិសាស្រ្ត ។
- តាមរយៈគណៈកម្មការត្រួតពិនិត្យគ្រឿងញៀន ខេត្ត-ក្រុង ត្រូវបង្កើនយុទ្ធនាការឃោសនាប្រឆាំងនឹងការដាំដុះដំណាំគ្រឿងញៀនខុសច្បាប់ សំដៅកាត់បន្ថយអោយមានកំរិតទាប។
- បំផុសអោយមានការចូលរួមជាសាធារណៈក្នុងការផ្តល់ព័ត៌មានទាំងឡាយណាដែលមានការពាក់ព័ន្ធដល់ការផលិតគ្រឿងញៀនខុសច្បាប់តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្ត ។
- ត្រូវព្យាយាមលុបបំបាត់បន្តិចម្តងៗនូវទីផ្សារគ្រឿងញៀន ។

**កថាខណ្ឌទី ២ ដំណោះស្រាយបញ្ហាគ្រឿងញៀននៅកម្ពុជា**

រាល់ការអនុវត្តច្បាប់ ឬការបង្ក្រាបអ្វីមួយសុទ្ធសឹងតែមានផលល្អនឹងអាក្រក់ ហេតុនេះហើយទើបរដ្ឋាភិបាលត្រូវតែមានដំណោះស្រាយក្នុងការអនុវត្តជាមួយគ្នាផងដែរ ព្រោះដើម្បីអោយប្រទេសរីកចម្រើនបានមិនមែនសុទ្ធតែប្រើប្រាស់នូវច្បាប់មកអនុវត្តសុទ្ធសាធបាននោះទេ ។

**ក. ការបង្ក្រាបបទល្មើស**

ការបង្ក្រាបបទល្មើសគ្រឿងញៀន គឺសំដៅទៅលើសមត្ថកិច្ចចំរុះធ្វើការស៊ើបអង្កេត និងស្វែងរកភស្តុតាងដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ ដើម្បីធ្វើការបង្ក្រាបទៅលើដំណាំខុសច្បាប់ ការបង្ក្រាបទៅលើការជួញដូរគ្រឿងញៀន ការបង្ក្រាបទៅលើការផលិត ការចែកចាយ និងរក្សាទុកគ្រឿងញៀនគ្រប់ប្រទេស និងសារធាតុដែលធ្វើអោយប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទជាដើម ។ ហើយព័ត៌មានត្រូវបានប្រមូលមកពីគ្រប់ ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជាដើម្បីយកមកធ្វើការចងក្រង និងវិភាគ ។

**ខ. ដំណោះស្រាយ**

ដោយមើលឃើញពីឥទ្ធិពល និងផលប៉ះពាល់នៃគ្រឿងញៀន មកលើអ្នកប្រើប្រាស់ ក្រុមគ្រួសារ និងសង្គមទាំងមូលចាំបាច់ត្រូវមានការចូលរួមគ្នាពីគ្រប់ស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ព្រមទាំងប្រជាពលរដ្ឋទាំងអស់គ្នា ក្នុងការលុបបំបាត់ ការដាំដុះ ការផលិត ការចរាចរ ការស្តុកទុក ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន និងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទ "ការអនុវត្តច្បាប់គ្រឿងញៀននៅកម្ពុជា" រួចមកយើងអាចសន្និដ្ឋានបានដូចខាងក្រោមៈ

គ្រឿងញៀនត្រូវបានគេបែងចែកជា ពីរប្រភេទ គឺគ្រឿងញៀន ធម្មជាតិ និងគ្រឿងញៀនសំយោគ ។ គ្រឿងញៀនធម្មជាតិមាន កញ្ឆា កូកា អាភៀនជាដើម និងគ្រឿងញៀនសំយោគរួមមាន មេតំហ្វេតាមីន អំហ្វេតាមីន កូកាអ៊ីន ហេរ៉ូអ៊ីន ម័រហ្វីន អ៊ិចស្តាស៊ី...។ល។ រីឯគ្រឿងញៀនសំយោគដូចជា មេតំហ្វេតាមីន មានការកើនឡើងយ៉ាងខ្លាំងនាប៉ុន្មានឆ្នាំចុងក្រោយ ដែលភាគច្រើននៃការហូរចូលគ្រឿងញៀនប្រភេទនេះតាមច្រកនៃខេត្តស្ទឹងត្រែង ដែលមានព្រំប្រទល់នឹងប្រទេសឡាវ ចំណែកឯថ្នាំញៀនប្រភេទសំយោគផ្សេងៗទៀងដូចជា ហេរ៉ូអ៊ីន អាភៀន ម័រហ្វីន អ៊ិចស្តាស៊ី កេតាមីនក៏មានការហូរចូលតាមច្រកនៃខេត្តស្ទឹងត្រែងដែរ តែវាមានបរិមាណមិនសូវច្រើនដូចគ្រឿងញៀនសំយោគមេតំហ្វេតាមីនទេ ។ ចំនែកឯផលិតផលកញ្ឆាវិញស្ទើរតែគ្មានការដាំដុះ និងផលិតនោះទេក្នុងប្រទេសកម្ពុជានាប៉ុន្មានឆ្នាំចុងក្រោយនេះ ។

គ្រឿងញៀនវាពិតជាមានឥទ្ធិពល និងផលប៉ះពាល់ធ្ងន់ធ្ងរយ៉ាងខ្លាំងដល់អ្នកប្រើប្រាស់ជាពិសេសគ្រួសារ និងសង្គម ។ ការប៉ះពាល់ដល់អ្នកប្រើប្រាស់ ដូចជាមានការញៀន ការឆ្លងរាលដាលនៃជម្ងឺអេដស៍ ជម្ងឺថ្លើម និងជម្ងឺផ្សេងៗទៀត ហើយនឹងធ្វើអោយមានការបាត់បង់ថវិកាជាច្រើនទៅលើការទិញគ្រឿងញៀន ការខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍ ។ ហើយវាក៏បណ្តាលអោយមានអំពើជាច្រើនក្នុងសង្គមផងដែរគឺ ការកើតមានអំពើហឹង្សារក្នុងគ្រួសារ ការរើសអើងសំណាក់ក្រុមគ្រួសារ ការប៉ះពាល់មកលើផ្លូវចិត្ត និងបញ្ហាផ្សេងៗទៀត ហើយវាក៏អាចឈានទៅដល់ការកើតឡើងនៃបទល្មើសគ្រប់ប្រភេទផងដែរគឺ ការលួច ការឆក់ប្លន់ ចាប់ជំរិត ឃាតកម្ម ដែលនិងបង្កើតអោយមានក្រុមបងធំបងតូច ព្រមទាំងអាចមានក្រុមឧក្រឹដ្ឋកម្មផងដែរ ។ ការបាត់បង់ធនធានមនុស្ស និងជាពិសេសទៅទៀតរាជរដ្ឋាភិបាលនឹងត្រូវចំនាយថវិកាយ៉ាងច្រើន ក្នុងការលុបបំបាត់បញ្ហាគ្រឿងញៀន និងបង្កើតមជ្ឈមណ្ឌលកព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

ចំពោះបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងគ្រឿងញៀន ឃើញថាអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានខិតខំបំពេញការងាររបស់ខ្លួនដោយសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់នឹងបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ និងបានខិតខំបង្កើតអោយមានឡើងនូវលិខិតបទដ្ឋានគតិយុត្តិ គ្រប់ប្រភេទដែលមានការពាក់ព័ន្ធនៃបញ្ហាគ្រឿងញៀន ព្រមទាំងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ហើយក៏បានព្យាយាមសម្រេចនូវការចេញយុទ្ធសាស្ត្រថ្មីៗ ក្នុងការលុបបំបាត់បញ្ហាគ្រឿងញៀននៅកម្ពុជា ។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវចប់សព្វគ្រប់លើប្រធានបទ " ការអនុវត្តច្បាប់គ្រឿងញៀន នៅកម្ពុជា " ខ្ញុំបានមានអនុសាសន៍មួយចំនួនចំពោះរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀងដូចខាងក្រោម ៖

- គប្បីពង្រឹង និងពង្រីកបន្ថែមទៀតនូវការិយាល័យត្រួតពិនិត្យគ្រឿងញៀន តាមព្រំដែន ដោយត្រូវបំពាក់បន្ថែមនូវគ្រឿងសម្ភារៈសម្រាប់ធ្វើការត្រួតពិនិត្យគ្រឿងញៀនតាមច្រកព្រំដែន និងតាមកន្លែងសំខាន់ៗទៀតដែលមានការចរាចរ ការចែកចាយ និងការជួញដូរ ។

- គួរធ្វើយ៉ាងណាណែនាំអោយប្រជាពលរដ្ឋឈប់ដាំនូវដំដាំគ្រឿងញៀនខុសច្បាប់ ហើយប្រែក្លាយមកជាដំណាំកសិកម្មជំនួសវិញ ដូចជា ពោត សណ្តែក ដំឡូងមីជាដើម ។

- គប្បីធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដោយបញ្ចូលអោយកាន់តែច្រើននូវ ចំណេះដឹងមូលដ្ឋានស្តីពីគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សាធិការជាតិទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអប់រំចាប់ពីកម្រិតបឋមសិក្សា រហូតដល់ថ្នាក់មហាវិទ្យាល័យព្រមទាំងធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនអោយបានទូលំទូលាយដល់ប្រជាជន ដើម្បីអោយបានយល់ដឹងពីទោសទណ្ឌ នៃការដាំដុះ ការជួញដូរ និងការផលិតគ្រឿងញៀន ។

- ត្រូវបង្ក្រាបអោយខានតែបាននៅការដាំដុះ ការជួញដូរ ការផលិត ការចរាចរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅប្រទេសកម្ពុជាដោយស្វែងរកអោយឃើញនូវ បណ្តាញផលិត បណ្តាយជួញដូរ ដើម្បីធ្វើការបំផ្លាញចោល ។

- គប្បីមានយន្តការក្នុងការត្រួតពិនិត្យផ្ទៃក្នុងចំពោះមន្ត្រីអនុវត្តនន៍ច្បាប់ ជៀសវាងការឃុបឃិតគ្នាជាមួយក្រុមឧក្រិដ្ឋជនក្នុងការលាក់កំបាំង ការដាំដុះ ការផលិត ការជួញដូរ ការចរាចរ ការចែកចាយនូវគ្រឿងញៀន និងសារធាតុប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ។

- ត្រូវពង្រឹង និងពង្រីកបន្ថែមទៀត នូវមន្ត្រីអនុវត្តន៍ច្បាប់អោយមានការយកចិត្តទុកដាក់ខ្ពស់លើករណីគ្រឿងញៀន និងបទល្មើសទាក់ទងនឹងគ្រឿងញៀន និងសារធាតុដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលចាំបាច់ត្រូវបំពេញអោយបានគ្រប់គ្រាន់ និងត្រូវមានជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងបរិមាណដែលចាប់បានអោយមានគ្រប់ ខេត្ត-ក្រុង ។

- ត្រូវដាក់អោយដំណើរការនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ដោយផ្តល់នូវទីតាំង ថវិកា សម្ភារៈបច្ចេកទេស និងធនធានមនុស្សសម្រាប់បំរើការងារលើបញ្ហាគ្រឿងញៀន។

- គប្បីបង្កើត និងដាក់អោយដំណើរការនូវក្រុមការងារផ្សេងៗទៀត ដូចជាក្រុមការងារអប់រំ និងបង្ការការពារប្រើបំពានគ្រឿងញៀន និងក្រុមការងារតាមដានការអនុវត្តច្បាប់គ្រឿងញៀន ។

- គប្បីកំណត់អោយបានច្បាស់លាស់នូវការនាំចូលសារធាតុគីមីផ្សំ ដែលយកមកប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងវិស័យវេជ្ជសាស្ត្រជៀសវាងការនាំចូលដោយលើសចំនួនជាហេតុនាំអោយជនខិលខូចមួយចំនួនយកសារធាតុគីមីផ្សំនោះទៅបំលែងជាគ្រឿងញៀន ។
- គប្បីបង្កើតអោយមានមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនអោយបានយ៉ាងតិច មួយកន្លែងក្នុងមួយខេត្ត ទូទាំងប្រទេស ។
- គប្បីពង្រឹង និងពង្រីកបន្ថែមទៀតនូកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ អង្គការ ក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងប្រទេសជាច្រើនទៀត ដើម្បីដោះស្រាយនូវវិបត្តិគ្រឿងញៀននៅកម្ពុជា និងនៅលើសកលលោក ។

# ឯកសារយោង

- រដ្ឋធម្មនុញ ១៩៩៣
- អនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារ ឆ្នាំ១៩៧២
- អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវ គ្រឿងញៀន និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២
- ឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន
- បញ្ហាគ្រឿងញៀន និងគោលនយោបាយត្រួតពិនិត្យគ្រឿងញៀនរបស់រដ្ឋាភិបាលកម្ពុជា (សិក្ខាសាលាស្តីពី ការដកស្រង់បទពិសោធន៍ពីករណីបង្ក្រាបមន្ទីពីសោធន៍លួចលាក់ផលិតគ្រឿងញៀនសំយោគនៅខេត្តកំពង់ស្ពឺ ឆ្នាំ ២០០៨ )

# ឧបសម្ព័ន

# ប្រកាសបង្កើតមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ ៖ ០០១/០៦ អ.ជ.ប.គ.ញ

ប្រកាស

ស្តីពី

ការបង្កើត "មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន"

របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៧១ អន/កបក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សំ រេ ច

១. បទបញ្ញត្តិទូទៅ

ប្រការ១៖ ត្រូវបានបង្កើតអង្គភាពព័ត៌មានគ្រឿងញៀនមួយ ដែលមានឈ្មោះថា "មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន" ដោយដាក់អោយស្ថិតនៅក្នុងរចនាសម្ព័ន្ធ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ហើយទទួលការដឹកនាំផ្ទាល់របស់អគ្គលេខាធិការ ។

Tel: 023 721640, Fax: 023 721023, 023 721004

## ២. តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ

**ប្រការ២:** មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មានគ្រឿងញៀនទាំងឡាយពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការជួញដូរ ផ្លូវចរាចរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនដោយបំពាន ដោយសហការ និង សំរបសំរួលជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស ដើម្បីរៀបចំប្រព័ន្ធពត៌មានគ្រឿងញៀនមួយមានលក្ខណៈវិទ្យាសាស្ត្រ និងអាចធ្វើជាមូលដ្ឋានបាន ក្នុងការវាយតំលៃសភាពការណ៍គ្រឿងញៀន។ នៅក្នុងតួនាទីនេះ មជ្ឈមណ្ឌលពត៌មានគ្រឿងញៀនមានមុខងារសំខាន់១ដូចតទៅ:

១. រៀបចំជូនអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នូវសេវាពត៌មានគ្រឿងញៀនមួយសមស្រប ដើម្បីកសាងមូលដ្ឋានទិន្នន័យគ្រឿងញៀនថ្នាក់ជាតិមួយនៅកម្ពុជា។

២. វិវាំងនូវការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មានវិទ្យា សំដៅលើកកំពស់ប្រសិទ្ធិភាពនៃការប្រមូល ចងក្រង រក្សាទុក និង ចែកចាយទិន្នន័យពត៌មានគ្រឿងញៀន អោយមានប្រសិទ្ធិភាព ។

៣. អនុវត្ត និងសំរបសំរួលជាមួយបណ្តាអង្គភាពពាក់ព័ន្ធ អង្គការជាតិ តំបន់ អន្តរជាតិនានា ក្នុងការជំរុញវិស័យគ្រប់គ្រង ប្រមូល និង វិភាគទិន្នន័យគ្រឿងញៀន ។

**ប្រការ៣:** នៅក្នុងក្របខ័ណ្ឌនៃតួនាទី និង មុខងាររបស់ខ្លួន មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានភារកិច្ចដូចតទៅ:

១. ធ្វើជាមជ្ឈមណ្ឌលក្នុងការប្រមូល ចងក្រង វិភាគ និង រក្សាទុកនូវពត៌មានគ្រឿងញៀនគ្រប់ប្រភេទសំដៅជំរុញអោយកម្ពុជាមានទិន្នន័យគ្រប់គ្រាន់អំពីបញ្ហាគ្រឿងញៀន។

២. ជំរុញ លើកកំពស់ការអនុវត្តការប្រមូលទិន្នន័យពត៌មាន ដោយប្រើប្រាស់បច្ចេកទេសពត៌មានវិទ្យាអោយបានដល់គ្រប់អង្គភាពពាក់ព័ន្ធ សំដៅធ្វើអោយទិន្នន័យដែលទទួលបានមានលក្ខណៈវិទ្យាសាស្ត្រ និង ទាន់ពេលវេលា។

៣. ជួយអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការវាយតំលៃសភាពការណ៍គ្រឿងញៀនក្នុង និង ក្រៅប្រទេស។

៤. រៀបចំជូនអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការចេញផ្សាយនូវពត៌មានគ្រឿងញៀននានា ដែលទទួលបាន តាមបញ្ជារបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៥. គ្រប់គ្រងបច្ចេកទេសលើការដាក់អោយប្រើប្រាស់ប្រព័ន្ធបញ្ចូន និង ផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិក របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៦. សហការជាមួយអ្នកជំនាញការ និង អង្គភាពពាក់ព័ន្ធនានាក្នុងការធ្វើអង្កេតទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន និង រៀបចំនីតិវិធី ប្រមូល វិភាគ ចងក្រង និង រក្សាទុកទិន្នន័យពត៌មានគ្រឿងញៀន ។

**ប្រការ៤:** មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានថ្នាក់ស្មើការិយាល័យ និងមានរចនាសម្ព័ន្ធដូចតទៅ:

១. ផ្នែករដ្ឋបាល និងទិន្នន័យ

២. ផ្នែកសេវាបច្ចេកទេសពត៌មានវិទ្យា

៣. ផ្នែកអង្កេត និង ធ្វើស្ថិតិបទល្មើសគ្រឿងញៀន

អង្គការលេខរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៥:** មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានដឹកនាំ និង គ្រប់គ្រងដោយប្រធានមួយរូប និងអនុប្រធានចំនួនពីររូបជា ជំនួយការ ។

## ៣. អំពីផ្នែក

**ប្រការ៦:** ផ្នែករដ្ឋបាល និងទិន្នន័យ មានភារកិច្ចដូចតទៅ:

- សំរបសំរួលផ្នែករដ្ឋបាលរាល់សកម្មភាពរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- ធានាប្រសិទ្ធិភាព និង សុវត្ថិភាពរដ្ឋបាលរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- បញ្ចូលទិន្នន័យពត៌មានគ្រឿងញៀនដែលទទួលបានពីផ្នែកផ្សេងៗ និងពីអង្គភាពនានា
- សរុប ធ្វើរបាយការណ៍ការងារ និង សកម្មភាពផ្សេងៗរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- បោះពុម្ពផ្សាយព្រឹត្តិប័ត្រ និង ពត៌មានគ្រឿងញៀននានា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ក្នុងមជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- លើក និង អនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលពត៌មានគ្រឿងញៀន
- រៀបចំកិច្ចប្រជុំនានានៅក្នុងមជ្ឈមណ្ឌលពត៌មានគ្រឿងញៀន

- ទំនាក់ទំនងជាប្រចាំជាមួយមន្ត្រីទំនាក់ទំនងក្នុងខេត្ត-ក្រុងនានា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់អោយ ។

ផ្នែកត្រូវបានដឹកនាំដោយប្រធានផ្នែកមួយរូប និង មានអនុប្រធានផ្នែកចំនួនពីររូប ជាជំនួយការ ។

ប្រការ៧: ផ្នែកសេវាបច្ចេកទេសព័ត៌មានវិទ្យាមានភារកិច្ចដូចតទៅ:

- រៀបចំបង្កើតអោយមានកម្មវិធីផ្តល់ រក្សាទុក និង បញ្ជូនព័ត៌មានមួយដែលមានប្រសិទ្ធិភាព ដោយប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ និង សារតាមប្រព័ន្ធអេឡិចត្រូនិក ។
- រៀបចំអោយមានបណ្តាញផ្តល់ព័ត៌មាន និង បញ្ជូនព័ត៌មានអោយបានទៅដល់គ្រប់ខេត្ត-ក្រុងទាំងអស់
- ធ្វើសំណើពាក់ព័ន្ធនិងការរៀបចំការប្រជុំជាមួយអ្នកជំនាញការព័ត៌មានវិទ្យានានា និង ធ្វើការអភិវឌ្ឍន៍ព័ត៌មានវិទ្យាគ្រឿងញៀន អោយសមស្របតាមតម្រូវការរបស់អគ្គលេខាធិការដ្ឋាន ។
- គ្រប់គ្រងសេវាកម្មព័ត៌មានវិទ្យា និង ជួយអង្គភាពនានាក្នុងការបណ្តុះបណ្តាលពីបច្ចេកទេសកុំព្យូទ័រ និងកម្មវិធីបញ្ចូលទិន្នន័យនានា ។
- រៀបចំ និង ផ្សព្វផ្សាយជំរុញអោយប្រើប្រាស់ទំរង់បែបបទព័ត៌មានគ្រឿងញៀនតែមួយដល់គ្រប់អង្គភាពពាក់ព័ន្ធ និង គ្រប់ខេត្តក្រុង ។
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់អោយ ។

ផ្នែកនេះត្រូវបានដឹកនាំដោយប្រធានផ្នែកមួយរូប និង មានអនុប្រធានផ្នែកចំនួនពីររូប ជាជំនួយការ ។

ប្រការ៨: ផ្នែកអង្កេត និង ធ្វើស្ថិតិបទល្មើសគ្រឿងញៀន មានភារកិច្ចដូចតទៅ:

- ចាត់ចែងអោយមានការប្រមូលព័ត៌មានគ្រឿងញៀនគ្រប់ប្រភេទ រួមមានដូចជា:ព័ត៌មានអំពីអ្នកប្រើប្រាស់គ្រឿងញៀនតាមប្រភេទ ព័ត៌មានអំពីការផលិត ការជួញដូរ ការប្រើប្រាស់ ការដឹកជញ្ជូនគ្រឿងញៀន និងសំភារ:បរិក្ខារផលិតគ្រឿងញៀន ។
- រៀបចំការសិក្សាស្រាវជ្រាវពីវិធីសាស្ត្រដើម្បីធ្វើការប្រមូលព័ត៌មាន និង វិភាគព័ត៌មានអោយមានប្រសិទ្ធិភាព ។
- ដំណើរការស្ទាបស្ទង់ចំនួនអ្នកញៀនដោយសហការជាមួយបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានា ។
- សំរបសំរួលជំរុញអោយមានការបញ្ជូនព័ត៌មានគ្រឿងញៀន ផ្តល់យោបល់ក្នុងការវិភាគទិន្នន័យគ្រឿងញៀន និង ផ្តល់តឹកតាងនានាក្នុងការវាយតំលៃសភាពការណ៍គ្រឿងញៀន ពីបណ្តាអង្គភាពផ្សេងៗអោយបានជាប់ជាប្រចាំ ។

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានមជ្ឈមណ្ឌលប្រគល់អោយ ។

ផ្នែកនេះត្រូវបានដឹកនាំដោយប្រធានផ្នែកមួយរូប និង មានអនុប្រធានផ្នែកចំនួនពីររូប ជាជំនួយការ ។

## ៤. អំពីការសំរបសំរួលការងារ

**ប្រការ៩:** មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ត្រូវសហការជាមួយក្រុមការងារប្រមូលទិន្នន័យរបស់លេខាធិការដ្ឋានត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ហើយផ្នែកនីមួយៗក្នុងមជ្ឈមណ្ឌល ត្រូវសហការគ្នាធ្វើការអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួន ដើម្បីអោយសំរេចបានតាមតួនាទី និង ភារកិច្ចដែលអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រគល់ជូន ។

## ៥. អវសានបញ្ញត្តិ

**ប្រការ១០:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងស្មារតីនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១១:** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននិងប្រធានអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ[illegible] ឆ្នាំ ២០០៤

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងសមាជិក អ.ជ.ប.គ.ញ
- គណៈកម្មការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង
- ដូចប្រការ១១
- ឯកសារ-កាលប្បវត្តិ

# ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន



# ទំរង់នៃគ្រឿងញៀន

## អាភៀន







## ម័រហ្វីន







## ហេរ៉ូអ៊ីន







កូកាអ៊ីន | កញ្ឆា | ស្មៅអេហ្វេដ្រា













# តំបន់ធំៗដែលផលិតគ្រឿងញៀនក្នុងពិភពលោក

តំបន់អឌ្ឍចន្ទមាស: អ៊ីរ៉ង់ អាហ្គានីស្ថាន ប៉ាគីស្ថាន

- តំបន់ត្រីកោណមាស: ថៃ  មីយ៉ាន់ម៉ា និង ឡាវ



# សម្ភារៈសឹកដែលរឹបអូសពីក្រុមឧក្រិដ្ឋជន





Narcosub 'Drug Submarine' seized in Colombia







# ផ្លូវចរាចរគ្រឿងញៀនចូលមកក្នុងប្រទេសកម្ពុជា

- តំបន់ត្រីកោណមាស: ថៃ មីយ៉ាន់ម៉ា និង ឡាវ



# ល្បិចកលលាក់គ្រឿងញៀន









# រចនាសម្ព័ន្ធមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន



# ការិយាល័យទំនាក់ទំនងព្រំដែន ( Border Liaison Office )
# ដែលហៅកាត់ថា BLO
# ដែលមានព្រំប្រទល់ជាប់ ប្រទេស វៀតណាម ថៃ និង ឡាវ



# ករណីសមត្ថកិច្ច ការិយាល័យទំនាក់ទំនងព្រំដែន ខេត្តស្ទឹងត្រែង បង្រ្កាបការរត់ពន្ធគ្រឿងញៀន នៅថ្ងៃនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៨





## មេតំហ្វេតាមីន ១៧.៣៤៩គ្រាប់









# ករណីការបង្ក្រាបការរត់ពន្ធគ្រឿងញៀនមកក្នុងប្រទេសកម្ពុជា
# កំពង់សោម លេខ ៣៧២ ចាប់ថ្ងៃ ១៥ ខែ កក្កដា ឆ្នាំ ២០១២
# នៅកំពង់ផែស្វយ័ត






# ការបង្ក្រាបករណីដឹកជញ្ជូន នូវសារធាតុញៀនឆ្លងដែនខុសច្បាប់ តាមព្រលានយន្តហោះអន្តរជាតិភ្នំពេញថ្ងៃទី១២-០២-២០១៤















# ឧបករណ៍ខ្នាតធំពិនិត្យគ្រឿងញៀនគ្រប់ប្រភេទ





# ឧបករណ៍ពិនិត្យអ្នកប្រើប្រាស់គ្រឿងញៀន

## ( តាមទឹកនោម )








# ឧបករណ៍ប្រើប្រាស់គ្រឿងញៀន





# ការប្រើបំពានគ្រឿងញៀនតាមទំរង់គ្រប់រូបភាព







